ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

# ប្លង់គោលប្រើប្រាស់ដីខណ្ឌព្រែកព្នៅ

## ចក្ខុវិស័យឆ្នាំ ២០៣៥

រៀបចំដោយ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ

បោះពុម្ពផ្សាយលើកទី១

ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥, ខែធ្នូ ឆ្នាំ២០២១

ប្លង់គោលប្រើប្រាស់ដីខណ្ឌព្រែកព្នៅ ចក្ខុវិស័យឆ្នាំ ២០៣៥

# ប្លង់គោលប្រើប្រាស់ដីខណ្ឌព្រែកព្នៅ

## ចក្ខុវិស័យឆ្នាំ២០៣៥

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ
លេខ : ០៧៧ សសរ

# សេចក្តីសម្រេច
# ស្តីពី
# ការដាក់ឱ្យប្រើប្រាស់ប្លង់គោលប្រើប្រាស់ដីខណ្ឌព្រែកព្នៅ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
## និងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២១០/០០៣ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអស្សាមិករណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៩ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសំណង់

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១២/៤៦៣ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣១៤/៣៧៣ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការកែសម្រួលមាត្រា២ និងមាត្រា៥ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៥១២/៤៦៣ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ
- បានឃើញអនុក្រឹត្យលេខ៧៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន
- បានឃើញអនុក្រឹត្យលេខ៧៦ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា៣០ មាត្រា៣៤ មាត្រា៣៨ មាត្រា៥០ មាត្រា៦៦ មាត្រា៧៤ និងមាត្រា៨២ នៃអនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន
- បានឃើញអនុក្រឹត្យលេខ១៨១ អនក្រ.បក ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការដាក់ឱ្យអនុវត្តប្លង់គោលប្រើប្រាស់ដីរាជធានីភ្នំពេញ
- បានឃើញសេចក្តីសម្រេចលេខ០៤១ សសរ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីនីតិវិធីលម្អិតនៃការរៀបចំប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ
- យោងតាមសំណើរបស់អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញនិងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មរាជធានីភ្នំពេញ

## សម្រេច

**ប្រការ១.-**

ត្រូវបានដាក់ឱ្យប្រើប្រាស់ប្លង់គោលប្រើប្រាស់ដីខណ្ឌព្រែកព្នៅ ដែលមានចក្ខុវិស័យដល់ឆ្នាំ២០៣៥ ដូចមានឧបសម្ព័ន្ធភ្ជាប់ជាមួយសេចក្តីសម្រេចនេះ។

**ប្រការ២.-**

គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មរាជធានីភ្នំពេញ និងគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខណ្ឌព្រែកព្នៅត្រូវរៀបចំផែនការសម្រាប់អនុវត្តប្លង់គោលប្រើប្រាស់ដីខាងលើនេះឱ្យមានប្រសិទ្ធភាព និងត្រូវរាយការណ៍អំពីវឌ្ឍនភាពជូនគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**ប្រការ៣.-**

គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខណ្ឌព្រែកព្នៅ ត្រូវធ្វើបច្ចុប្បន្នភាពប្លង់គោលប្រើប្រាស់ដីខណ្ឌព្រែកព្នៅក្នុងរយៈពេល៥(ប្រាំ)ឆ្នាំម្តង តាមករណីចាំបាច់នៃការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម។ ការកែសម្រួលប្លង់គោលប្រើប្រាស់ដីខណ្ឌព្រែកព្នៅមុនពេលកំណត់ អាចប្រព្រឹត្តទៅបានក្នុងករណីដែលមានតម្រូវការចាំបាច់សម្រាប់បម្រើផលប្រយោជន៍សាធារណៈឬផលប្រយោជន៍ជាតិ។

ការកែសម្រួលប្លង់គោលប្រើប្រាស់ដីខណ្ឌព្រែកព្នៅ ត្រូវអនុវត្តតាមនីតិវិធីដែលមានចែងនៅក្នុងសេចក្តីសម្រេចលេខ០៤១ សសរ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីនីតិវិធីលម្អិតនៃការរៀបចំប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ។

**ប្រការ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍។

**ប្រការ៥.-**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានរៀបចំដែនដីនិងនគរូបនីយកម្ម អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញនិងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មរាជធានីភ្នំពេញ និងអភិបាលនៃគណៈអភិបាលខណ្ឌព្រែកព្នៅនិងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខណ្ឌព្រែកព្នៅ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ១២រោច ខែ មិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០២១

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**
**និងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ**

**ជា សុផារ៉ា**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងស្ថាប័នពាក់ព័ន្ធ
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ដូចប្រការ៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃសេចក្តីសម្រេចលេខ០៧៣ អនក្រ.បក ចុះថ្ងៃសុក្រ ១២កើត ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ត្រូវនឹងថ្ងៃទី...៣១... ខែ...ធ្នូ... ឆ្នាំ២០២១

ស្តីពីការដាក់ឱ្យប្រើប្រាស់ប្លង់គោលប្រើប្រាស់ដីខណ្ឌព្រែកព្នៅ

# ប្លង់គោលប្រើប្រាស់ដីខណ្ឌព្រែកព្នៅ

## ចក្ខុវិស័យឆ្នាំ២០៣៥

# មាតិកា

ទំព័រ


**១-សេចក្តីផ្តើម** ........ ១

**២-ក្របខណ្ឌសង្គម-សេដ្ឋកិច្ច និងចក្ខុវិស័យ** ........ ២

២.១- ក្របខណ្ឌសង្គម- សេដ្ឋកិច្ច........ ២

២.២- ចក្ខុវិស័យ........ ៣

**៣-គោលបំណងនិងគោលដៅ** ........ ៣

៣.១- គោលបំណង........ ៣

៣.២- គោលដៅ........ ៣

**៤-យុទ្ធសាស្ត្រអភិវឌ្ឍនិងអភិរក្សប្រកបដោយភាពឆ្លាត ចីរភាព និងបរិយាបន្ន** ........ ៤

៤.១- យុទ្ធសាស្ត្រអភិវឌ្ឍនគរូបនីយកម្ម ........ ៤

៤.១.១- តំបន់នគរូបនីយកម្មបច្ចុប្បន្ន........ ៤

៤.១.២- ទិសដៅនគរូបនីយកម្ម ........ ៥

៤.១.៣- ការអភិវឌ្ឍនគរូបនីយកម្មឆ្លាត មានចីរភាព និងប្រកបដោយបរិយាបន្ន........ ៥

៤.២- យុទ្ធសាស្ត្រគ្រប់គ្រងនិងប្រើប្រាស់ដី........ ៧

៤.២.១- ប្រភេទដីអាចសាងសង់បាន........ ៨

៤.២.២- ប្រភេទដីកម្រិតការសាងសង់ ........ ៩

៤.៣- យុទ្ធសាស្ត្រអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ........ ១០

៤.៣.១- ផ្លូវថ្នល់........ ១០

៤.៣.២- ផ្លូវទឹក ........ ១១

៤.៣.៣- ផ្លូវអាកាស........ ១១

៤.៣.៤- ការគ្រប់គ្រងធនធានទឹកនិងការផ្គត់ផ្គង់ទឹកស្អាត ........ ១១

៤.៣.៥- ការផ្គត់ផ្គង់ថាមពលអគ្គិសនី ទូរគមនាគមន៍ បច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍........ ១២

៤.៣.៦- ហេដ្ឋារចនាសម្ព័ន្ធសង្គម........ ១២

៤.៤- យុទ្ធសាស្ត្រអភិវឌ្ឍសេដ្ឋកិច្ច........ ១២

៤.៤.១- ការអភិវឌ្ឍវិស័យទេសចរណ៍........ ១២

៤.៤.២- ការអភិវឌ្ឍវិស័យពាណិជ្ជកម្មនិងសេវាកម្ម........ ១៤

៤.៤.៣- ការអភិវឌ្ឍវិស័យឧស្សាហកម្ម........ ១៥

៤.៤.៤- ការគាំទ្រការអភិវឌ្ឍវិស័យកសិកម្មនិងផ្សព្វផ្សាយផលិតផលក្នុងស្រុក............................ ១៥
៤.៥- យុទ្ធសាស្ត្រអភិវឌ្ឍសង្គមកិច្ច........................................................................ ១៦
៤.៦- យុទ្ធសាស្ត្រការពារបរិស្ថាននិងគ្រប់គ្រងសំណល់.................................................. ១៦
៤.៦.១- ការបែងចែកតំបន់ប្រើប្រាស់ដីសម្រាប់ការការពារបរិស្ថាន...................................... ១៦
៤.៦.២- វិធានការចាំបាច់ក្នុងការការពារតំបន់សំខាន់ៗ.................................................. ១៦
៤.៦.៣- ការគ្រប់គ្រងសំណល់រឹង................................................................................ ១៧
៤.៦.៤- ការគ្រប់គ្រងសំណល់រាវនិងទឹកកខ្វក់................................................................ ១៧
៤.៧- យុទ្ធសាស្ត្របង្ការទប់ស្កាត់គ្រោះមហន្តរាយ....................................................... ១៧
៤.៨- យុទ្ធសាស្ត្រពង្រឹងអភិបាលកិច្ចល្អ គ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុនៅមូលដ្ឋាន.................. ១៨
**៥- ផែនការសកម្មភាព**.......................................................................................... ១៨
៥.១- ការរៀបចំបទប្បញ្ញត្តិនគរូបនីយកម្ម.................................................................. ១៨
៥.២- ការផ្សព្វផ្សាយ............................................................................................. ១៩
៥.៣- ការអនុវត្តគម្រោងតាមវិស័យ........................................................................... ១៩
៥.៣.១- ការអភិវឌ្ឍខណ្ឌ........................................................................................ ១៩
៥.៣.២- ការអភិវឌ្ឍការដឹកជញ្ជូន............................................................................. ១៩
៥.៣.៣- ការអភិវឌ្ឍទេសចរណ៍................................................................................ ១៩
៥.៣.៤- ការអភិវឌ្ឍពាណិជ្ជកម្មនិងសេវាកម្ម.............................................................. ២០
៥.៣.៥- ការអភិវឌ្ឍឧស្សាហកម្ម.............................................................................. ២០
៥.៣.៦- ការគ្រប់គ្រងបរិស្ថាន.................................................................................. ២០
៥.៣.៧- ការគ្រប់គ្រងធនធានទឹកនិងការផ្គត់ផ្គង់ទឹកស្អាត............................................... ២០
៥.៣.៨- ការផ្គត់ផ្គង់ថាមពលអគ្គិសនី ទូរគមនាគមន៍ បច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍................ ២០
៥.៣.៩- ការគ្រប់គ្រងសំណល់រឹង................................................................................ ២១
៥.៣.១០- ការគ្រប់គ្រងសំណល់រាវនិងទឹកកខ្វក់............................................................. ២១
៥.៤- ការអនុវត្តគម្រោងរយៈពេលខ្លី មធ្យម និងវែង....................................................... ២១
៥.៤.១- ការអនុវត្តគម្រោងរយៈពេលខ្លី........................................................................ ២១
៥.៤.២- ការអនុវត្តគម្រោងរយៈពេលមធ្យម................................................................... ២១
៥.៤.៣- ការអនុវត្តគម្រោងរយៈពេលវែង...................................................................... ២១
៥.៥- គម្រោងអាទិភាព........................................................................................... ២២
**៦- ធនធានហិរញ្ញវត្ថុ**........................................................................................... ២២

**៧-ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃ** ........ ២២

៧.១- យន្តការ ........ ២២

៧.២- គោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ........ ២២

៧.៣- ភារកិច្ច នីតិវិធី និងគោលការណ៍ ........ ២៣

**៨-សេចក្តីសន្និដ្ឋាន** ........ ២៣

**អនុសាសន៍** ........ ២៥

**សទ្ទានុក្រម** ........ ២៦

**ឯកសារឧបសម្ព័ន្ធ** ........ ៣៧

## ១-សេចក្តីផ្តើម

ស្ថិតក្នុងបរិការណ៍សុខសន្តិភាព ឯកភាពទឹកដី ឯកភាពជាតិ ស្ថិរភាពនយោបាយរឹងមាំ ការប្រកាន់ខ្ជាប់ឥតងាករេនូវគោលការណ៍លទ្ធិប្រជាធិបតេយ្យ នីតិរដ្ឋ និងការគោរពសិទ្ធិមនុស្សនៅក្រោមដំបូលរដ្ឋធម្មនុញ្ញនិងច្បាប់ រាជរដ្ឋាភិបាលបានធានាជាប់ជាប្រចាំនូវប្រក្រតីភាពនៃដំណើរទៅមុខនៃការអភិវឌ្ឍសង្គមសេដ្ឋកិច្ចកម្ពុជា។ រាជរដ្ឋាភិបាលបានបន្តជំរុញការកែទម្រង់ស្ថាប័នឱ្យមានសន្ទុះថ្មី មុតស្រួច និងកាន់តែស៊ីជម្រៅលើគ្រប់ផ្នែកនិងគ្រប់វិស័យក្នុងគោលដៅបង្កើននិងកែលម្អការផ្តល់សេវាសាធារណៈប្រកបដោយគុណភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព។

ផ្អែកតាមយុទ្ធសាស្ត្រចតុកោណនិងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ រាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានដាក់ចេញនូវគោលនយោបាយជាតិស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា សំដៅធានាថាដែនដីនៅទូទាំងព្រះរាជាណាចក្រកម្ពុជាត្រូវបានគ្រប់គ្រង ប្រើប្រាស់ ការពារ និងអភិវឌ្ឍតាមរយៈការធ្វើសមាហរណកម្មនូវផែនការយុទ្ធសាស្ត្ររៀបចំដែនដីនិងការធ្វើឱ្យរលូននូវវិធាននិងឧបករណ៍ចាំបាច់នានាតាមវិស័យប្រកបដោយភាពសុខដុមរមនានៅតាមតំបន់ភូមិសាស្ត្រនីមួយៗ។

ខណ្ឌព្រែកព្នៅជាខណ្ឌមួយក្នុងចំណោមខណ្ឌទាំង១៤ របស់រាជធានីភ្នំពេញ និងត្រូវបានកំណត់ជាតំបន់កំពុងអភិវឌ្ឍក្នុងរាជធានីភ្នំពេញក្នុងចំណោមតំបន់ជាយក្រុងផ្សេងទៀតគឺខណ្ឌច្បារអំពៅ ខណ្ឌជ្រោយចង្វារ ខណ្ឌពោធិ៍សែនជ័យ ខណ្ឌសែនសុខ។ល។ និងជាមជ្ឈមណ្ឌលវប្បធម៌ នយោបាយ សន្តិសុខ សេដ្ឋកិច្ច សង្គមដែលមានការអភិវឌ្ឍប្រកបដោយសក្តានុពលប្រកួតប្រជែងនិងនិរន្តរភាពលើគ្រប់វិស័យ។

បច្ចុប្បន្នខណ្ឌព្រែកព្នៅមានព្រំប្រទល់ផ្នែកខាងជើងជាប់នឹងឃុំព្រែកតាទែន ស្រុកពញាឮ ខេត្តកណ្តាល ផ្នែកខាងត្បូងជាប់នឹងខណ្ឌឫស្សីកែវ ខណ្ឌសែនសុខ និងខណ្ឌពោធិ៍សែនជ័យ ផ្នែកខាងលិចជាប់នឹងឃុំទួលព្រិច ស្រុកអង្គស្នួល ខេត្តកណ្តាល និងផ្នែកខាងកើតជាប់នឹងទន្លេសាប។ ខណ្ឌព្រែកព្នៅមានផ្ទៃដីប្រមាណ១១ ៥៦០,៩០ ហិកតា និងចែកជា៥សង្កាត់និង៥៩ភូមិ ដូចតទៅៈ

- សង្កាត់គោករកាស្ថិតនៅតាមផ្លូវទំនប់កប់ស្រូវមានលេខកូដ 121201 និងមានភូមិចំនួន១៨
- សង្កាត់ព្រែកព្នៅស្ថិតនៅតាមដងផ្លូវជាតិលេខ៥ និងផ្លូវទំនប់កប់ស្រូវមានលេខកូដ 121202 និងមានភូមិចំនួន៥
- សង្កាត់ពញាពន់ស្ថិតនៅតាមដងផ្លូវលេខ១៥១មានលេខកូដ 121203 និងមានភូមិចំនួន៨
- សង្កាត់ពន្សាំងដែលមានផ្លូវលេខ៤២ជាផ្លូវយុទ្ធសាស្ត្រមានលេខកូដ 121204 និងមានភូមិចំនួន២៤
- សង្កាត់សំរោងស្ថិតនៅតាមផ្លូវជាតិលេខ៥ និងផ្លូវលេខ១៥១ ឆ្ពោះទៅភ្នំប្រសិទ្ធិមានលេខកូដ 121205 និងមានភូមិចំនួន៤។

ក្នុងគោលដៅធានាការគ្រប់គ្រងនិងការអភិវឌ្ឍខណ្ឌព្រែកព្នៅប្រកបដោយចីរភាព គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មរាជធានីភ្នំពេញនិងគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខណ្ឌព្រែកព្នៅក្រោមការគាំទ្របច្ចេកទេសដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់បានរៀបចំនូវប្លង់គោលប្រើប្រាស់ដីខណ្ឌព្រែកព្នៅចក្ខុវិស័យឆ្នាំ២០៣៥ដើម្បីជាមូលដ្ឋានក្នុងការគ្រប់គ្រងនិងតម្រង់ទិសការអភិវឌ្ឍដែនដីខណ្ឌព្រែកព្នៅទាំងមូលឱ្យស្របតាមចក្ខុវិស័យគោលនយោបាយជាតិស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា ប្លង់គោលប្រើប្រាស់ដីរាជធានីភ្នំពេញ ឆ្នាំ២០៣៥ និងគោលនយោបាយតាមវិស័យសំខាន់ៗជាច្រើនទៀត។

ប្លង់គោលប្រើប្រាស់ដីខណ្ឌព្រែកព្នៅត្រូវបានកសាងដោយមានការសិក្សាច្បាស់លាស់លើកត្តាភូមិសាស្ត្រ ប្រជាសាស្ត្រ សង្គមកិច្ច សេដ្ឋកិច្ច បរិស្ថាន ទេសចរណ៍ និងវប្បធម៌ ព្រមទាំងគោលនយោបាយច្បាប់និងលិខិតបទដ្ឋានគតិយុត្តសំខាន់ៗមួយចំនួនពាក់ព័ន្ធនឹងការរៀបចំដែនដីនិងនគរូបនីយកម្ម មានជាអាទិ៍ ច្បាប់ភូមិបាល ច្បាប់ស្តីពីសំណង់ ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ ច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ ច្បាប់ស្តីពីទេសចរណ៍ ច្បាប់ស្តីពីជលផល ច្បាប់ស្តីពីផ្លូវថ្នល់ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ អនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អនុក្រឹត្យស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន អនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង់ អនុក្រឹត្យស្តីពីការដាក់ឱ្យអនុវត្តប្លង់គោលប្រើប្រាស់ដីរាជធានីភ្នំពេញ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

ចក្ខុវិស័យនៃប្លង់គោលប្រើប្រាស់ដីខណ្ឌព្រែកព្នៅមានលក្ខណៈទូលំទូលាយ គ្របដណ្តប់ទាំងទិដ្ឋភាពគតិយុត្ត និងបច្ចេកទេស សម្រាប់ធ្វើការសម្របសម្រួលរវាងវិស័យនានាដែលជាកម្លាំងចលករសេដ្ឋកិច្ច សំដៅធ្វើការ**តម្រង់ទិសការអភិវឌ្ឍនគរូបនីយកម្ម**ប្រកបដោយចីរភាពនិងបរិយាបន្ន ឆ្លើយតបទៅនឹងកំណើនប្រជាសាស្ត្រ តម្រូវការប្រើប្រាស់ដី ការអភិវឌ្ឍលំនៅឋាន និងការអភិវឌ្ឍគ្រប់វិស័យក្នុងពេលបច្ចុប្បន្ននិងទៅអនាគត ដោយធានាបាននូវការការពារធនធានដី ធនធានទឹក ទឹកក្រោមដី ប្រព័ន្ធអេកូឡូស៊ី បរិស្ថាន និងធនធានធម្មជាតិដែលអាចធ្វើការអភិវឌ្ឍឱ្យមានសណ្តាប់ធ្នាប់ របៀបរៀបរយ សោភណភាព ចីរភាព និងចូលរួមបង្ការទប់ស្កាត់ការប្រែប្រួលអាកាសធាតុដូចជាការបំភាយឧស្ម័នផ្ទះកញ្ចក់ ការកើនឡើងនៃកម្តៅ ទឹកជំនន់ និងខ្យល់ព្យុះក្នុងរាជធានីជាដើម។

## ២-ក្របខណ្ឌសង្គម-សេដ្ឋកិច្ច និងចក្ខុវិស័យ

### ២.១-ក្របខណ្ឌសង្គម-សេដ្ឋកិច្ច

ប្លង់គោលប្រើប្រាស់ដីខណ្ឌព្រែកព្នៅត្រូវបានរៀបចំឡើងដោយបានសិក្សា ប្រមូលនិងវិភាគទិន្នន័យប្រជាសាស្ត្រ ទិន្នន័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ទិន្នន័យសង្គម ទិន្នន័យសេដ្ឋកិច្ច ទិន្នន័យបរិស្ថាន និងការស្រង់មតិសមស្របតាមគោលនយោបាយជាតិស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា គោលនយោបាយដីធ្លី "សៀវភៅសដីធ្លី" ច្បាប់ស្តីពីសំណង់ និងអនុក្រឹត្យស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន។

ដើម្បីកំណត់ចក្ខុវិស័យប្លង់គោលប្រើប្រាស់ដីខណ្ឌព្រែកព្នៅដល់ឆ្នាំ២០៣៥ ក្របខណ្ឌសង្គម-សេដ្ឋកិច្ចត្រូវបានសិក្សាវិភាគតាមបែបវិទ្យាសាស្ត្រដោយផ្អែកតាមលទ្ធផលនៃជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ២០០៨ និងជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩។ ខណ្ឌព្រែកព្នៅត្រូវបានបង្កើតឡើងនៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៣ មានផ្ទៃដីប្រមាណ១១ ៥៦០,៩០ហិកតា និងចែកចេញចំនួន៥សង្កាត់ ដែលកាត់ចេញពីខណ្ឌសែនសុខនិងខណ្ឌពោធិ៍សែនជ័យ។ ប្រជាជននៅឆ្នាំ២០០៨ មានចំនួន៤៧ ៣១៣នាក់ និងនៅឆ្នាំ២០១៩ មានចំនួន១៩១ ៤៣៧នាក់ ហើយតាមការព្យាករណ៍នៅឆ្នាំ២០៣៥ ប្រជាជននឹងថយចុះមកត្រឹមចំនួន១៤៨ ១០៤នាក់ផ្អែកតាមការគណនាអត្រាកំណើនប្រចាំឆ្នាំ។ ជាមួយគ្នានេះការបែងចែកកម្លាំងពលកម្មតាមវិស័យសេដ្ឋកិច្ចសម្រាប់ខណ្ឌព្រែកព្នៅនៅឆ្នាំ២០០៨ ប្រជាជនដែលធ្វើការក្នុងវិស័យកសិកម្មមានចំនួន១១ ៨២៦នាក់ស្មើនឹង៤៩,៤% វិស័យឧស្សាហកម្មមានចំនួន៥ ៤៤០នាក់ស្មើនឹង២២,៧% និងវិស័យសេវាកម្មមានចំនួន៦ ៦៨២នាក់ស្មើនឹង២៧,៩% ហើយរំពឹងថានៅឆ្នាំ២០៣៥ ប្រជាជនដែលធ្វើការក្នុងវិស័យកសិកម្មនឹងថយចុះមកត្រឹមចំនួន១០ ៩៦០នាក់ស្មើនឹង២០,០% វិស័យឧស្សាហកម្មនឹងកើនឡើងដល់ចំនួន២៥ ៧៥៥នាក់ស្មើនឹង៤៧,០% និងវិស័យសេវាកម្មនឹងកើនឡើងដល់ចំនួន១៨ ០៨៣នាក់ស្មើនឹង៣៣,០%។

**២.២-ចក្ខុវិស័យ**

ចក្ខុវិស័យដល់ឆ្នាំ២០៣៥ នៃប្លង់គោលប្រើប្រាស់ដីខណ្ឌព្រែកព្នៅគឺសំដៅរៀបចំនិងអភិវឌ្ឍខណ្ឌព្រែកព្នៅជា "**មជ្ឈមណ្ឌលទីក្រុងមាត់ទឹកនៃរាជធានីភ្នំពេញតាមដងទន្លេសាប បឹងធំៗពីរគឺបឹងតាមោកនិងបឹងសំរោង និងជាច្រកចេញចូលខាងជើងនៃរាជធានីភ្នំពេញដែលជាគោលដៅអភិវឌ្ឍប្រកបដោយសក្តានុពលប្រកួតប្រជែងខ្ពស់ និងទាក់ទាញបំផុតសម្រាប់លំនៅឋាន ទេសចរណ៍វប្បធម៌-ធម្មជាតិ ពាណិជ្ជកម្ម ឧស្សាហកម្ម សេដ្ឋកិច្ច កសិកម្ម សិប្បកម្ម និងសេវាកម្មប្រកបដោយគុណភាពបរិស្ថានរស់នៅ និងប្រព័ន្ធគមនាគមន៍ល្អប្រសើរ**" តាមរយៈការជំរុញ៖ ១)លើកកម្ពស់ការគ្រប់គ្រង ការអភិវឌ្ឍ និងការកែលម្អនគរូបនីយកម្មនិងការគ្រប់គ្រងការប្រើប្រាស់ដីឱ្យបានត្រឹមត្រូវ ចំទិសដៅ មានគុណភាពបរិស្ថានរស់នៅល្អនិងសកម្មភាពទីក្រុងរស់រវើកប្រកបដោយភាពឆ្លាត ចីរភាព និងបរិយាបន្ន ២)អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ បរិក្ខារនិងសេវាទីក្រុងសម្បូរបែបប្រកបដោយគុណភាព សណ្តាប់ធ្នាប់សាធារណៈ និងធ្វើសមាហរណកម្មទៅក្នុងតំបន់ដើម្បីធានាគុណភាពរស់នៅល្អប្រសើរ ៣)អភិវឌ្ឍទេសចរណ៍វប្បធម៌-ធម្មជាតិតាមរយៈការថែរក្សាអត្តសញ្ញាណវប្បធម៌ជាតិ ការពារធនធានធម្មជាតិ និងទេសភាពធម្មជាតិ បរិស្ថានទន្លេសាប បឹងតាមោក បឹងសំរោង និងកសិកម្មបៃតង ៤)អភិវឌ្ឍពាណិជ្ជកម្ម ឧស្សាហកម្ម ធុរកិច្ច និងសេវាកម្មសម្បូរបែប និង៥)លើកកម្ពស់ការគ្រប់គ្រង អភិបាលកិច្ចល្អ ការអភិវឌ្ឍសង្គម និងការផ្តល់សេវាសាធារណៈល្អ កិច្ចការពារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈល្អ។

ចក្ខុវិស័យដល់ឆ្នាំ២០៣៥ នៃប្លង់គោលប្រើប្រាស់ដីខណ្ឌព្រែកព្នៅ នឹងចូលរួមសម្រេចចក្ខុវិស័យប្លង់គោលប្រើប្រាស់ដីរាជធានីភ្នំពេញ ឆ្នាំ២០៣៥ សំដៅធ្វើឱ្យរាជធានីភ្នំពេញដែលជា "**បេះដូងរបស់ព្រះរាជាណាចក្រកម្ពុជាដែលស្ថិតនៅលើចំណុចពិសេសនៃប្រសព្វទន្លេបួនមុខហៅថាទន្លេបួនមុខដែលជាអត្តសញ្ញាណតែមួយគ្មានពីរ ជាមជ្ឈមណ្ឌលនយោបាយ សេដ្ឋកិច្ច ពាណិជ្ជកម្ម និងវប្បធម៌ប្រកបដោយសក្តានុពលប្រកួតប្រជែងជាមួយការអភិវឌ្ឍមួយប្រកបដោយវឌ្ឍនភាព សមធម៌ និងចីរភាព**"។

**៣-គោលបំណងនិងគោលដៅ**

ដើម្បីសម្រេចចក្ខុវិស័យខាងលើ ប្លង់គោលប្រើប្រាស់ដីខណ្ឌព្រែកព្នៅមានគោលបំណងនិងគោលដៅដូចខាងក្រោម៖

**៣.១-គោលបំណង**

ប្លង់គោលប្រើប្រាស់ដីខណ្ឌព្រែកព្នៅមានគោលបំណងធានាសមាហរណកម្មនៃការអភិវឌ្ឍនិងការអភិរក្សនគរូបនីយកម្ម ការប្រើប្រាស់ដីនិងសក្តានុពលដែលមានស្រាប់ឱ្យបានត្រឹមត្រូវនិងចំទិសដៅ ប្រកបដោយភាពឆ្លាត គុណភាព តុល្យភាព ចីរភាព និងបរិយាបន្ន តាមរយៈការគ្រប់គ្រងនិងអភិបាលកិច្ចប្រកបដោយប្រសិទ្ធភាពខ្ពស់។

**៣.២-គោលដៅ**

ប្លង់គោលប្រើប្រាស់ដីខណ្ឌព្រែកព្នៅមានគោលដៅដូចខាងក្រោម៖

- គ្រប់គ្រងការប្រើប្រាស់ដីនិងការប្រើប្រាស់សក្តានុពលធម្មជាតិនិងនគរូបនីយកម្មស្របទៅនឹងតំបន់លំនៅឋាន សេដ្ឋកិច្ច ពាណិជ្ជកម្ម វប្បធម៌ រដ្ឋបាល និងសេវាសាធារណៈ ប្រកបដោយប្រសិទ្ធភាព ចីរភាព តុល្យភាព និងស្របតាមលក្ខណៈពិសេសនៃតំបន់នីមួយៗ

- ជំរុញកំណើនសេដ្ឋកិច្ចនិងអភិវឌ្ឍធុរកិច្ចទាក់ទាញគាំទ្រដល់ការវិនិយោគសាធារណៈនិងឯកជន ដើម្បីសមធមិសង្គមនិងផ្តល់ការងារ
- ធ្វើសមាហរណកម្មផែនការរូបវន្ត សង្គម សេដ្ឋកិច្ច វប្បធម៌ បរិស្ថាន និងផែនការតាមវិស័យដើម្បី ធានាភាពសុខដុមរមនាសង្គមនិងការអភិវឌ្ឍប្រកបដោយចីរភាព
- លើកកម្ពស់វិស័យទេសចរណ៍និងសេវាកម្មដោយអភិរក្សតំបន់ទេសចរណ៍ដែលមានស្រាប់ស្របតាម សក្តានុពលធម្មជាតិនិងអភិវឌ្ឍតាមលទ្ធភាពជាក់ស្តែងដោយលៃយ៉ាងណាឱ្យការអភិវឌ្ឍមិនប៉ះពាល់ ដល់ការអភិរក្សហើយផ្តល់ប្រយោជន៍សម្រាប់មនុស្សទូទៅ
- លើកកម្ពស់និងអភិវឌ្ឍវិស័យកសិកម្មបែបទំនើប បង្កើនទីផ្សារផលិតផលកសិកម្ម និងបង្កើតទីតាំង បៃងចៃកផលនេសាទឱ្យបានល្អប្រសើរ
- លើកកម្ពស់បេតិកភណ្ឌ ធនធានធម្មជាតិ កិច្ចការពារបរិស្ថាន ការអភិវឌ្ឍបៃតង និងបង្ការទប់ស្កាត់ គ្រោះមហន្តរាយប្រកបដោយប្រសិទ្ធភាព
- លើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃការកែលម្អ ការអភិវឌ្ឍ និងការការពារហេដ្ឋារចនាសម្ព័ន្ធ
- ដោះស្រាយនិងឆ្លើយតបចំពោះសេចក្តីត្រូវការរបស់ប្រជាជន
- ដើម្បីងាយស្រួលក្នុងការគ្រប់គ្រងរដ្ឋបាលក៏ដូចជាការគ្រប់គ្រងដែនដី គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មខណ្ឌព្រែកព្នៅបានកំណត់យកផ្លូវនិងប្រឡាយជាខ្សែបន្ទាត់ព្រំប្រទល់រវាងខណ្ឌ និងខណ្ឌ និងរវាងខណ្ឌនិងស្រុក។

## ៤-យុទ្ធសាស្ត្រអភិវឌ្ឍនិងអភិរក្សប្រកបដោយភាពឆ្លាត ចីរភាព និងបរិយាបន្ន

ដើម្បីសម្រេចបានចក្ខុវិស័យ គោលបំណង និងគោលដៅខាងលើ ប្លង់គោលប្រើប្រាស់ដីខណ្ឌព្រែកព្នៅ បានកំណត់យុទ្ធសាស្ត្រគ្រប់គ្រង អភិបាលកិច្ច និងការធ្វើសមាហរណកម្មការអភិវឌ្ឍនិងការអភិរក្សប្រកបដោយ ប្រសិទ្ធភាព ចីរភាព តុល្យភាព និងសមធមិដូចខាងក្រោម៖

### ៤.១-យុទ្ធសាស្ត្រអភិវឌ្ឍនគរូបនីយកម្ម

### ៤.១.១-តំបន់នគរូបនីយកម្មបច្ចុប្បន្ន

ដើម្បីជំរុញការគ្រប់គ្រងនិងការកែលម្អតំបន់នគរូបនីយកម្មបច្ចុប្បន្នរបស់ខណ្ឌ សម្រាប់ការរស់នៅប្រកប ដោយសុខុមាលភាព ត្រូវអនុវត្តដូចខាងក្រោម៖

- បន្តជំរុញដាក់ឈ្មោះឬលេខផ្លូវនិងលេខផ្ទះ ដើម្បីងាយស្រួលក្នុងការគ្រប់គ្រងរដ្ឋបាលនិងប្រៃសណីយ៍
- កែលម្អនិងអភិវឌ្ឍបណ្តាញហេដ្ឋារចនាសម្ព័ន្ធរួមមានបណ្តាញផ្លូវ បណ្តាញទឹកស្អាត បណ្តាញអគ្គិសនី បណ្តាញប្រឡាយ និងការប្រមូលសំណល់រឹងនិងរាវឱ្យមានលក្ខណៈសមស្របនិងមានគុណភាព ដើម្បីលើកកម្ពស់គុណភាពរស់នៅនិងសោភណភាពក្នុងខណ្ឌនិងរាជធានី
- កែលម្អនិងអភិវឌ្ឍផ្លូវសំខាន់ៗដូចជាមហាវិថី វិថី អនុវិថី ផ្លូវថ្មើរជើង ផ្លូវសម្រាប់ជនមានពិការភាព គន្លងផ្លូវទោចក្រយាន ចិញ្ចើមផ្លូវ ភ្លើងបំភ្លឺឆ្លាត ផ្លាកសញ្ញាចរាចរណ៍ និងផ្លាកផ្សព្វផ្សាយពាណិជ្ជកម្ម នៅក្នុងខណ្ឌស្របទៅតាមតំបន់ប្រើប្រាស់ដី សោភណភាពរស់រវើក សណ្តាប់ធ្នាប់ល្អ និងបរិស្ថាន រស់នៅប្រកបដោយសុខភាពល្អសម្រាប់មនុស្សទាំងអស់គ្នា

- រៀបចំសួនសាធារណៈដោយកំណត់ប្រភេទនិងដាំដើមឈើ សួនច្បារតាមបណ្ដោយផ្លូវ សួនកុមារ ទីលានកីឡា កន្លែងកម្សាន្ត និងការអភិវឌ្ឍផ្ទៃបៃតងស្ថិតនៅក្នុងខណ្ឌ
- គ្រប់គ្រងសំណង់ រៀបចំ និងកំណត់ស្ថាបត្យកម្មត្រូវមានរចនាបថខ្មែរ អត្តសញ្ញាណវប្បធម៌ខ្មែរ និងលក្ខណៈធម្មជាតិនិងបរិស្ថាន សោភណភាពនិងពណ៌សមស្រប និងរបងដីឡូត៍ឱ្យមានសោភណភាពល្អស្របតាមទីតាំងភូមិសាស្ត្រ មជ្ឈមណ្ឌលវប្បធម៌ សន្តិសុខ សេដ្ឋកិច្ចនិងសង្គម
- រៀបចំផែនការប្រើប្រាស់ដីដោយកំណត់បទប្បញ្ញត្តិនៃការប្រើប្រាស់ដី ការអភិវឌ្ឍ ការសាងសង់ និងប្លង់លម្អិតនគរូបនីយកម្មតាមសង្កាត់នីមួយៗ
- គ្រប់គ្រង អភិវឌ្ឍ និងអភិរក្សបឹង ស្ទឹង ប្រឡាយ និងទីទួលបុរាណសម្រាប់សក្ការៈបូជា
- រៀបចំនិងកែលម្អតំបន់អប់រំនិងសិក្សាដូចជាសាកលវិទ្យាល័យ វិទ្យាស្ថាន វិទ្យាល័យ អនុវិទ្យាល័យ និងសាលាបឋមសិក្សា។

### ៤.១.២- ទិសដៅនគរូបនីយកម្ម

អភិវឌ្ឍនគរូបនីយកម្មជាតំបន់កំពុងអភិវឌ្ឍក្នុងរាជធានីភ្នំពេញសម្រាប់រដ្ឋបាល វប្បធម៌ សេដ្ឋកិច្ច ពាណិជ្ជកម្ម និងទេសចរណ៍ប្រកបដោយគុណភាពបរិស្ថានរស់នៅល្អប្រសើរ ភាពសុខដុមរមនា ភាពឆ្លាត ចីរភាព និងបរិយាបន្ន ដោយៈ

- លើកកម្ពស់ការគ្រប់គ្រង ការអភិវឌ្ឍ និងការកែលម្អនគរូបនីយកម្មនិងការគ្រប់គ្រងការប្រើប្រាស់ដីប្រកបដោយសោភណភាព ប្រសិទ្ធភាព និងតុល្យភាព
- អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ បរិក្ខារ និងសេវាទីក្រុងសម្បូរបែបប្រកបដោយគុណភាព សណ្ដាប់ធ្នាប់សាធារណៈនិងធ្វើសមាហរណកម្មទៅក្នុងតំបន់ដើម្បីធានាគុណភាពនៃការរស់នៅល្អប្រសើរ
- កំណត់និន្នាការនៃការអភិវឌ្ឍខណ្ឌនិងនគរូបនីយកម្មមានលទ្ធភាពពង្រីកតាមវិធីសាស្ត្រនៃការអភិវឌ្ឍបែបលាតសន្ធឹងទៅទិសពាយ័ព្យ និងការអភិវឌ្ឍសំណង់ខ្ពស់ៗ
- គ្រប់គ្រងការអភិវឌ្ឍនិងការធ្វើសមាហរណកម្មការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធប្រកបដោយប្រសិទ្ធភាពនិងចីរភាពស្របតាមបទដ្ឋានបច្ចេកទេសនគរូបនីយកម្មនិងការអភិវឌ្ឍប្រវត្តិជាពិសេសបណ្ដាញផ្លូវ បណ្ដាញអគ្គិសនី បណ្ដាញទឹកស្អាត បណ្ដាញលូប្រឡាយ អាងស្ដុកទឹក និងអាងប្រព្រឹត្តិកម្មទឹកកខ្វក់
- ពង្រឹងសមត្ថភាពគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខណ្ឌព្រែកព្នៅដែលមានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលនៃរដ្ឋបាលខណ្ឌព្រែកព្នៅជាសេនាធិការ នៅក្នុងការគ្រប់គ្រងនិងអនុវត្តការងាររៀបចំដែនដីនិងនគរូបនីយកម្ម
- បន្តរៀបចំផែនការប្រើប្រាស់ដីនិងប្លង់លម្អិតនគរូបនីយកម្មដើម្បីធានាការគ្រប់គ្រង ការអភិវឌ្ឍ និងការអភិរក្សប្រកបដោយប្រសិទ្ធភាពនិងចីរភាព។

### ៤.១.៣- ការអភិវឌ្ឍនគរូបនីយកម្មឆ្លាត មានចីរភាព និងប្រកបដោយបរិយាបន្ន

ដើម្បីលើកកម្ពស់ដល់គុណភាពរស់នៅប្រកបដោយភាពងាយស្រួលក្នុងការទំនាក់ទំនងនិងសន្សំសំចៃ ឆ្លើយតបទៅនឹងតម្រូវការបច្ចុប្បន្ននិងអនាគត ប្លង់គោលប្រើប្រាស់ដីខណ្ឌព្រែកព្នៅចក្ខុវិស័យឆ្នាំ២០៣៥ បានដាក់ចេញនូវយុទ្ធសាស្ត្រអភិវឌ្ឍខណ្ឌឆ្លាតតាមរយៈការគិតគូរនិងបំពាក់នូវបរិក្ខារនិងសេវាកម្មសម្រាប់ខណ្ឌឆ្លាត ដូចខាងក្រោមៈ

## ក-វិស័យទូរគមនាគមន៍

ក.១- សេវាអ៊ីនធឺណិតសាធារណៈ

- ផ្តល់ការប្រើប្រាស់សេវាអ៊ីនធឺណិតសាធារណៈដល់សាធារណជនទូទៅនិងនៅកន្លែងសាធារណៈ ដូចជាស្ថាប័នរដ្ឋ សួនកម្សាន្ត តំបន់ទេសចរណ៍ តំបន់វប្បធម៌ និងមហាវិថីធំៗដែលផ្តល់ដោយស្ថាប័នផ្គត់ផ្គង់សេវាទូរគមនាគមន៍ដោយមានការគាំទ្រពីរាជរដ្ឋាភិបាល
- រៀបចំនិងផ្សព្វផ្សាយផែនទីបង្ហាញទីតាំងដែលមានសេវាអ៊ីនធឺណិតសាធារណៈ។

ក.២- មជ្ឈមណ្ឌលទិន្នន័យសាធារណៈ

- សិក្សានូវលទ្ធភាពក្នុងការកសាងមជ្ឈមណ្ឌលទិន្នន័យសម្រាប់ជិនួយគម្រោងខណ្ឌឆ្លាតដែលអាចគ្រប់គ្រងនិងប្រមូលទិន្នន័យបច្ចុប្បន្នភាពក្នុងខណ្ឌ
- ជាមជ្ឈមណ្ឌលសម្រាប់ដំណើរការប្រព័ន្ធទិន្នន័យរបស់រាជរដ្ឋាភិបាលនៅក្នុងតំបន់ដែលអាចជួយសម្រួលនិងដំណើរការនូវគេហទំព័រ សេវាកម្មដល់ប្រជាពលរដ្ឋ ការងាររដ្ឋបាល និងជាប្រភពទិន្នន័យសម្រាប់ប្រព័ន្ធការងាររដ្ឋបាលអន្តរជាតិផង
- ជាមជ្ឈមណ្ឌលដែលអាចវិភាគនិងដោះស្រាយបញ្ហារបស់ខណ្ឌបានទាន់ហេតុការណ៍ផង។

ក.៣- សេវាផ្តល់សេចក្តីជូនដំណឹងពីព័ត៌មានស្តីពីសេវាសាធារណៈនៅក្នុងខណ្ឌដល់ប្រជាពលរដ្ឋ

- រៀបចំប្រព័ន្ធសេវាផ្តល់ព័ត៌មានដល់ប្រជាពលរដ្ឋឱ្យបានទៀងទាត់និងទាន់ហេតុការណ៍ដូចជាសន្តិសុខចរាចរណ៍ សុខាភិបាល រដ្ឋបាល បរិស្ថាន សេដ្ឋកិច្ច និងវប្បធម៌ជាដើម។

## ខ-វិស័យដឹកជញ្ជូន

ខ.១- កសាងប្រព័ន្ធដឹកជញ្ជូនសាធារណៈឆ្លាត

- បង្កើតប្រព័ន្ធគ្រប់គ្រងចរាចរណ៍តាមបែបសមាហរណកម្ម
- ប្រើប្រាស់ប្រព័ន្ធដឹកជញ្ជូនសន្សំសំចៃនិងមិនប៉ះពាល់ដល់បរិស្ថាន
- បង្កើតប្រព័ន្ធទំនាក់ទំនងសម្រាប់មធ្យោបាយដឹកជញ្ជូនសាធារណៈ
- ប្រើប្រាស់គំនូសផ្លូវឆ្លាតដោយលាយសារធាតុបារ៉ែត២០% ជាមួយនឹងទឹកថ្នាំគំនូសផ្លូវដើម្បីមានចំណាំងផ្លាតនិងភ្លឺក្នុងពេលធ្វើចរាចរណ៍នៅពេលយប់
- បំពាក់អំពូលឆ្លាតនៅតាមដងផ្លូវដែលជាប្រភេទអំពូលមានការសន្សំសំចៃខ្ពស់និងគ្រប់គ្រងថាមពលដោយស្វ័យប្រវត្តិ
- បំពាក់កាមេរ៉ាសុវត្ថិភាពតាមដងផ្លូវក្នុងខណ្ឌដើម្បីត្រួតពិនិត្យចរាចរណ៍ជាទូទៅនៅតាមដងផ្លូវក៏ដូចជាទីសាធារណៈនានាដើម្បីធានាសុវត្ថិភាពជូនប្រជាជននិងបង្ក្រាបនូវរាល់សកម្មភាពអវិជ្ជមានដែលកើតមានឱ្យបានទាន់ពេលវេលានិងមានប្រសិទ្ធភាព និងពន្លឿនការស្រាវជ្រាវរកមុខសញ្ញាចំពោះករណីណាមួយដែលកើតមានឡើង។

ខ.២- កសាងផ្លូវដឹកជញ្ជូនសាធារណៈនិងការផ្តល់ព័ត៌មាននៃពេលវេលាមកដល់

- បង្កើតប្រព័ន្ធព័ត៌មានពេលវេលាដឹកជញ្ជូនសាធារណៈដល់អ្នកដំណើរ
- ផ្តល់ការពិនិត្យព័ត៌មាននៃការធ្វើដំណើរមកដល់របស់រថយន្តសាធារណៈតាមទូរស័ព្ទដៃទំនើប។

ខ.៣- កសាងប្រព័ន្ធចតយានយន្តឆ្លាត

- កសាងសុវត្ថិភាពនិងបែងចែកចំណតសម្រាប់ចតយានយន្តផ្ទាល់ខ្លួន
- ផ្តល់ព័ត៌មានជាក់លាក់និងទាន់ពេលអំពីកន្លែងចតយានយន្ត។

**គ- ការប្រើប្រាស់ថាមពល**

- រៀបចំសន្សំសំចៃថាមពលដោយផ្តួចផ្តើមការប្រើប្រាស់ថាមពលកកើតឡើងវិញនៅតាមការិយាល័យនិងស្ថាប័នរដ្ឋ
- តាមស្ថានភាពខណ្ឌអាចធ្វើការផ្គត់ផ្គង់ថាមពលកកើតឡើងវិញដោយប្រើប្រាស់ពន្លឺព្រះអាទិត្យ
- លើកទឹកចិត្តនិងជំរុញការប្រើប្រាស់ថាមពលកកើតឡើងវិញដោយប្រើប្រាស់ពន្លឺព្រះអាទិត្យតាមរយៈការបំពាក់ឧបករណ៍បង្កើតថាមពលពន្លឺព្រះអាទិត្យនៅលើដំបូលអគារស្នាក់នៅ អគាររដ្ឋបាល និងកន្លែងចតយានយន្តជាដើម។

**ឃ- ការគ្រប់គ្រងធនធានទឹក**

- អភិវឌ្ឍប្រព័ន្ធគ្រប់គ្រងនិងប្រើប្រាស់ទឹកប្រកបដោយប្រសិទ្ធភាពនិងសន្សំសំចៃ
- រៀបចំផែនការគ្រប់គ្រងនិងប្រើប្រាស់ទឹកដែលមានប្រភពមកពីទឹកភ្លៀងតាមរយៈការបង្កើនប្រសិទ្ធភាពអាងស្តុកទឹកភ្លៀងនិងការគ្រប់គ្រងទីជម្រាល។

**ង- ការបង្ការគ្រោះមហន្តរាយ**

- រៀបចំប្រព័ន្ធឆ្លាតនិងផ្លូវសុវត្ថិភាពក្នុងការជម្លៀសចេញពីគ្រោះមហន្តរាយ
- រៀបចំប្រព័ន្ធផ្លូវចេញចូលសម្រាប់រថយន្តពន្លត់អគ្គិភ័យនិងរថយន្តសង្គ្រោះនៅក្នុងតំបន់លំនៅឋាននិងតំបន់ពាណិជ្ជកម្ម
- រៀបចំប្រព័ន្ធតាមដាននិងផ្តល់ព័ត៌មានអំពីគ្រោះមហន្តរាយឱ្យបានទាន់ពេលវេលាដើម្បីជូនដំណឹងដល់សាធារណជននៅពេលមានគ្រោះអាសន្ននានាកើតឡើងតាមរយៈទូរស័ព្ទដៃទំនើបឬតាមបណ្តាញសង្គមនានាឱ្យបានឆាប់រហ័សក្នុងការធានាសុវត្ថិភាពជូនប្រជាជននិងថែរក្សាទ្រព្យសម្បត្តិ។

**ច- ការគ្រប់គ្រងបរិស្ថាន**

- អភិវឌ្ឍប្រព័ន្ធឆ្លាតសម្រាប់គ្រប់គ្រងនិងប្រព្រឹត្តិកម្មទឹកកខ្វក់និងសំណល់រាវ
- អភិវឌ្ឍប្រព័ន្ធឆ្លាតសម្រាប់គ្រប់គ្រងសំណល់រឹង
- រៀបចំដំណើរការមជ្ឈមណ្ឌលគ្រប់គ្រងខណ្ឌតាមបែបសមាហរណកម្ម។

## ៤.២-យុទ្ធសាស្ត្រគ្រប់គ្រងនិងប្រើប្រាស់ដី

អនុលោមតាមអនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន អនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ និងអនុក្រឹត្យលេខ១៨១ អនក្រ.បក ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការដាក់ឱ្យអនុវត្តប្លង់គោលប្រើប្រាស់ដីរាជធានីភ្នំពេញ ចក្ខុវិស័យឆ្នាំ២០៣៥ ខណ្ឌព្រែកព្នៅត្រូវបានកំណត់ការប្រើប្រាស់ដីជាពីរប្រភេទគឺប្រភេទដីអាចសាងសង់បាននិងប្រភេទដីកម្រិតការសាងសង់។

### ៤.២.១- ប្រភេទដីអាចសាងសង់បាន

ខណ្ឌព្រែកព្នៅមានផ្ទៃដីសរុបប្រមាណ១១ ៥៦០,៩០ហិកតា ក្នុងនោះប្រភេទដីអាចសាងសង់បានមានផ្ទៃដីប្រមាណ៨ ០៦៧,៥៨ហិកតាស្មើនឹង៦៩,៧៨%នៃផ្ទៃដីសរុប។ ប្រភេទដីអាចសាងសង់បាន ត្រូវបានរៀបចំនិងបែងចែកជាតំបន់ដូចមានក្នុងផែនទីប្លង់គោលឧបសម្ព័ន្ធ ដូចខាងក្រោម៖

១) តំបន់លំនៅឋានមានផ្ទៃដីប្រមាណ៣ ៣១២,០៩ហិកតាស្មើនឹង៤១,០៥%នៃផ្ទៃដីអាចសាងសង់បាន។ តំបន់លំនៅឋានត្រូវបានបែងចែកបន្តដូចខាងក្រោម៖

- តំបន់លំនៅឋានដាច់ពីគ្នាដែលមានកម្ពស់ទាប (ត្រឹមជាន់ទី២) ស្ថិតនៅក្នុងសង្កាត់គោករកា និងសង្កាត់ព្រែកព្នៅដូចជាបុរីពិភពថ្មីឈូកវ៉ា១ កម្មបុរី បុរីសុខតុង បុរីសុខសាលី និងមួយផ្នែកទៀតស្ថិតនៅក្នុងសង្កាត់ពន្សាំងផ្នែកខាងជើងជាប់ផ្លូវវត្តភ្មៀតសិម្ពលីមានផ្ទៃដីប្រមាណ១ ៤៦៨,០០ហិកតាស្មើនឹង១៨,២០%នៃផ្ទៃដីអាចសាងសង់បាន ត្រូវមានសន្ទស្សន៍ប្រើប្រាស់ដីអតិបរមា១,៥ និងផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា៥០%
- តំបន់លំនៅឋានជាប់គ្នាដែលមានកម្ពស់ទាប (ត្រឹមជាន់ទី២) ស្ថិតនៅតំបន់លំនៅឋានជុំវិញផ្សារព្រែកព្នៅមានផ្ទៃដីប្រមាណ៣៧៨,៥៩ហិកតាស្មើនឹង៤,៦៩%នៃផ្ទៃដីអាចសាងសង់បាន ត្រូវមានសន្ទស្សន៍ប្រើប្រាស់ដីអតិបរមា១,៥ និងផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា៥០%
- តំបន់លំនៅឋានដែលមានកម្ពស់ខ្ពស់ប្រភេទទី១ (ត្រឹមជាន់ទី១៨) ស្ថិតនៅក្នុងសង្កាត់ទាំងប្រាំនៃខណ្ឌព្រែកព្នៅមានផ្ទៃដីប្រមាណ១០០,៧៤ហិកតាស្មើនឹង១,២៥%នៃផ្ទៃដីអាចសាងសង់បាន ត្រូវមានសន្ទស្សន៍ប្រើប្រាស់ដីអតិបរមា៥,០ និងផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា៦០%
- តំបន់លំនៅឋានដែលមានកម្ពស់ខ្ពស់ប្រភេទទី២ (ពីជាន់ទី១៩ឡើងទៅ) ស្ថិតនៅក្នុងសង្កាត់ទាំងប្រាំនៃខណ្ឌព្រែកព្នៅមានផ្ទៃដីប្រមាណ២២៤,៩១ហិកតាស្មើនឹង២,៧៩%នៃផ្ទៃដីអាចសាងសង់បាន ត្រូវមានសន្ទស្សន៍ប្រើប្រាស់ដីអតិបរមា៥,០ និងផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា៦០%
- តំបន់លំនៅឋានចម្រុះស្ថិតនៅក្នុងសង្កាត់ទាំងប្រាំនៃខណ្ឌព្រែកព្នៅ តាមដងផ្លូវមេសំខាន់ៗ និងនៅតំបន់ទីប្រជុំជន មានផ្ទៃដីប្រមាណ១ ១៣៩,៨៦ហិកតាស្មើនឹង១៤,១៣%នៃផ្ទៃដីអាចសាងសង់បាន ត្រូវមានសន្ទស្សន៍ប្រើប្រាស់ដីអតិបរមា៥,០ និងផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា៦៥%។

២) តំបន់ឧស្សាហកម្មមានផ្ទៃដីប្រមាណ១ ០២៦,១៣ហិកតាស្មើនឹង១២,៧២%នៃផ្ទៃដីអាចសាងសង់បាន។ តំបន់ឧស្សាហកម្មត្រូវបានបែងចែកបន្តដូចខាងក្រោម៖

- តំបន់ឧស្សាហកម្មស្រាលស្ថិតនៅផ្នែកខ្លះក្នុងសង្កាត់គោករកា និងសង្កាត់ពញាពន់មានផ្ទៃដីប្រមាណ១,៥៣ហិកតាស្មើនឹង០,០២%នៃផ្ទៃដីអាចសាងសង់បាន ត្រូវមានសន្ទស្សន៍ប្រើប្រាស់ដីអតិបរមា៣,០ និងផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា៦០%
- តំបន់ឧស្សាហកម្មចម្រុះស្ថិតនៅផ្នែកខ្លះក្នុងសង្កាត់សំរោងភាគខាងលិច មានផ្ទៃដីប្រមាណ១ ០២៤,៦១ហិកតាស្មើនឹង១២,៧០%នៃផ្ទៃដីអាចសាងសង់បាន ត្រូវមានសន្ទស្សន៍ប្រើប្រាស់ដីអតិបរមា៣,០ និងផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា៦០%។

៣) តំបន់ចម្រុះស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ៥ផ្នែកខាងលិចមានផ្ទៃដីប្រមាណ៩៤២,៣៥ហិកតាស្មើនឹង១១,៦៨%នៃផ្ទៃដីអាចសាងសង់បាន ត្រូវមានសន្ទស្សន៍ប្រើប្រាស់ដីអតិបរមា១០,០ និងផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា៧០%។

៤) តំបន់ទេសចរណ៍ស្ថិតនៅជុំវិញបឹងតាមោក និងតាមបណ្តោយផ្លូវជាតិលេខ៥ស្របតាមទន្លេបាសាក់ជុំវិញបឹងសំរោង ភ្នំរាប ភ្នំប្រសិទ្ធិមានផ្ទៃដីប្រមាណ៧០,៣៦ហិកតាស្មើនឹង០,៨៧%នៃផ្ទៃដីអាចសាងសង់បាន ត្រូវមានសន្ទស្សន៍ប្រើប្រាស់ដីអតិបរមា៥,០ និងផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា៥០%។

៥) តំបន់ដឹកជញ្ជូនមានបណ្តាញផ្លូវ ចំណតរថយន្តក្រុង និងកំពង់ផែមានផ្ទៃដីប្រមាណ២ ១៥៥,៧២ហិកតាស្មើនឹង២៦,៧២%នៃផ្ទៃដីអាចសាងសង់បានក្នុងនោះដីចំណីផ្លូវសាធារណៈមានផ្ទៃដីប្រមាណ២ ១៣៨,៣៩ហិកតាស្មើនឹង២៦,៥១% ត្រូវមានសន្ទស្សន៍ប្រើប្រាស់ដីអតិបរមា៣,០ និងផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា៦០%។

៦) តំបន់រដ្ឋបាលនិងសេវាសាធារណៈមានគ្រឹះស្ថានសិក្សាធិការ អប់រំ កីឡា សុខភាព សាលប្រជុំ/ពិធីការិយាល័យ និងរដ្ឋបាលសាធារណៈ មានផ្ទៃដីប្រមាណ៤០,១៧ហិកតាស្មើនឹង០,៥០%នៃផ្ទៃដីអាចសាងសង់បាន ត្រូវមានសន្ទស្សន៍ប្រើប្រាស់ដីអតិបរមា៥,០ និងផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា៦០%។

៧) តំបន់លម្ហសាធារណៈនិងផ្ទៃបៃតងមានទីតាំងនៅច្រាំងដីចំណីទន្លេ ដីចំណីបឹងសំរោង និងដីចំណីបឹងតាមោកមានផ្ទៃដីប្រមាណ៤៤៨,០២ហិកតាស្មើនឹង៥,៥៥%នៃផ្ទៃដីអាចសាងសង់បាន ត្រូវមានសន្ទស្សន៍ប្រើប្រាស់ដីអតិបរមា៣,០ និងផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា១០%។ ជំរុញរៀបចំនិងអភិវឌ្ឍសួនសាធារណៈនិងសួនក្នុងតំបន់លំនៅឋានបន្ថែមឱ្យបានយ៉ាងតិច១០%នៃផ្ទៃដីអាចសាងសង់បាននៅឆ្នាំ២០៣៥។

៨) តំបន់វប្បធម៌និងសាសនាស្ថិតនៅបរិវេណវត្តនិងទីទួលបុរាណដូចជាវត្តចន្ទមុនីវង្ស វត្តអង្គសិរីសួស្តី វត្តប្រាសាទ វត្តបឹងប្រីយ៍ វត្តជុំ វត្តឈូកវ៉ា ត្រពាំងស្វាយធំ ទួលអ្នកតាព្រីងក្អែក ទួលត្រពាំងសេះ ទួលអង្គ ទួលកន្ទោង១០០ ទួលតាសួរ និងទួលកំណប់ មានផ្ទៃដីប្រមាណ៧២,៧២ហិកតាស្មើនឹង០,៩០%នៃផ្ទៃដីអាចសាងសង់បាន ត្រូវមានសន្ទស្សន៍ប្រើប្រាស់ដីអតិបរមា២,០ និងផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា៥០%។

សន្ទស្សន៍ប្រើប្រាស់ដីអតិបរមា ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍ សួនច្បារជ្រាបទឹក ដាំដើមឈើ ផ្លូវតម្រង់ ផ្លាគម្លាត កម្ពស់សំណង់ ចំណតរថយន្ត អាងបង្គន់អនាម័យ អាងប្រព្រឹត្តកម្មទឹកកខ្វក់ ពណ៌អគារ សោភណភាព និងរចនាបថស្ថាបត្យកម្មខ្មែរនិង/ឬលក្ខណៈធម្មជាតិនៃតំបន់នីមួយៗដូចបានកំណត់ខាងលើត្រូវអនុវត្តឱ្យបានត្រឹមត្រូវស្របតាមបទប្បញ្ញត្តិជាធរមាន។

### ៤.២.២- ប្រភេទដីកម្រិតការសាងសង់

ប្រភេទដីកម្រិតការសាងសង់ មានផ្ទៃដីប្រមាណ៣ ៤៩៣,៣២ហិកតាស្មើនឹង៣០,២២%នៃផ្ទៃដីសរុប។ ប្រភេទដីកម្រិតការសាងសង់ ត្រូវបានរៀបចំនិងបែងចែកជាតំបន់ដូចមានក្នុងផែនទីប្លង់គោលឧបសម្ព័ន្ធ ដូចខាងក្រោម៖

១) តំបន់កសិកម្មៈ ស្ថិតនៅសង្កាត់ពន្សាំងផ្នែកខាងជើងជាប់ភូមិបឹង ខាងត្បូងជាប់ភូមិចុងថ្នល់ ខាងលិចជាប់ផ្លូវលេខ៤២ ខាងកើតជាប់បឹងតាមោកមានផ្ទៃដីប្រមាណ៩៨៩,៩១ហិកតាស្មើនឹង២៨,៣៤% នៃផ្ទៃដីកម្រិតការសាងសង់។

២) តំបន់ធនធានទឹកៈ មានតំបន់ទន្លេសាប តំបន់បឹងតាមោក តំបន់បឹងសំរោង តំបន់ព្រៃកញ្ចៅ តំបន់ព្រៃកអូរពីមពិស តំបន់អូរផ្សេងៗមានផ្ទៃដីប្រមាណ២ ៣៤៦,៥៩ហិកតាស្មើនឹង៦៧,១៧%នៃផ្ទៃដីកម្រិតការសាងសង់។

៣) តំបន់ការពារៈ មានតំបន់ច្រាំងទន្លេសាបដែលត្រូវរក្សា៥០ម៉ែត្រ បឹងតាមោក បឹងសំរោងមានផ្ទៃដីប្រមាណ១៥៦,៨២ហិកតាស្មើនឹង៤,៤៩%នៃផ្ទៃដីកម្រិតការសាងសង់។

## ៤.៣-យុទ្ធសាស្ត្រអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ

ហេដ្ឋារចនាសម្ព័ន្ធត្រូវតែពង្រឹងនិងលើកកម្ពស់ឱ្យដល់កម្រិតសម្រាប់បម្រើវិស័យវប្បធម៌ សាសនា សេដ្ឋកិច្ចសង្គម ទេសចរណ៍ ពាណិជ្ជកម្ម និងបរិស្ថានក្នុងខណ្ឌព្រែកព្នៅរួមមានៈ

### ៤.៣.១- ផ្លូវថ្នល់

- បន្តការពារនិងជួសជុលផ្លូវមេនិងផ្លូវសំខាន់ៗទៀតក្នុងមូលដ្ឋាន
- បន្តការកសាងផ្លូវតាមបណ្តោយច្រាំងទន្លេក្នុងភូមិ ផ្លូវសង្កាត់ដើម្បីចូលរួមអភិវឌ្ឍវិស័យទេសចរណ៍ សុខុមាលភាព និងសោភណភាពរាជធានីភ្នំពេញ
- បន្តរៀបចំផ្លូវឱ្យល្អប្រណីត អមដោយដើមផ្កាអមសងខាងផ្លូវនិងសួនពុះចែកទ្រូងផ្លូវ ចិញ្ចើមផ្លូវ ផ្លូវថ្មើរជើង ផ្លូវសម្រាប់ជនមានពិការភាព គន្លងផ្លូវទោចក្រយាន បរិក្ខារផ្លូវថ្នល់ដែលមានបរិស្ថានធម្មជាតិស្រស់បំព្រង បង្គោលភ្លើងបំភ្លឺផ្លូវ និងភ្លើងលម្អប្រកបដោយក្បូរក្បាច់រចនាបថខ្មែរនិងធម្មជាតិ និងសក្តានុពលទាក់ទាញភ្ញៀវទេសចរនិងអ្នកដំណើរឆ្លងកាត់
- សិក្សាការបើកផ្លូវ ផ្លូវត្រឡប់ក្រោយ ច្រកផ្លូវ និងពង្រីកទ្រូងផ្លូវបន្ថែមដើម្បីបង្កភាពងាយស្រួលដល់ចរាចរណ៍សាធារណៈ
- រៀបចំគន្លងផ្លូវរថយន្តសាធារណៈនៅតាមផ្លូវសំខាន់ៗនិងតំបន់ទីប្រជុំជនដើម្បីសម្រួលដល់ការធ្វើចរាចរណ៍នៃរថយន្តសាធារណៈក៏ដូចជាលើកទឹកចិត្តដល់ប្រជាជនប្រើប្រាស់សេវារថយន្តសាធារណៈ
- ជំរុញអនុវត្តសេចក្តីសម្រេចលេខ០៣៩ សសរ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការដាក់ឱ្យប្រើប្រាស់ប្លង់ស្តាបត្យកម្មចិញ្ចើមផ្លូវ ផ្លូវថ្មើរជើង និងគន្លងផ្លូវទោចក្រយានសម្រាប់សាធារណជននិងជនមានពិការភាពដើម្បីធានាសោភណភាពសាធារណៈនិងការធ្វើចរាចរណ៍ប្រកបដោយសុវត្ថិភាព សុខុមាលភាពនិងភាពងាយស្រួលដល់សាធារណជននិងជនមានពិការភាព
- រៀបចំកំណត់កម្ពស់ផ្លូវនិងចិញ្ចើមផ្លូវដោយមានកម្ពស់០,២ម៉ែត្រធៀបជាមួយនឹងកម្រិតកម្ពស់ទ្រូងផ្លូវ មានមុំជម្រាល០,១% និងមានបទដ្ឋានបច្ចេកទេសតែមួយដើម្បីមានភាពងាយស្រួលសម្រាប់អ្នកថ្មើរជើងនិងធានាបាននូវសុវត្ថិភាព។

### ៤.៣.២- ផ្លូវទឹក

- ការពារដីចំណើទន្លេ និងការពារថែរក្សាផ្ទៃទឹកទន្លេពីការសាងសង់សំណង់ផ្សេងៗដែលប៉ះពាល់ដល់ការធ្វើចរាចរណ៍ផ្លូវទឹក
- រៀបចំមធ្យោបាយធ្វើដំណើរតាមផ្លូវទឹកឱ្យបានច្រើនប្រភេទដើម្បីសម្រួលដល់ការធ្វើដំណើរទូទៅ
- សិក្សាការចាក់ដីបំពេញដីឡូត៍នៅតាមតំបន់ងាយលិចលង់ដែលតម្រូវឱ្យម្ចាស់ស្នើសុំលិខិតអនុញ្ញាតអភិវឌ្ឍដីជាមុនសិន
- សិក្សាសំណង់ច្រាំងទន្លេដើម្បីការពារការបាក់ស្រុតដីច្រាំងចូលក្នុងទឹកទន្លេដែលធ្វើឱ្យជម្រៅទឹករាក់ដែលនឹងប៉ះពាល់ដល់ការធ្វើចរាចរណ៍ផ្លូវទឹក
- សិក្សាប្រព័ន្ធចរាចរណ៍ផ្លូវទឹកនិងរៀបចំផ្លូវទឹកតាមដងទន្លេសាបដោយរៀបចំឱ្យមានប្រព័ន្ធដឹកជញ្ជូនតាមផ្លូវទឹក និងសិក្សាការបូមដីពីបាតទន្លេដែលធ្វើឱ្យរាំងស្ទះដល់ការធ្វើចរាចរណ៍តាមផ្លូវទឹកស្របតាមបទដ្ឋានបច្ចេកទេសនិងកិច្ចការពារបរិស្ថានបាតទន្លេ
- សិក្សារៀបចំភ្លើងបំភ្លឺតាមបណ្តោយច្រាំងទន្លេដែលស្ថិតក្នុងខណ្ឌព្រែកព្នៅដើម្បីសម្រួលដល់ការធ្វើចរាចរណ៍ផ្លូវទឹកនិងបម្រើដល់វិស័យទេសចរណ៍
- សិក្សាគម្រោងប្លង់ដែលមានសោភណភាពល្អប្រពៃទាក់ទាញសម្រាប់ការអភិវឌ្ឍនិងការសាងសង់កំពង់ផែ និងចំណតសម្រាប់ការធ្វើដំណើរ ទេសចរណ៍ និងការលើកដាក់ទំនិញតាមច្រាំងទន្លេ។

### ៤.៣.៣- ផ្លូវអាកាស

- រក្សាលម្ហអាកាសពីការសាងសង់សំណង់ផ្សេងៗដោយកំណត់កម្ពស់សំណង់ក្នុងតំបន់គ្រប់គ្រងកម្ពស់ឧបសគ្គនៃអាកាសយានដ្ឋានអន្តរជាតិភ្នំពេញស្របតាមព្រះរាជក្រមលេខ នស/រកម/០១០៨/០០៣ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអាកាសចរស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- ពិនិត្យលទ្ធភាពអនុញ្ញាតឱ្យមន្ទីរពេទ្យដែលត្រូវរៀបចំឱ្យមានចំណតឧទ្ធម្ភាគចក្រ និងនិមិត្តសញ្ញាពេទ្យនៅលើដំបូលអគារដើម្បីជួយសង្គ្រោះបន្ទាន់
- បំពាក់ភ្លើងសញ្ញាពណ៌ក្រហមនៅតាមជ្រុងនៃអគារដែលមានកម្ពស់ខ្ពស់តាមបទដ្ឋានបច្ចេកទេសរបស់អាកាសចរស៊ីវិល។

### ៤.៣.៤- ការគ្រប់គ្រងធនធានទឹកនិងការផ្គត់ផ្គង់ទឹកស្អាត

- កំណត់ទីតាំងនិងចាត់វិធានការក្នុងការការពារប្រភពផ្គត់ផ្គង់ទឹកដែលបណ្តាលមកពីការអភិវឌ្ឍ
- បន្តលើកកម្ពស់ការផ្គត់ផ្គង់ទឹកស្អាតដោយយកចិត្តទុកដាក់លើគុណភាពនិងបរិមាណ
- គ្រប់គ្រងធនធានទឹកដែលមានប្រភពពីទឹកភ្លៀងសម្រាប់សម្អាតទីក្រុងនិងស្រោចដំណាំ
- ជំរុញការថែទាំនិងកែលម្អបណ្តាញចែកចាយទឹកស្អាត
- បង្កើតឱ្យមានស្ថានីយចម្រោះទឹកស្អាតទំនើបក្នុងខណ្ឌសម្រាប់ស្តុកនិងចែកចាយទឹកស្អាតប្រកបដោយស័យភាព។

### ៤.៣.៥- ការផ្គត់ផ្គង់ថាមពលអគ្គិសនី ទូរគមនាគមន៍ បច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍

- បន្តកែលម្អបណ្តាញអគ្គិសនីនិងទូរគមនាគមន៍ឱ្យស្របទៅតាមបទដ្ឋានបច្ចេកទេស ចៀសវាងបង្កគ្រោះថ្នាក់និងបាត់បង់នូវសោភណភាពខណ្ឌ
- រៀបចំឱ្យមានប្រព័ន្ធសុវត្ថិភាពស្វ័យប្រវត្តិនៅទីសាធារណៈដើម្បីងាយស្រួលគ្រប់គ្រងនិងអន្តរាគមន៍ឱ្យបានទាន់ពេលវេលាដើម្បីធានាបាននូវសុវត្ថិភាពក្នុងការរស់នៅ
- ជំរុញលទ្ធភាពរៀបចំបណ្តាញអគ្គិសនី ឬបណ្តាញបញ្ជូនអគ្គិសនី បណ្តាញទូរគមនាគមន៍ ខ្សែកាប្លិ៍គ្រប់ប្រភេទ កប់ក្នុងដី ដើម្បីការអភិវឌ្ឍប្រកបដោយចីរភាពនិងរក្សាដល់សោភណភាពទីក្រុង
- ជំរុញការវិនិយោគនិងការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាននិងគមនាគមន៍ ដើម្បីគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ច ទេសចរណ៍ និងពាណិជ្ជកម្ម។

### ៤.៣.៦- ហេដ្ឋារចនាសម្ព័ន្ធសង្គម

- ជំរុញស្តារ និងរៀបចំលម្អសាធារណៈ ផ្ទៃបៃតង សួនសាធារណៈ មជ្ឈមណ្ឌលវប្បធម៌ និងសាសនាសម្រាប់មនុស្សគ្រប់គ្នារួមមានកុមារ យុវជន ស្ត្រីមានគភ៌ មនុស្សវ័យចាស់ និងជនមានពិការភាពឱ្យទទួលបាននូវសេវាប្រកបដោយសមធម៌
- រៀបចំឱ្យមានចិញ្ចើមផ្លូវ ផ្លូវថ្មើរជើង គន្លងផ្លូវទោចក្រយាន បង្គន់អនាម័យ និងបរិក្ខារសម្រាប់សាធារណជននិងជនមានពិការភាពដើម្បីធានាសោភណភាពសាធារណៈនិងការធ្វើចរាចរណ៍ប្រកបដោយសុវត្ថិភាព សុខុមាលភាព និងភាពងាយស្រួលដល់សាធារណជននិងជនមានពិការភាព
- រៀបចំឱ្យមានសាលារៀននិងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈគ្រប់កម្រិតក្នុងខណ្ឌស្របតាមបទប្បញ្ញត្តិរៀបចំដែនដីនិងនគរូបនីយកម្ម និងបទដ្ឋានបច្ចេកទេសរបស់ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- រៀបចំកែលម្អនិងពង្រីកសេវាកម្មសុខាភិបាលនៅគ្រប់កម្រិត មានជាអាទិ៍ប៉ុស្តិ៍សុខភាព កន្លែងសង្គ្រោះបន្ទាន់ មណ្ឌលសុខភាព មន្ទីរពេទ្យ ឱសថស្ថាននៅក្នុងខណ្ឌស្របតាមបទដ្ឋានបច្ចេកទេសរបស់ក្រសួងសុខាភិបាល
- រៀបចំឱ្យមានសួនជ្រាបទឹកនៅតាមហេដ្ឋារចនាសម្ព័ន្ធសង្គម។

## ៤.៤- យុទ្ធសាស្ត្រអភិវឌ្ឍសេដ្ឋកិច្ច

### ៤.៤.១- ការអភិវឌ្ឍវិស័យទេសចរណ៍

ខណ្ឌព្រែកព្នៅមានសក្តានុពលទេសចរណ៍ជាច្រើនដូចជាតំបន់ទេសចរណ៍វប្បធម៌ ទេសចរណ៍ធម្មជាតិ និងខ្សែទស្សនកិច្ចកម្សាន្ត ផលិតផល ហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មទេសចរណ៍។

១) តំបន់ទេសចរណ៍វប្បធម៌និងសោភណភាព

- អភិវឌ្ឍតំបន់ទេសចរណ៍ក្នុងខណ្ឌជាតំបន់លំនៅឋានបម្រើទេសចរណ៍ប្រកបដោយសុខុមាលភាព
- ថែរក្សានិងការពារសំណង់សម្រាប់បម្រើវិស័យវប្បធម៌និងសាសនា

- កែលម្អនិងរៀបចំមហាវិថី វិថី អនុវិថីសម្រាប់មនុស្សទាំងអស់គ្នាដោយរៀបចំឱ្យមានផ្លូវសម្រាប់រថយន្ត គន្លងផ្លូវទោចក្រយាន ផ្លូវថ្មើរជើង ផ្លូវជនមានពិការភាព ចំណតរថយន្ត សញ្ញាបង្ហាញផ្លូវទេសចរណ៍ ប្រព័ន្ធការពារសុវត្ថិភាពតាមបទដ្ឋានបច្ចេកទេសនិងអភិវឌ្ឍបៃតងដោយធានាសោភណភាព វប្បធម៌ សន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាព និងគុណភាពបរិស្ថានល្អ
- រៀបចំតំបន់ទេសចរណ៍វប្បធម៌ដោយចងក្រងសហគមន៍ទេសចរណ៍ អភិវឌ្ឍទេសចរណ៍ស្នាក់នៅនិងជំរុញការលក់ផលិតផលក្នុងស្រុក ព្រមទាំងរៀបចំកម្មវិធីប្រពៃណីនិងកម្សាន្តផ្សេងៗ
- កំណត់កំរង្វង់គោលការណ៍អភិវឌ្ឍជុំវិញតំបន់វប្បធម៌និងសាសនាស្របតាមអនុក្រឹត្យលេខ១៩១ អនក្រ.បក ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រងមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ។

២) តំបន់ទេសចរណ៍ធម្មជាតិ

- ជំរុញការរៀបចំអភិវឌ្ឍទេសចរណ៍ធម្មជាតិនិងទេសចរណ៍កែច្នៃនៅតាមដងទន្លេ បឹង ព្រែក និងរុក្ខវិថី
- លើកកម្ពស់ប្រសិទ្ធភាពនៃការអភិរក្សនិងការការពារធនធានធម្មជាតិនិងជីវចម្រុះតាមដងទន្លេសាប បឹងតាមោក បឹងសំរោង
- រៀបចំដីចំណីច្រាំងទន្លេជាសួនច្បារ តំបន់លម្ហែកម្សាន្ត និងកន្លែងទេសចរណ៍ធម្មជាតិដែលមានអនាម័យបរិស្ថានល្អនិងរក្សាលក្ខណៈធម្មជាតិរបស់ទន្លេដើម្បីទាក់ទាញភ្ញៀវទេសចរមកកម្សាន្ត
- កែច្នៃច្រាំងទន្លេសាប តំបន់អភិរក្សបឹងតាមោក និងបឹងសំរោងឱ្យក្លាយជាតំបន់លម្ហសាធារណៈនិងផ្ទៃបៃតងសម្រាប់បម្រើសេវាទេសចរណ៍
- លើកទឹកចិត្តដល់វិស័យឯកជនឱ្យមានដំណើរការល្អចំពោះសេវាកម្មនាវាកម្សាន្តដើម្បីបំពេញតម្រូវការភ្ញៀវទេសចរ
- បង្កើតឱ្យមានផែទេសចរណ៍នៅតំបន់ផ្នែកខាងលិចនិងខាងកើតបឹងតាមោកដើម្បីបម្រើចរាចរណ៍ផ្លូវទឹកចាប់ពីបឹងតាមោកបន្តទៅទន្លេសាបតាមដងព្រែកព្នៅ។

៣) ខ្សែទស្សនកិច្ចកម្សាន្ត ផលិតផល ហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មទេសចរណ៍

- បន្តកែលម្អរមណីយដ្ឋាន សួនច្បារ បណ្តាញផ្លូវ ទឹកស្អាត អគ្គិសនី និងប្រព័ន្ធលូ
- រៀបចំបែងចែកតំបន់សណ្ឋាគារ រមណីយដ្ឋាន ផ្សារទំនើប ផ្សាររាត្រី និងលំនៅឋានទេសចរណ៍
- លើកទឹកចិត្តនិងបង្កលក្ខណៈងាយស្រួលដល់ផ្នែកឯកជនក្នុងការកសាងអគារបម្រើវិស័យទេសចរណ៍ រួមមានការកម្សាន្ត រមណីយដ្ឋាន សណ្ឋាគារ ភោជនីយដ្ឋាន ទេសចរណ៍ផ្នែកធុរកិច្ច និងពិព័រណ៍ផលិតផល
- អភិវឌ្ឍទេសចរណ៍សម្រាប់ការស្នាក់នៅរយៈពេលខ្លីនិងយូរប្រកបដោយជាសុខភាពតាមរយៈការរៀបចំខណ្ឌឱ្យមានសុវត្ថិភាព បរិស្ថានរស់នៅល្អ ខ្យល់អាកាសល្អបរិសុទ្ធ ទិដ្ឋភាពធម្មជាតិជាមួយនឹងសេវាកម្មល្អ ដោយបន្តការសាងសង់មូលដ្ឋានសេវាកម្មម្ហូបអាហារនិងភេសជ្ជៈនិងមូលដ្ឋានសេវាកម្មស្នាក់នៅនិងទេសចរណ៍
- ធ្វើសមាហរណកម្មផែនការអភិវឌ្ឍន៍ទេសចរណ៍ទៅក្នុងផែនការអភិវឌ្ឍន៍ខណ្ឌដើម្បីធានាបាននូវការអភិវឌ្ឍប្រកបដោយចីរភាព

- ធ្វើសមាហរណកម្មតំបន់ទេសចរណ៍ជាមួយនឹងតំបន់ទេសចរណ៍ក្នុងភូមិសាស្ត្ររាជធានីភ្នំពេញនិងខេត្តកណ្តាល
- រៀបចំនិងបំពាក់បរិក្ខារនៅតាមដងផ្លូវ កន្លែងកម្សាន្ត កន្លែងស្នាក់នៅ និងកន្លែងផ្សេងៗទៀត ដើម្បីធានាសន្តិសុខនិងសុវត្ថិភាពសម្រាប់ភ្ញៀវទេសចរ
- រៀបចំគេហទំព័រទេសចរណ៍ដោយចាំបាច់ត្រូវតភ្ជាប់ជាមួយគេហទំព័ររបស់ក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាល
- កែច្នៃរមណីយដ្ឋានភ្នំរាប ភ្នំប្រសិទ្ធិ ទីទួលបុរាណ ស្រះបុរាណ បឹងតាមោក បឹងសំរោង សួនច្បារលម្ហែកម្សាន្ត សួនកុមារ ទីលានសម្រាប់ប្រជាជនមកពីបណ្តាខេត្តឆ្ងាយៗមកកម្សាន្ត និងសេវាបម្រើវិស័យទេសចរណ៍ផ្សេងៗទៀត
- ជំរុញរៀបចំហេដ្ឋារចនាសម្ព័ន្ធដើម្បីបម្រើខ្សែទស្សនកិច្ចកម្សាន្តទេសចរណ៍
- រៀបចំសណ្តាប់ធ្នាប់ ប្រព័ន្ធចរាចរណ៍ កំពង់ចម្លង ផ្លាកសញ្ញាបង្ហាញផ្លូវភ្ញៀវទេសចរ និងប្រព័ន្ធការពារសុវត្ថិភាពភ្ញៀវទេសចរ
- កែលម្អនិងរៀបចំទីផ្សារ កន្លែងលក់វត្ថុអនុស្សាវរីយ៍ កន្លែងផ្តល់សេវាកម្ម និងព័ត៌មានទេសចរណ៍
- ជំរុញរៀបចំអភិវឌ្ឍផលិតផលទេសចរណ៍និងរៀបចំកែច្នៃផលិតផលឱ្យមានលក្ខណៈជាតិ
- កសាងនិងកែលម្អហេដ្ឋារចនាសម្ព័ន្ធនិងសេវាកម្មទេសចរណ៍។

### ៤.៤.២-ការអភិវឌ្ឍវិស័យពាណិជ្ជកម្មនិងសេវាកម្ម

- ធ្វើការបែងចែកតំបន់ប្រើប្រាស់ដីពាណិជ្ជកម្មសម្រាប់អនាគតឱ្យបានច្បាស់លាស់និងត្រឹមត្រូវ
- កែលម្អនិងពង្រីកទីផ្សារលក់ដូរដើម្បីឱ្យប្រជាពលរដ្ឋនិងអាជីវករក្នុងផ្សារមានកន្លែងលក់ដូរធំទូលាយសមស្របនិងមានសណ្តាប់ធ្នាប់
- រៀបចំមជ្ឈមណ្ឌលផ្សព្វផ្សាយនិងមណ្ឌលព័ត៌មានអំពីស្តង់ដាបច្ចេកទេសផលិតផលិតផលក្នុងស្រុកដល់ប្រជាពលរដ្ឋ
- កែលម្អផ្សារនិងមជ្ឈមណ្ឌលពាណិជ្ជកម្មមានស្រាប់ទាំងឯកជននិងរដ្ឋឱ្យមានលក្ខណៈស្តង់ដាររួមមានចំណតយានយន្ត ច្រកចេញចូលនិងផ្លូវដើរក្នុងផ្សារ បណ្តាញទឹកស្អាត បណ្តាញអគ្គិសនី តំបន់បៃតងនិងហេដ្ឋារចនាសម្ព័ន្ធកម្សាន្តឱ្យមានរបៀបរៀបរយនិងសណ្តាប់ធ្នាប់
- រៀបចំបង្កើតផ្សារដើម្បីឆ្លើយតបទៅនឹងតម្រូវការក្នុងជីវភាពរស់នៅរបស់ប្រជាជន
- គាំទ្រឱ្យមានការវិនិយោគផ្សារទំនើប ហាងទំនិញ ផ្សាររាត្រី មជ្ឈមណ្ឌលពាណិជ្ជកម្ម ធនាគារ ឃ្លាំងនិងសហគ្រាសផ្សេងៗដើម្បីងាយស្រួលក្នុងការដោះដូរទំនិញ បង្កើតការងារ និងលើកស្ទួយការអភិវឌ្ឍសេដ្ឋកិច្ចឱ្យបានខ្លាំងក្លា
- រៀបចំដេប៉ូស្តុកទំនិញសម្រាប់ចែកចាយក្នុងខណ្ឌនិងតំបន់ជុំវិញនិងសាងសង់ហេដ្ឋារចនាសម្ព័ន្ធឱ្យបានល្អដើម្បីជួយសម្រួលដល់ការដឹកជញ្ជូន
- រៀបចំទីកន្លែងសម្រាប់តាំងពិព័រណ៍និងផ្សព្វផ្សាយផលិតផលគ្រប់ប្រភេទដើម្បីបង្កើនការផលិតនិងជំរុញសេដ្ឋកិច្ចឱ្យបានខ្លាំងក្លា។

### ៤.៤.៣- ការអភិវឌ្ឍវិស័យឧស្សាហកម្ម

- រៀបចំបែងចែកតំបន់ឧស្សាហកម្មឱ្យសមស្របទៅតាមបទដ្ឋានបច្ចេកទេសនិងត្រូវមានទីតាំងដាច់ចេញពីតំបន់លំនៅឋាន
- លើកទឹកចិត្តដល់អ្នកវិនិយោគជាតិនិងអន្តរជាតិដែលមកធ្វើឧស្សាហកម្មបៃតងក្នុងខណ្ឌ
- បង្កើនឧស្សាហកម្មបៃតងសម្រាប់សហគ្រាសខ្នាតតូចនិងមធ្យមសំដៅតភ្ជាប់រវាងសហគ្រាសខ្នាតធំក្រៅប្រទេសនិងសហគ្រាសនៅក្នុងស្រុក ជាពិសេសការចូលរួមក្នុងខ្សែច្រវាក់តម្លៃនិងខ្សែច្រវាក់ផលិតកម្ម
- ជំរុញអភិវឌ្ឍឧស្សាហកម្មធុនស្រាលឬសិប្បកម្មដែលប្រើប្រាស់គ្រឿងម៉ាស៊ីនស្វ័យប្រវត្តិទំនើបសម្រាប់កែច្នៃផលិតផលក្នុងស្រុកនិងសម្ភារៈប្រើប្រាស់ផ្សេងៗដើម្បីបំពេញតម្រូវការរបស់ប្រជាពលរដ្ឋក្នុងខណ្ឌក៏ដូចជាក្នុងរាជធានីនិងសម្រាប់ការចែកចាយទាំងក្នុងនិងក្រៅប្រទេស
- លើកទឹកចិត្តការវិនិយោគរោងចក្រផលិតគ្រឿងបរិភោគនិងភេសជ្ជៈ រោងចក្រដំឡើងយានយន្តនិងគ្រឿងអេឡិចត្រូនិក និងសិប្បកម្មដែលអាចបង្កើតការងារជូនប្រជាពលរដ្ឋដើម្បីលើកស្ទួយជីវភាពរស់នៅប្រចាំថ្ងៃ
- ផ្លាស់ប្តូរទីតាំងរោងចក្រ សហគ្រាស សិប្បកម្ម ស្ថានីយប្រេងឥន្ធនៈ និងអាជីវកម្មបច្ចុប្បន្នដែលប៉ះពាល់ដល់បរិស្ថាននិងសុខភាពឱ្យទៅសាងសង់និងកែសម្រួលឡើងវិញស្របតាមស្តង់ដាបរិស្ថាននិងតាមប្លង់គោលប្រើប្រាស់ដីខណ្ឌ។

### ៤.៤.៤- ការគាំទ្រការអភិវឌ្ឍវិស័យកសិកម្មនិងផ្សព្វផ្សាយផលិតផលក្នុងស្រុក

- ជំរុញការពារនិងបង្កើនផ្ទៃដីកសិកម្ម លើកកម្ពស់គុណភាពផលិតផល និងផ្សព្វផ្សាយផលិតផលក្នុងស្រុកដែលផលិតដោយកសិករ ឬអ្នកជំនួញក្នុងខណ្ឌ
- ជំរុញរៀបចំឱ្យមានកន្លែងលក់ផលិតផលក្នុងស្រុកនៅតាមផ្សារក្នុងខណ្ឌ
- ជំរុញការអភិវឌ្ឍផលិតផលក្នុងស្រុកតាមតម្រូវការទីផ្សារទេសចរណ៍និងសិក្សាទីផ្សារឱ្យបានទូលំទូលាយ
- ពិនិត្យលទ្ធភាពក្នុងការកំណត់ទីតាំងផលិតផលិតផលក្នុងស្រុកតាមសង្កាត់ផ្សារភ្ជាប់ជាមួយនឹងទេសចរណ៍
- សហការជាមួយស្ថាប័ននិងអង្គភាពពាក់ព័ន្ធដើម្បីលុបបំបាត់ឱ្យបាននូវការផលិតផលិតផលក្នុងស្រុកដែលមិនគោរពតាមបទដ្ឋានបច្ចេកទេសនិងបទដ្ឋានគតិយុត្តជាធរមាន
- អភិវឌ្ឍធនធានមនុស្សដោយជំរុញការបណ្តុះបណ្តាលជំនាញដល់អ្នកផលិតដោយអនុវត្តតាមបទដ្ឋានបច្ចេកទេសនិងចលនាផ្ទែកឯកជនឱ្យចូលរួមការបណ្តុះបណ្តាលនៅតាមមូលដ្ឋាន
- ថែរក្សាទីតាំងតំបន់សម្រាប់ការលក់ដូរនិងផ្សាំបណ្តុះរុក្ខជាតិ កូនឈើ ផ្កាឱ្យទៅជាតំបន់បៃតងនៅក្នុងមូលដ្ឋានដើម្បីប្រែក្លាយជាតំបន់ទេសចរណ៍ធម្មជាតិសម្រាប់ការលម្ហែកម្សាន្ត។

### ៤.៥-យុទ្ធសាស្ត្រអភិវឌ្ឍសង្គមកិច្ច

- ដោះស្រាយសំណង់មិនរៀបរយនៅលើដីសាធារណៈនិងដីឯកជនរបស់រដ្ឋជាពិសេសនៅតាមផ្លូវជាតិលេខ៥ ផ្លូវ ច្រកផ្លូវ ដីចំណីទន្លេ បឹង ប្រឡាយ និងប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀត
- សិក្សាលទ្ធភាពនិងរៀបចំគម្រោងកែលម្អតំបន់លំនៅឋានរបស់សហគមន៍ក្រីក្រនិងប្រជាជនរស់នៅក្នុងសំណង់មិនរៀបរយតាមរយៈការអភិវឌ្ឍនៅនឹងកន្លែងឬបំលាស់ទីតាំងថ្មី
- ជំរុញលើកទឹកចិត្តដល់អ្នកវិនិយោគក្នុងការសាងសង់លំនៅឋានមានតម្លៃសមរម្យសម្រាប់ប្រជាជនដែលមានប្រាក់ចំណូលទាប
- ពង្រឹងហេដ្ឋារចនាសម្ព័ន្ធនិងសេវាកម្មដោះស្រាយហានិភ័យសង្គ្រោះបន្ទាន់ សន្តិសុខ សណ្តាប់ធ្នាប់សង្គម និងគ្រោះមហន្តរាយនានាដូចជាគ្រោះអគ្គិភ័យ ទឹកជំនន់ និងបាតុភូតធម្មជាតិផ្សេងៗ
- ជំរុញនិងកែលម្អគ្រប់ស្ថានីយប្រេងឥន្ធនៈឱ្យមានបង្គន់អនាម័យសាធារណៈសម្រាប់កុមារ បុរស ស្ត្រី និងជនមានពិការភាព។

### ៤.៦-យុទ្ធសាស្ត្រការពារបរិស្ថាននិងគ្រប់គ្រងសំណល់

#### ៤.៦.១-ការបែងចែកតំបន់ប្រើប្រាស់ដីសម្រាប់ការការពារបរិស្ថាន

កំណត់និងបែងចែកតំបន់ប្រើប្រាស់ដីសម្រាប់ទុកដាក់សំណល់រឹងតាមគ្រប់ទីតាំងផ្សារ ទីតាំងបុរី តាមភូមិ តាមខ្នងផ្ទះ និងតាមគ្រឹះស្ថានសាធារណៈនិងឯកជនដោយមានការទុកដាក់បានត្រឹមត្រូវតាមបទដ្ឋានកំណត់និងតាមតំបន់ផ្សេងៗរួមមាន៖

- តំបន់តាមដងផ្លូវសាធារណៈ
- តំបន់តាមដងទន្លេសាប បឹងតាមោក បឹងសំរោង ព្រែកព្នៅ ប្រឡាយ
- តំបន់សហគមន៍។

#### ៤.៦.២-វិធានការចាំបាច់ក្នុងការការពារតំបន់សំខាន់ៗ

- ការពារនិងថែរក្សាតំបន់ច្រាំងទន្លេ បឹង ព្រែក ប្រឡាយ សួនជ្រាបទឹក និងដើមឈើតាមទីសាធារណៈ
- ការពារនិងថែរក្សាបណ្តាញទឹកស្អាតនិងបណ្តាញលូស្របតាមបទប្បញ្ញត្តិជាធរមាន
- ការពារនិងថែរក្សាទន្លេសាបដើម្បីធានាប្រព័ន្ធអេកូឡូស៊ីនិងជីវចម្រុះក្នុងទន្លេសាប
- កាត់បន្ថយការបំពុលខ្យល់ដោយសារម៉ាស៊ីនភ្លើងតាមរយៈការផ្គត់ផ្គង់អគ្គិសនីរដ្ឋឱ្យបានច្រើន
- លើកកម្ពស់ការប្រើប្រាស់មធ្យោបាយដឹកជញ្ជូនដែលមិនបំពុលបរិស្ថាន
- បង្កើតគណៈកម្មាធិការត្រួតពិនិត្យបរិស្ថានមានប្រសិទ្ធភាពមួយនៅថ្នាក់ខណ្ឌនិងលើកកម្ពស់ចំណេះដឹងរបស់ប្រជាជនអំពីបរិស្ថាន
- ទប់ស្កាត់ការលុបបឹងនិងប្រព័ន្ធផ្លូវទឹកធម្មជាតិក្នុងការសាងសង់សំណង់ផ្សេងៗ
- រៀបចំឱ្យមានមូលនិធិសម្រាប់ថែទាំបរិស្ថាននិងជំរុញការវិនិយោគរបស់រដ្ឋនិងវិស័យឯកជន។

### ៤.៦.៣- ការគ្រប់គ្រងសំណល់រឹង

- ពង្រឹងយន្តការនិងហេដ្ឋារចនាសម្ព័ន្ធក្នុងការគ្រប់គ្រងសំណល់រឹង
- រៀបចំទីតាំងសម្រាប់ទុកដាក់សំណល់រឹងតាមទីសាធារណៈនិងតាមលំនៅឋានរបស់ប្រជាពលរដ្ឋស្របតាមបទដ្ឋានបច្ចេកទេសនិងស្តង់ដាទីក្រុងស្អាត
- ជំរុញឱ្យមានការអនុវត្តគោលការណ៍កាត់បន្ថយការប្រើប្រាស់ ការប្រើប្រាស់ឡើងវិញ និងការកែច្នៃប្រើប្រាស់ឡើងវិញ
- ជំរុញកំណត់តំបន់គ្មានសំរាមតាមទីតាំងសំខាន់ៗដើម្បីលើកកម្ពស់សោភណភាពទីក្រុងនិងសុខភាពសាធារណៈ។

### ៤.៦.៤- ការគ្រប់គ្រងសំណល់រាវនិងទឹកកខ្វក់

- រៀបចំកែលម្អនិងពង្រីកបន្ថែមប្រព័ន្ធលូទឹកភ្លៀងនិងលូទឹកកខ្វក់ឱ្យដាច់ពីគ្នាដោយតភ្ជាប់ទៅនឹងអាងប្រព្រឹត្តិកម្មទឹកកខ្វក់ស្របតាមស្ថានភាពទីតាំងភូមិសាស្ត្រដើម្បីចម្រោះឱ្យបានស្អាតស្របតាមបទដ្ឋានបច្ចេកទេសអនាម័យមុននឹងបង្ហូរចូលប្រព័ន្ធលូសាធារណៈ
- ណែនាំគ្រប់ម្ចាស់សំណង់លំនៅឋាន ឧស្សាហកម្ម ពាណិជ្ជកម្ម សេវាកម្ម និងសំណង់សាធារណៈត្រូវមានអាងប្រព្រឹត្តិកម្មទឹកកខ្វក់និងអាងបង្គន់អនាម័យត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេសមុនបង្ហូរចូលប្រព័ន្ធលូសាធារណៈ
- មន្ត្រីមានសមត្ថកិច្ចជំនាញសហការជាមួយអាជ្ញាធរមូលដ្ឋានត្រូវត្រួតពិនិត្យជាប្រចាំរាល់ការដ្ឋានសំណង់ក្នុងការធ្វើអាងប្រព្រឹត្តិកម្មទឹកកខ្វក់និងអាងបង្គន់អនាម័យ
- រៀបចំអណ្តូងលូឱ្យមានប្រព័ន្ធចម្រោះជាមុននូវសំណល់ភក់មុននឹងបង្ហូរចូលលូសាធារណៈឱ្យស្របតាមបទដ្ឋានបច្ចេកទេស
- សិក្សានិងរៀបចំឱ្យមានប្រព័ន្ធប្រព្រឹត្តិកម្មទឹកកខ្វក់ឱ្យបានត្រឹមត្រូវតាមអនុក្រឹត្យលេខ២៣៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការគ្រប់គ្រងប្រព័ន្ធលូនិងប្រព័ន្ធប្រព្រឹត្តិកម្មទឹកកខ្វក់
- ផ្សព្វផ្សាយពីគោលការណ៍បរិស្ថាននិងអនាម័យដើម្បីធានាបាននិរន្តរភាពជាតំបន់លំនៅឋានប្រកបដោយសុខុមាលភាព
- ទប់ស្កាត់ការបង្ហូរទឹកកខ្វក់ដែលមានការបំពុលបរិស្ថានឱ្យខានតែបានដែលបណ្តាលមកពីសហគ្រាសនិងអាជីវកម្មផ្សេងៗ។

### ៤.៧- យុទ្ធសាស្ត្របង្ការទប់ស្កាត់គ្រោះមហន្តរាយ

- លើកកម្ពស់ប្រសិទ្ធភាពនៃការអភិរក្សនិងការការពារច្រាំងទន្លេដោយសិក្សានិងរៀបចំផែនការគ្រប់គ្រងការប្រើប្រាស់ច្រាំងទន្លេជារបាំងការពារនិងផ្លូវថ្មើរជើង
- ជំរុញការដាំដើមឈើតាមដីចំណីទន្លេ បឹង ព្រែក ប្រឡាយ ដីចំណីផ្លូវ ក្នុងដីឡូត៍នៃតំបន់លំនៅឋាននិងតាមទីសាធារណៈ
- ពង្រឹងសុវត្ថិភាពផ្លូវក្រវាត់រាជធានីក្នុងខណ្ឌ
- រៀបចំនិងស្តារបឹង ប្រឡាយ និងប្រព័ន្ធលូបង្ហូរទឹកឱ្យស្របតាមបទដ្ឋានបច្ចេកទេស

- រៀបចំឱ្យមានឧបករណ៍ ប្រព័ន្ធការពារ និងប្រឆាំងអគ្គិភ័យ ព្រមទាំងរៀបចំក្បាលបូមពន្លត់អគ្គិភ័យនៅតាមដងផ្លូវសាធារណៈនិងតាមសំណង់អគារនានា
- តម្រូវឱ្យបំពាក់ឧបករណ៍ការពាររន្ទះនៅតាមសំណង់អគារកម្ពស់ខ្ពស់
- ហាមសាងសង់ស្ថានីយប្រេងឥន្ទនៈនៅទីប្រជុំជននិងនៅក្បែរសំណង់ដែលមានឧបនិស្ស័យខាងអប់រំ វប្បធម៌ សុខាភិបាល សាសនា និងបណ្ដុំលំនៅឋាន
- ការសាងសង់សំណង់គ្រប់ប្រភេទត្រូវមានចម្ងាយយ៉ាងតិច៣,៥ម៉ែត្រពីប្រព័ន្ធបញ្ចូនអគ្គិសនីដែលមានតង់ស្យុងខ្ពស់គិតពីខ្សែបញ្ជូនថាមពលដល់ចុងនៃផ្នែកដែលលយចេញនៃអគារ។

### ៤.៨-យុទ្ធសាស្ត្រពង្រឹងអភិបាលកិច្ចល្អ គ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុនៅមូលដ្ឋាន

ការពង្រឹងលើកកម្ពស់សមត្ថភាព ស្ថាប័ន និងធនធានមនុស្សនៅរដ្ឋបាលរាជធានីភ្នំពេញ និងរដ្ឋបាលខណ្ឌព្រែកព្នៅក្នុងការសម្របសម្រួលអនុវត្តប្លង់គោលប្រើប្រាស់ដីនេះ  និងការគ្រប់គ្រងហិរញ្ញវត្ថុនៅមូលដ្ឋានជាកត្តាសំខាន់ចាំបាច់និងជាស្នូលនៃវិស័យទេសចរណ៍ សេដ្ឋកិច្ច អភិវឌ្ឍទីក្រុង និងបរិស្ថានដោយចាំបាច់ត្រូវ៖

- សម្របសម្រួលស្ថាប័នពាក់ព័ន្ធឱ្យចែករំលែកព័ត៌មានអំពីគម្រោងដែលត្រូវអនុវត្តនិងគម្រោងដែលត្រូវស្នើឡើងក្នុងខណ្ឌ
- ពង្រឹងមូលដ្ឋានធនធានមនុស្សទាំងនៅថ្នាក់សង្កាត់និងថ្នាក់ខណ្ឌជាពិសេសសម្រាប់ការគ្រប់គ្រងការអភិវឌ្ឍនិងការត្រួតពិនិត្យគម្រោងសាធារណៈ ការគ្រប់គ្រងដីធ្លី ការប្រមូលពន្ធ។ល។
- ពង្រឹងការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធការប្រើប្រាស់ដីសាធារណៈ ការផ្ដល់លិខិតអនុញ្ញាតសាងសង់  ការផ្ដល់លិខិតអនុញ្ញាតអភិវឌ្ឍដី ការចុះបញ្ជីដីធ្លី  ការចុះបញ្ជីយានយន្ត ការបូមទឹកក្រោមដីរបស់ឯកជន និងការគ្រប់គ្រងបរិស្ថាន
- ពង្រឹងហិរញ្ញវត្ថុនៅមូលដ្ឋានតាមរយៈការប្រមូលចំណូលក្នុងមូលដ្ឋាន ការបែងចែកចំណូលរដ្ឋ និងប្រភពផ្សេងៗទៀតដល់រដ្ឋបាលមូលដ្ឋានសម្រាប់ប្រើប្រាស់ជាប្រយោជន៍សាធារណៈជាពិសេសសម្រាប់ការជួសជុលថែទាំហេដ្ឋារចនាសម្ព័ន្ធសាធារណៈនិងការលើកកម្ពស់សោភណភាពនិងកែលម្អបរិស្ថានក្នុងខណ្ឌ។

## ៥-ផែនការសកម្មភាព

ផ្អែកតាមគោលនយោបាយជាតិស្ដីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា និងប្លង់គោលប្រើប្រាស់ដីខណ្ឌព្រែកព្នៅ រដ្ឋបាលខណ្ឌព្រែកព្នៅនិងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធត្រូវអនុវត្តផែនការសកម្មភាពសំខាន់ៗចាំបាច់ដូចតទៅ៖

### ៥.១-ការរៀបចំបទប្បញ្ញត្តិនគរូបនីយកម្ម

តាមរយៈគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខណ្ឌព្រែកព្នៅ បទប្បញ្ញត្តិនគរូបនីយកម្មដែលត្រូវរៀបចំរួមមាន៖

- ប្លង់បណ្ដាញផ្លូវថ្នល់និងគមនាគមន៍ចម្បងៗ (ឧបសម្ព័ន្ធទី២)
- ប្លង់កំណត់កម្ពស់សំណង់តាមសន្ទស្សន៍ប្រើប្រាស់ដី (ឧបសម្ព័ន្ធទី៤)
- តំបន់ប្រើប្រាស់ដី កម្ពស់សំណង់ និងប្រភេទសំណង់ (ឧបសម្ព័ន្ធទី១៥)។

## ៥.២-ការផ្សព្វផ្សាយ

រៀបចំប្រជុំផ្សព្វផ្សាយប្លង់គោលប្រើប្រាស់ដីខណ្ឌព្រែកព្នៅដល់ក្រុមអ្នកជំនាញ រដ្ឋបាលខណ្ឌ វិនិយោគិន ប្រជាពលរដ្ឋ និងផ្សព្វផ្សាយតាមរយៈវេទិកាសាធារណៈ គេហទំព័រឬតាមបណ្ដាញសង្គមរបស់រដ្ឋបាលខណ្ឌព្រែកព្នៅ។

## ៥.៣-ការអនុវត្តគម្រោងតាមវិស័យ

គម្រោងសំខាន់ៗដែលត្រូវការចាំបាច់សម្រាប់ការអភិវឌ្ឍខណ្ឌ ទេសចរណ៍ ការដឹកជញ្ជូន សិប្បកម្ម កសិកម្ម និងការផ្សព្វផ្សាយផលិតផលក្នុងស្រុក ពាណិជ្ជកម្ម ការគ្រប់គ្រងបរិស្ថាន ការផ្គត់ផ្គង់ទឹកស្អាតនិងធនធានទឹក ការគ្រប់គ្រងសំណល់រឹង ការគ្រប់គ្រងសំណល់រាវ ប្រព័ន្ធលូបង្ហូរទឹកភ្លៀង ការផ្គត់ផ្គង់ថាមពលអគ្គិសនី និងទូរគមនាគមន៍មានដូចខាងក្រោម៖

### ៥.៣.១-ការអភិវឌ្ឍខណ្ឌ

- សិក្សារៀបចំប្លង់លម្អិតនគរូបនីយកម្មតំបន់ពាណិជ្ជកម្ម និងតាមដងផ្លូវ ដើម្បីធ្វើសមាហរណកម្មប្រព័ន្ធនគរូបនីយកម្មក្រុងឱ្យមានសកម្មភាពរស់រវើក
- កែលម្អសោភណភាពនិងហេដ្ឋារចនាសម្ព័ន្ធ
- កសាងសមត្ថភាពមន្ត្រីធ្វើផែនការ និងតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការ
- រៀបចំបញ្ជីសារពើភ័ណ្ឌស្ថាបត្យកម្មប្រវត្តិសាស្ត្រនិងតំបន់ការពារធម្មជាតិដែលមានតម្លៃសម្រាប់ការអភិរក្ស។

### ៥.៣.២-ការអភិវឌ្ឍការដឹកជញ្ជូន

- សាងសង់ស្ពានរំលងថ្មើរជើងសម្រាប់ឆ្លងកាត់ផ្លូវនៅទីតាំងដែលមានចរាចរណ៍មមាញឹក
- កែលម្អបណ្ដាញផ្លូវមេសំខាន់ៗនិងសាងសង់ចំណតរថយន្ត
- រៀបចំចិញ្ចើមផ្លូវ ផ្លូវថ្មើរជើង និងគន្លងផ្លូវទោចក្រយានសម្រាប់សាធារណជននិងជនមានពិការភាព
- កែលម្អនិងសាងសង់ផ្លូវក្រវាត់រាជធានីនិងបណ្ដាញផ្លូវក្នុងខណ្ឌ
- លើកកម្ពស់សណ្ដាប់ធ្នាប់និងយុទ្ធនាការសម្រាប់ការពារសុវត្ថិភាពតាមផ្លូវថ្នល់
- រៀបចំមធ្យោបាយដឹកជញ្ជូនសាធារណៈដែលមិនបំពុលបរិស្ថាន
- ពង្រឹងសមត្ថភាពស្ថាប័នសម្រាប់ថែទាំផ្លូវឱ្យមានប្រសិទ្ធភាព។

### ៥.៣.៣-ការអភិវឌ្ឍទេសចរណ៍

- អភិវឌ្ឍផលិតផល ហេដ្ឋារចនាសម្ព័ន្ធ និងបណ្ដាញទេសចរណ៍
- អភិវឌ្ឍផ្សាររាត្រីតាមបណ្ដោយមហាវិថីឈ្នះឈ្នះ
- លើកកម្ពស់ទេសចរណ៍គុណភាពតាមរយៈភាពជាដៃគូរវាងរដ្ឋនិងឯកជន
- អភិវឌ្ឍនិងលើកកម្ពស់ទេសចរណ៍វប្បធម៌និងទេសចរណ៍ធម្មជាតិតាមដងទន្លេសាប បឹងតាមោក បឹងសំរោង ព្រែកព្នៅ។

### ៥.៣.៤- ការអភិវឌ្ឍពាណិជ្ជកម្មនិងសេវាកម្ម

- រៀបចំសណ្ដាប់ធ្នាប់ឱ្យល្អប្រសើរក្នុងតំបន់ពាណិជ្ជកម្ម
- រៀបចំភ្លើងអគ្គិសនីសម្រាប់ប្រើប្រាស់ក្នុងតំបន់ពាណិជ្ជកម្មជាការបំភ្លឺនិងផ្ដល់ថាមពលគ្រប់គ្រាន់ក្នុងការលើកដាក់ទំនិញ
- រៀបចំឱ្យមានកន្លែងដោះដូរទំនិញក្នុងបរិវេណទីផ្សារឱ្យមានទីតាំងចំណតនិងចំណតបណ្ដោះអាសន្នឱ្យស្របទៅតាមបទដ្ឋានបច្ចេកទេស។

### ៥.៣.៥- ការអភិវឌ្ឍឧស្សាហកម្ម

- អភិវឌ្ឍធនធានមនុស្សនិងបង្កើតមជ្ឈមណ្ឌលផ្សព្វផ្សាយផលិតផលឧស្សាហកម្ម
- អភិវឌ្ឍសហគមន៍ផលិតកម្មនិងចលនាសហគមន៍ភូមិមួយផលិតផលមួយ
- តាំងពិព័រណ៍ផលិតផលឧស្សាហកម្ម
- ពង្រីងទីផ្សារសម្រាប់តាំងនិងលក់ផលិតផលឧស្សាហកម្ម។

### ៥.៣.៦- ការគ្រប់គ្រងបរិស្ថាន

- ជំរុញឱ្យមានការប្រមូលកម្រៃពីការផ្ដល់សេវាសាធារណៈ
- ប្រែក្លាយខណ្ឌព្រែកព្នៅឱ្យក្លាយជាកន្លែងរស់នៅដែលមានលក្ខណៈល្អប្រសើរ
- បង្កើនទីតាំងលម្ហនិងតំបន់បៃតងក្នុងខណ្ឌក៏ដូចជាក្នុងលំនៅឋាននិងអគារឯកជននិងរដ្ឋ។

### ៥.៣.៧- ការគ្រប់គ្រងធនធានទឹកនិងការផ្គត់ផ្គង់ទឹកស្អាត

- ត្រួតពិនិត្យបណ្ដាញផ្គត់ផ្គង់ទឹកស្អាត
- បំពាក់បំពង់បង្ហូរទឹកថ្មីជំនួសបំពង់ទឹកចាស់ៗដែលខូច
- សិក្សាអំពីយុទ្ធសាស្ត្រសមាហរណកម្មនៃការគ្រប់គ្រងធនធានទឹក
- អភិវឌ្ឍបណ្ដាញផ្គត់ផ្គង់ទឹកថ្មីរហូតដល់ឆ្នាំ២០៣៥
- អភិវឌ្ឍស្ថានីយចម្រោះទឹកស្អាតនិងបណ្ដាញចែកចាយទឹកស្អាតរហូតដល់ឆ្នាំ២០៣៥។

### ៥.៣.៨- ការផ្គត់ផ្គង់ថាមពលអគ្គិសនី ទូរគមនាគមន៍ បច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍

- រៀបចំប្រព័ន្ធផ្គត់ផ្គង់ថាមពលអគ្គិសនីដើរដោយពន្លឺព្រះអាទិត្យតាមផ្លូវនិងទីសាធារណៈ
- លើកកម្ពស់ការប្រើប្រាស់ថាមពលអគ្គិសនីដើរដោយពន្លឺព្រះអាទិត្យ
- ដំឡើងនិងជួសជុលបណ្ដាញអគ្គិសនីបំភ្លឺតាមមហាវិថី អនុវិថី វិថី និងទីសាធារណៈ
- ធ្វើផែនការប្រើប្រាស់ថាមពលអគ្គិសនីប្រកបដោយប្រសិទ្ធភាពខ្ពស់
- ជំរុញបង្កើតបទប្បញ្ញត្តិអំពីការផ្គត់ផ្គង់និងការប្រើប្រាស់ថាមពលអគ្គិសនីដើម្បីកាត់បន្ថយបន្ទុកបរិស្ថាន
- អភិវឌ្ឍបណ្ដាញផ្គត់ផ្គង់អគ្គិសនី ទូរគមនាគមន៍ និងប្រព័ន្ធព័ត៌មានវិទ្យាឱ្យបានទូលំទូលាយ មានសណ្ដាប់ធ្នាប់ និងសោភណភាព។

### ៥.៣.៩- ការគ្រប់គ្រងសំណល់រឹង

- រៀបចំប្រព័ន្ធគ្រប់គ្រងសំណល់រឹង
- ពង្រឹងប្រព័ន្ធប្រមូលសំណល់រឹង
- រៀបចំកន្លែងទុកដាក់សំរាមបណ្ដោះអាសន្នដែលមានអនាម័យ។

### ៥.៣.១០- ការគ្រប់គ្រងសំណល់រាវនិងទឹកកខ្វក់

- អភិវឌ្ឍប្រព័ន្ធបង្ហូរទឹកភ្លៀងនិងទឹកកខ្វក់ដោយចែកឱ្យដាច់ពីគ្នាមុនបង្ហូរចូលលូសាធារណៈ
- រៀបចំនិងស្តារឡើងវិញនូវប្រព័ន្ធអាងស្តុកទឹកបណ្ដោះអាសន្នតាមគេហដ្ឋាននិងទីសាធារណៈ
- គ្រប់គ្រងនិងត្រួតពិនិត្យជាប្រចាំនូវសំណល់រាវនិងអាងប្រព្រឹត្តិកម្មទឹកកខ្វក់
- កែលម្អនិងពង្រីកបន្ថែមស្ថានីយនិងអនុស្ថានីយបូមទឹកកខ្វក់។

## ៥.៤-ការអនុវត្តគម្រោងរយៈពេលខ្លី មធ្យម និងវែង

ផែនការសកម្មភាពសម្រាប់ការអនុវត្តរយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែងមានដូចខាងក្រោម៖

### ៥.៤.១- ការអនុវត្តគម្រោងរយៈពេលខ្លី

- កែលម្អហេដ្ឋារចនាសម្ព័ន្ធរូបវន្តក្នុងគម្រោងអាទិភាពនៃការអភិវឌ្ឍ ការអភិរក្ស និងការសាងសង់
- រៀបចំផែនការប្រើប្រាស់ដីដោយកំណត់បទប្បញ្ញត្តិប្រើប្រាស់ដី
- សិក្សាការដាក់លេខផ្លូវនិងលេខផ្ទះ។

### ៥.៤.២- ការអនុវត្តគម្រោងរយៈពេលមធ្យម

- រៀបចំគំនូរប្លង់គំរូសម្រាប់សាងសង់ច្រាំងទន្លេ
- រៀបចំគំនូរប្លង់គំរូបណ្ដាញប្រឡាយ ប្លង់គំរូអាងប្រព្រឹត្តិកម្មទឹកកខ្វក់សម្រាប់សំណង់ឧស្សាហកម្មឬសំណង់ដែលមានសំណល់សរីរាង្គឬជាតិពុល និងហេដ្ឋារចនាសម្ព័ន្ធសាធារណៈ
- រៀបចំគំនូរប្លង់គំរូនិងបទដ្ឋានអាងបង្គន់អនាម័យ
- ផែនការសកម្មភាពតាមលំដាប់អាទិភាពបន្ទាប់និងគម្រោងអាទិភាពនៃការអភិវឌ្ឍ ការអភិរក្ស និងការសាងសង់។

### ៥.៤.៣- ការអនុវត្តគម្រោងរយៈពេលវែង

- ចំពោះសំណង់បណ្ដោះអាសន្ន និងការតាំងទីលំនៅត្រូវបន្តដោះស្រាយតាមសារាចរលេខ០៣ សរ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១០ ស្តីពីការដោះស្រាយសំណង់បណ្ដោះអាសន្នលើដីរបស់រដ្ឋដែលត្រូវបានទន្ទ្រានកាន់កាប់ដោយខុសច្បាប់តាមរាជធានី ទីក្រុង និងទីប្រជុំជន
- សហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធដើម្បីដោះស្រាយរកដីជូនប្រជាពលរដ្ឋដែលរស់នៅក្នុងសំណង់បណ្ដោះអាសន្ន
- ចំពោះគម្រោងចាំបាច់ត្រូវធ្វើបច្ចុប្បន្នភាពហេដ្ឋារចនាសម្ព័ន្ធសមស្របជាមុនដូចជាបណ្ដាញផ្លូវនិងប្រព័ន្ធលូបង្ហូរទឹកកខ្វក់និងទឹកភ្លៀង និងប្លង់បែងចែកតំបន់ប្រើប្រាស់ដីផ្សេងៗស្របតាមស្ថានភាពភូមិសាស្ត្រជាក់ស្តែងដោយអនុលោមតាមបទប្បញ្ញត្តិនគរូបនីយកម្មនិងគោលការណ៍អភិវឌ្ឍន៍បៃតងសំដៅធ្វើឱ្យខណ្ឌក្លាយជាតំបន់រស់នៅប្រកបដោយសុខុមាលភាព គុណភាព វឌ្ឍនភាព និងចីរភាព។

### ៥.៥-គម្រោងអាទិភាព

- កែលម្អសោភណភាពនិងហេដ្ឋារចនាសម្ព័ន្ធបរវត្ត
- កសាងសមត្ថភាពមន្ត្រីធ្វើផែនការ
- លើកកម្ពស់ការយល់ដឹងអំពីបរិស្ថាន
- លើកកម្ពស់គុណភាពទេសចរណ៍តាមរយៈភាពជាដៃគូរវាងរដ្ឋនិងឯកជន
- អភិវឌ្ឍធនធានមនុស្សនិងបង្កើតមជ្ឈមណ្ឌលផ្សព្វផ្សាយផលិតផលសិប្បកម្ម
- ស្តារនិងជួសជុលបណ្តាញផ្លូវ
- បំពាក់បំពង់បង្ហូរទឹកថ្មីជំនួសបំពង់ទឹកចាស់ៗដែលខូច
- សិក្សាយុទ្ធសាស្ត្រសមាហរណកម្មនៃប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ
- អភិវឌ្ឍប្រព័ន្ធលូបង្ហូរទឹកភ្លៀងនិងប្រព័ន្ធគ្រប់គ្រងសំណល់រឹងនិងរាវ។

## ៦-ធនធានហិរញ្ញវត្ថុ

ប្រភពធនធានហិរញ្ញវត្ថុសម្រាប់ការអនុវត្តប្លង់គោលប្រើប្រាស់ដីខណ្ឌព្រែកព្នៅមានជាអាទិ៍៖

- ថវិកាជាតិ
- ថវិកាអភិវឌ្ឍន៍និងវិនិយោគដោយវិស័យឯកជន
- ថវិកាវិនិយោគរវាងរដ្ឋនិងឯកជន
- ថវិកាហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍និងកិច្ចសហប្រតិបត្តិការអន្តរជាតិ
- ថវិកាពីការចូលរួមរបស់ប្រជាពលរដ្ឋ សហគមន៍ និងសប្បុរសជន។

## ៧-ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃ

### ៧.១-យន្តការ

យន្តការថ្នាក់ជាតិដើម្បីត្រួតពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្តប្លង់គោលប្រើប្រាស់ដីខណ្ឌព្រែកព្នៅ ចក្ខុវិស័យឆ្នាំ២០៣៥ មាន៖ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ និងក្រសួង ស្ថាប័នតាមវិស័យរបស់រដ្ឋ។

យន្តការថ្នាក់ក្រោមជាតិសម្រាប់អនុវត្តប្លង់គោលប្រើប្រាស់ដីខណ្ឌព្រែកព្នៅ ចក្ខុវិស័យឆ្នាំ២០៣៥ មាន៖ រដ្ឋបាលរាជធានីភ្នំពេញ រដ្ឋបាលខណ្ឌព្រែកព្នៅ គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មរាជធានីភ្នំពេញ គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខណ្ឌព្រែកព្នៅ មន្ទីរ អង្គភាពពាក់ព័ន្ធ និងអាជ្ញាធរសង្កាត់និងភូមិ។

### ៧.២-គោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃការអនុវត្តប្លង់គោលប្រើប្រាស់ដីខណ្ឌព្រែកព្នៅ ចក្ខុវិស័យឆ្នាំ២០៣៥ ត្រូវបានធ្វើឡើងដោយផ្អែកទៅលើគោលនយោបាយ ច្បាប់ និងក្របខណ្ឌគតិយុត្តមានជាអាទិ៍គោលនយោបាយ ដីធ្លី "សៀវភៅសដីធ្លី" គោលនយោបាយជាតិស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា គោលនយោបាយជាតិស្តីពីលំនៅឋាន ច្បាប់ភូមិបាល ច្បាប់ស្តីពីសំណង់ ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ ច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌

ច្បាប់ស្តីពីទេសចរណ៍ ច្បាប់ស្តីពីជលផល ច្បាប់ស្តីពីផ្លូវថ្នល់ ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ អនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អនុក្រឹត្យស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន អនុក្រឹត្យស្តីពីនីតិវិធីនៃការធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ អនុក្រឹត្យស្តីពីការដាក់ឱ្យអនុវត្តប្លង់គោលប្រើប្រាស់ដីរាជធានីភ្នំពេញ ចក្ខុវិស័យឆ្នាំ២០៣៥ សេចក្តីសម្រេចស្តីពីនីតិវិធីលម្អិតនៃការរៀបចំប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

### ៧.៣-ភារកិច្ច នីតិវិធី និងគោលការណ៍

រដ្ឋបាលខណ្ឌព្រែកព្នៅដោយមានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលជាសេនាធិការមានភារកិច្ចៈ

- ទទួលខុសត្រូវក្នុងការរៀបចំផែនការសកម្មភាពលម្អិតសម្រាប់ការអនុវត្តប្លង់គោលប្រើប្រាស់ដីខណ្ឌព្រែកព្នៅដោយមានការចូលរួមពីក្រសួង ស្ថាប័ន មន្ទីរ អង្គភាព វិស័យឯកជន ដៃគូអភិវឌ្ឍន៍ និងសហគមន៍មូលដ្ឋាន។ ផែនការសកម្មភាពលម្អិតខាងលើត្រូវកំណត់នូវគោលបំណង គោលដៅ សកម្មភាព ពេលវេលា ធនធានហិរញ្ញវត្ថុ ការទទួលខុសត្រូវ និងសូចនាករសំខាន់ៗសម្រាប់ការត្រួតពិនិត្យ និងការវាយតម្លៃ ព្រមទាំងត្រូវមានសង្គតិភាពជាមួយផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍៥ឆ្នាំ កម្មវិធីវិនិយោគ៣ឆ្នាំរំកិល ប្លង់គោលប្រើប្រាស់ដីថ្នាក់ខណ្ឌ ផែនការប្រើប្រាស់ដីថ្នាក់សង្កាត់ និងប្លង់លម្អិតនគរូបនីយកម្មថ្នាក់សង្កាត់
- ត្រូវធ្វើបច្ចុប្បន្នភាពប្លង់គោលប្រើប្រាស់ដីខណ្ឌព្រែកព្នៅក្នុងរយៈពេល៥ឆ្នាំម្តងស្របតាមគោលការណ៍និងនីតិវិធីដែលបានកំណត់ តាមពេលវេលា និងតម្រូវការចាំបាច់ជាក់ស្តែងសំដៅបម្រើផលប្រយោជន៍សាធារណៈឬផលប្រយោជន៍ជាតិ
- ត្រូវធ្វើរបាយការណ៍ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំនៃការអនុវត្តប្លង់គោលប្រើប្រាស់ដីខណ្ឌព្រែកព្នៅជូនគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មរាជធានីភ្នំពេញ រដ្ឋបាលរាជធានីភ្នំពេញ ក្រសួងមហាផ្ទៃ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិដើម្បីធ្វើការបូកសរុបនិងធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាល។

គោលការណ៍នៃការត្រួតពិនិត្យនិងវាយតម្លៃត្រូវផ្អែកលើសូចនាករនៃការរៀបចំដែនដីនិងនគរូបនីយកម្ម និងសូចនាករតាមវិស័យ ដើម្បីបញ្ជាក់អំពីប្រសិទ្ធភាពនៃការអនុវត្តប្លង់គោលប្រើប្រាស់ដីខណ្ឌព្រែកព្នៅក្នុងការអភិវឌ្ឍសង្គមនិងសេដ្ឋកិច្ចប្រកបដោយចីរភាព។

### ៨-សេចក្តីសន្និដ្ឋាន

ព្រះរាជាណាចក្រកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ទទួលបាននូវសុខសន្តិភាពពេញលេញ ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម ព្រមទាំងការអភិវឌ្ឍរីកចម្រើនលើគ្រប់វិស័យតាមរយៈការអនុវត្តគោលនយោបាយឈ្នះ-ឈ្នះនិងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា។

ប្លង់គោលប្រើប្រាស់ដីខណ្ឌព្រែកព្នៅបានកំណត់នូវគោលដៅអំពីនគរូបនីយកម្មនិងធ្វើសមាហរណកម្មជាមួយបណ្ដាខណ្ឌជុំវិញដោយឆ្លុះបញ្ចាំងនូវកត្តាសំខាន់ៗចំនួន៥ គឺ៖ ទី១)មុខងារសមស្របសម្រាប់ការស្នាក់នៅ ការផ្ដល់ការងារ ការសិក្សា ការផ្ដល់សេវាកម្ម ការធ្វើចរាចរណ៍ និងកន្លែងលម្ហែកម្សាន្តប្រកបដោយសុខភាព សោភណភាព សុវត្ថិភាព សណ្ដាប់ធ្នាប់ និងភាពងាយស្រួល ទី២)លើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច ការការពារបរិស្ថាន សន្តិសុខស្បៀង និងការថែរក្សាសម្បត្តិវប្បធម៌ ទី៣)លើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃការកែលម្អ ការអភិវឌ្ឍ និងការការពារហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ទី៤)តុល្យភាពនៃការអភិវឌ្ឍនិងការអភិរក្ស ព្រមទាំងទំនាក់ទំនងរវាងតំបន់គម្រោងជាមួយតំបន់ជុំវិញដោយផ្អែកលើកត្តាភូមិសាស្ត្រនិងលក្ខណៈពិសេសនៃតំបន់នីមួយៗ និងទី៥)តម្រង់ទិសច្បាស់លាស់ក្នុងអំឡុងពេលអភិវឌ្ឍប្រកបដោយគុណភាព ប្រសិទ្ធភាព ចីរភាព និងសមធមិនគរូបនីយកម្ម។ បន្ថែមលើនេះប្លង់គោលប្រើប្រាស់ដីខណ្ឌព្រែកព្នៅជាមូលដ្ឋានសម្រាប់បន្តសិក្សាផែនការប្រើប្រាស់ដីនិងប្លង់លម្អិតនគរូបនីយកម្មថ្នាក់សង្កាត់ដើម្បីរួមចំណែកសម្រេចចក្ខុវិស័យកម្ពុជាទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០។

ថ្ងៃ សុក្រ ១២ រោច ខែ មិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០២១

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងជា**
**ប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ**

**ជា សុផារ៉ា**

**អនុសាសន៍**

ដើម្បីឱ្យប្លង់គោលប្រើប្រាស់ដីខណ្ឌព្រែកព្នៅ ចក្ខុវិស័យឆ្នាំ២០៣៥ អនុវត្តដោយជោគជ័យនិងមានប្រសិទ្ធភាព រដ្ឋបាលរាជធានីភ្នំពេញនិងក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធសូមយកចិត្តទុកដាក់៖

១) កំណត់ឱ្យបានច្បាស់លាស់នូវបញ្ហានិងបរិស្ថាននៃខណ្ឌ ក្នុងន័យទប់ស្កាត់លំហូរភ្ញៀវទេសចរចេញពីខណ្ឌនៅពេលមានការប្រកួតប្រជែងខ្ពស់ពីតំបន់ទេសចរណ៍ផ្សេងៗទៀត។

២) គ្រប់គ្រងធនធានទឹកសម្រាប់ភ្ញៀវទេសចរនិងប្រជាជនមូលដ្ឋាន និងលម្ហសាធារណៈនិងផ្ទៃបៃតងសម្រាប់សាធារណជននិងទេសចរ។

៣) សម្របសម្រួលការធ្វើផែនការប្រើប្រាស់ដីខណ្ឌព្រែកព្នៅដោយមានការចូលរួមពីប្រជាពលរដ្ឋមូលដ្ឋានដើម្បីធ្វើការគ្រប់គ្រងដីធ្លីប្រកបដោយប្រសិទ្ធភាព។

៤) ពិនិត្យវាយតម្លៃនិងកែលម្អប្លង់គោលប្រើប្រាស់ដីខណ្ឌព្រែកព្នៅរៀងរាល់៥(ប្រាំ)ឆ្នាំម្តងដើម្បីឆ្លើយតបទៅនឹងកាលៈទេសៈប្រែប្រួលនិងតម្រូវការសង្គម-សេដ្ឋកិច្ចជាក់ស្តែង។

៥) កសាងសមត្ថភាពមន្ត្រីជំនាញនៅថ្នាក់រាជធានី ខណ្ឌ និងលើកកម្ពស់ការចែករំលែកព័ត៌មានអំពីគម្រោងអភិវឌ្ឍនានារវាងមន្ទីរ អង្គភាព និងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធនៅក្នុងរាជធានីតាមរយៈគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មរាជធានីភ្នំពេញ។

៦) លើកកម្ពស់សមត្ថភាពបច្ចេកទេសសម្រាប់ការត្រួតពិនិត្យនិងថែរក្សាបរិស្ថានប្រកបដោយប្រសិទ្ធភាពដោយសហការជាមួយសមត្ថកិច្ចពាក់ព័ន្ធក្នុងរាជធានី។ រដ្ឋបាលរាជធានីភ្នំពេញត្រូវរៀបចំកញ្ចប់ថវិកាដល់អាជ្ញាធរខណ្ឌព្រែកព្នៅសម្រាប់អនុវត្តផែនការជួសជុលនិងថែទាំបរិក្ខារសាធារណៈដូចជាផ្លូវ សួនច្បារ ការប្រមូលសំណល់រឹងនិងរាវ ប្រព័ន្ធបង្ហូរទឹកភ្លៀងក្នុងខណ្ឌ។ល។

៧) ត្រូវយកផែនការរូបវន្តជាមូលដ្ឋានបង្អែកសម្រាប់ការអភិវឌ្ឍដី ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ការសាងសង់គ្រប់ប្រភេទ និងការអភិរក្សក្នុងខណ្ឌ ព្រមទាំងការធ្វើសមាហរណកម្មជុំវិញដើម្បីធ្វើឱ្យការប្រើប្រាស់ដីបានត្រឹមត្រូវ ចំទិសដៅ ប្រសិទ្ធភាព ចីរភាព តុល្យភាព និងសមធម៌។

៨) លើកកម្ពស់ប្រសិទ្ធភាពការផ្តល់សេវាសាធារណៈស្របតាមអភិក្រមរបស់រាជរដ្ឋាភិបាលគឺធ្វើឱ្យបានធ្វើឱ្យលឿន ធ្វើឱ្យមានគុណភាព និងធ្វើឱ្យមានតម្លាភាព។

៩) គ្រប់ក្រសួងស្ថាប័នមានសមត្ថកិច្ចនិងភាគីពាក់ព័ន្ធជួយគាំទ្រដល់រដ្ឋបាលខណ្ឌព្រែកព្នៅក្នុងការអនុវត្តប្លង់គោលប្រើប្រាស់ដីខណ្ឌព្រែកព្នៅដែលបានសម្រេចដាក់ឱ្យប្រើប្រាស់រួចដើម្បីការអភិវឌ្ឍប្រកបដោយចីរភាពនិងបរិយាបន្ន។

៚៚៙៚៚

**សទ្ទានុក្រម**

**ការអភិវឌ្ឍដី** សំដៅដល់ការប្តូរប្រភេទនៃការប្រើប្រាស់ដីទៅជាប្រភេទមួយផ្សេងទៀតតាមរយៈការបង្រួមក្បាលដី ការបំបែកក្បាលដី ការកែទម្រង់ដី និងការបង្កើនដង់ស៊ីតេនៃការប្រើប្រាស់ដីសម្រាប់គោលដៅនៃការសាងសង់លំនៅឋាន ពាណិជ្ជកម្ម សេវាកម្ម ឧស្សាហកម្ម។ល។ ដោយធានាបាននូវការរៀបចំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ លម្ហសាធារណៈ និងសេវាសាធារណៈស្របតាមបទប្បញ្ញត្តិនៃការប្រើប្រាស់ដី។

**កន្លែងផ្លូវប្រសព្វ** សំដៅដល់កន្លែងប្រសព្វនៃផ្លូវពីរឬច្រើនដែលមានផ្ទៃរាបតែមួយនិងមិនកំណត់មុំនៃអ័ក្សរបស់ទ្រូងផ្លូវឡើយ។ កន្លែងផ្លូវប្រសព្វអាចមានរាងជា +, X, Y, T ឬរង្វង់មូលជាដើម។

**កន្លែងផ្លូវប្រសព្វក្នុងលម្ហ** សំដៅដល់កន្លែងប្រសព្វនៃផ្លូវពីរឬច្រើនដែលមានកម្រិតកម្ពស់ផ្ទៃខុសគ្នានិងមិនកំណត់មុំនៃអ័ក្សរបស់ទ្រូងផ្លូវឡើយ។ ផ្លូវប្រសព្វក្នុងលម្ហអាចមានរាងជា +, X, និង *។

**ការកែសម្រួលក្បាលដី** សំដៅដល់ការរៀបចំក្បាលដីឡើងវិញដើម្បីធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធសាធារណៈ លម្ហសាធារណៈ និងសេវាសាធារណៈដោយមានការចូលរួម ព្រមទាំងបង្កើនលទ្ធភាពនិងប្រសិទ្ធភាពនៃការប្រើប្រាស់ដីស្របតាមបទប្បញ្ញត្តិជាធរមាន។

**ការត្រួតពិនិត្យការអភិវឌ្ឍ** សំដៅដល់ការត្រួតពិនិត្យការអនុវត្តស្របតាមប្លង់គោលប្រើប្រាស់ដី ផែនការប្រើប្រាស់ដី និងស្របតាមបទប្បញ្ញត្តិជាធរមាន។

**ការបង្រួមក្បាលដី** សំដៅដល់ការបញ្ចូលក្បាលដីច្រើនដែលជាប់គ្នាឱ្យក្លាយទៅជាក្បាលដីតែមួយដើម្បីធ្វើផែនការអភិវឌ្ឍទីក្រុងសម្រាប់ធ្វើសមាហរណកម្មនិងធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធសាធារណៈនិងសេវាសាធារណៈសំដៅធានាចីរភាព សមធម៌ តុល្យភាព សុខភាព និងភាពងាយស្រួលនៃទីក្រុង។

**ការប្តូរប្រភេទនៃការប្រើប្រាស់ដី** សំដៅដល់ការផ្លាស់ប្តូរការប្រើប្រាស់ដីពីប្រភេទមួយទៅប្រភេទផ្សេងទៀតស្របតាមបទប្បញ្ញត្តិជាធរមាន។

**ការបំបែកក្បាលដី** សំដៅដល់ការបំបែកក្បាលដីតែមួយទៅជាក្បាលដីច្រើនសម្រាប់ការសាងសង់លំនៅឋាន ពាណិជ្ជកម្ម ឧស្សាហកម្ម។ល។ ដោយធានាបាននូវការរៀបចំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ លម្ហសាធារណៈ និងសេវាសាធារណៈស្របតាមបទប្បញ្ញត្តិនៃការប្រើប្រាស់ដី។

**ការរៀបចំដែនដី** សំដៅដល់ការកំណត់ការប្រើប្រាស់ដីក្នុងកម្រិតម៉ាក្រូដោយយោងលើលក្ខខណ្ឌភូមិសាស្ត្រនិងសក្តានុពលនៃតំបន់នីមួយៗដើម្បីធានាការការពារ ការអភិរក្ស និងការអភិវឌ្ឍប្រកបដោយចីរភាព សមធម៌ និងប្រសិទ្ធភាព។ ការរៀបចំដែនដីធ្វើឡើងដើម្បីគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ច សង្គម ធានាសន្តិសុខស្បៀង កិច្ចការពារជាតិ លំនឹងធម្មជាតិ និងតម្រង់ទិសដល់ការអភិវឌ្ឍជាតិឱ្យមានតុល្យភាពនៅទូទាំងប្រទេសលើផ្នែកហេដ្ឋារចនាសម្ព័ន្ធរូបវន្ត សង្គម សេដ្ឋកិច្ច និងបរិស្ថាន ព្រមទាំងការធ្វើសមាហរណកម្មនៅក្នុងប្រទេស ក្របខណ្ឌតំបន់ និងអន្តរជាតិ។

**ខ្សែបន្ទាត់ព្រំដីចំណីផ្លូវថ្នល់** សំដៅដល់ខ្សែបន្ទាត់នៃបណ្តាចំណុចព្រំដីចំណីផ្លូវដែលមានចម្ងាយកំណត់ពីខ្សែបន្ទាត់ផ្ចិតនៃផ្លូវថ្នល់។

**គន្លងផ្លូវ** សំដៅដល់ចំណែកមួយនៃទ្រូងផ្លូវខណ្ឌដោយគំនូសឬបរិក្ខារបែងចំណែកផ្លូវតាមបណ្តោយទ្រូងផ្លូវដែលមានទទឹងគ្រប់គ្រាន់អាចឱ្យយានជំនិះគ្រប់ប្រភេទធ្វើចរាចរណ៍បានមួយជួរ។

**ចិញ្ចើមផ្លូវ** សំដៅដល់ផ្នែកសងខាងនៃទ្រូងផ្លូវនៅក្នុងទីប្រជុំជនដែលរៀបចំទុកសម្រាប់ថ្មើរជើងធ្វើដំណើរ ដាំដើមឈើ និងបង្កប់បរិក្ខារបម្រើផលប្រយោជន៍សេវាសាធារណៈ។

**ជាយផ្លូវ** សំដៅដល់ផ្នែកសងខាងនៃទ្រូងផ្លូវនៅក្រៅទីប្រជុំជនដែលយានជំនិះអាចចតបានក្នុងករណីចាំបាច់។

**ដង់ស៊ីតេប្រជាជន** សំដៅដល់អនុបាតរវាងចំនួនប្រជាជននិងផ្ទៃក្រឡាដីក្នុងវិសាលភាពជាក់លាក់ណាមួយ។

**ដីចំណីផ្លូវថ្នល់** សំដៅដល់ដីនៅសងខាងខ្សែបន្ទាត់ផ្ចិតនៃផ្លូវថ្នល់និងទំហំចំណីផ្លូវថ្នល់ទុកបម្រុងសម្រាប់ការគ្រប់គ្រង ការអភិវឌ្ឍ ការការពារផ្លូវថ្នល់ ធានាសុវត្ថិភាពចរាចរណ៍ និងការប្រើប្រាស់ការងារហេដ្ឋារចនាសម្ព័ន្ធរូបវន្តផ្សេងទៀតដែលកំណត់ដោយខ្សែបន្ទាត់ព្រំដីចំណីផ្លូវ។

**តំបន់កសិកម្ម** សំដៅដល់តំបន់ដែលមានមុខងារចម្បងសម្រាប់វិស័យកសិកម្មដូចជាវាលស្រែ ចម្ការសួនបន្លែ កសិដ្ឋានចិញ្ចឹមសត្វ ថ្នាលបណ្តុះកូនឈើ កន្លែងចិញ្ចឹមត្រី បង្គារ ក្តាម សិប្បកម្មបម្រើដល់កសិកម្ម។ល។ តំបន់នេះអាចសាងសង់លំនៅឋានរបស់កសិករ។ តំបន់នេះមានផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងដីឡូត៍និងមានសន្ទស្សន៍ប្រើប្រាស់ដីកំណត់ដោយអនុក្រឹត្យ។

**តំបន់ការពារ** សំដៅដល់តំបន់ធម្មជាតិនិងទស្សនីយភាពដែលត្រូវការពារដើម្បីបម្រើឱ្យវិស័យបរិស្ថាន សេដ្ឋកិច្ច សង្គមកិច្ច វិទ្យាសាស្ត្រ ការអប់រំ និងការកម្សាន្តដូចជាឆ្នេរសមុទ្រ ចំណីទន្លេ ភ្នំ ឧទ្យានជាតិ តំបន់ដីសើម តំបន់ជីវធម្មជាតិ។ល។

**តំបន់ចម្រុះ** សំដៅដល់តំបន់ដែលអាចប្រើប្រាស់ពហុមុខងារសម្រាប់លំនៅឋាន ពាណិជ្ជកម្ម និងសេវាកម្មដោយធានាបានបរិស្ថានរស់នៅដែលមានផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងដីឡូត៍ និងមានសន្ទស្សន៍ប្រើប្រាស់ដីកំណត់ដោយអនុក្រឹត្យ។

**តំបន់ដឹកជញ្ជូន** សំដៅដល់តំបន់ដែលមានមុខងារចម្បងសម្រាប់សាងសង់អគារហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មបម្រើដល់វិស័យដឹកជញ្ជូននិងគមនាគមន៍មានជាអាទិ៍ស្ថានីយរថភ្លើង ព្រលានយន្តហោះ ស្ថានីយរថយន្ត កំពង់ចម្លង កំពង់ផែ កំពង់ផែ ផែស្ងួត ឃ្លាំង មជ្ឈមណ្ឌលចែកចាយទំនិញនិងភស្តុភារកម្ម និងមជ្ឈមណ្ឌលសូរគមនាគមន៍។ តំបន់នេះមានផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងដីឡូត៍ និងមានសន្ទស្សន៍ប្រើប្រាស់ដីកំណត់ដោយអនុក្រឹត្យ។

**តំបន់ទេសចរណ៍** សំដៅដល់តំបន់សម្រាប់សាងសង់អគារបម្រើដល់វិស័យទេសចរណ៍និងកម្សាន្ត រួមមានសណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន កន្លែងកម្សាន្ត។ល។

**តំបន់ធនធានទឹក** សំដៅដល់តំបន់ផ្ទៃទឹកនិងប្រភពទឹកដែលត្រូវថែរក្សានិងការពារដូចជាសមុទ្រ ទន្លេ ព្រែក ស្ទឹង អូរ ប្រឡាយ បឹង ទំនប់ សំណង់ធារាសាស្ត្រ។ល។

**តំបន់ពាណិជ្ជកម្ម** សំដៅដល់តំបន់ដែលមានមុខងារសម្រាប់សាងសង់សំណង់ដែលបម្រើដល់វិស័យពាណិជ្ជកម្ម ធុរកិច្ច និងសេវាកម្មនានាដូចជាអគារការិយាល័យ ធនាគារ រោងកុន រោងល្ខោន ភោជនីយដ្ឋាន សណ្ឋាគារ ហាងលក់ដូរ ទីផ្សារ និងដេប៉ូចែកចាយទំនិញ ។ល។ ដែលមានផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងដីឡូត៍ និងមានសន្ទស្សន៍ប្រើប្រាស់ដីកំណត់ដោយអនុក្រឹត្យ។

**តំបន់ពាណិជ្ជកម្មចម្រុះ** សំដៅដល់តំបន់ដែលមានមុខងារពាណិជ្ជកម្មសម្រាប់បម្រើដល់លំនៅឋាននិងការស្នាក់នៅដូចជាហាងលក់ដូរនិងទីផ្សារតូចៗដែលលក់ដូរទំនិញនិងសេវាកម្មដើម្បីផ្គត់ផ្គង់និងគាំទ្រដល់ការរស់នៅរបស់ប្រជាពលរដ្ឋមូលដ្ឋានប្រចាំថ្ងៃដែលមានផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងដីឡូត៍ និងមានសន្ទស្សន៍ប្រើប្រាស់ដីកំណត់ដោយអនុក្រឹត្យ។

**តំបន់ព្រៃឈើ** សំដៅដល់តំបន់ផ្ទៃព្រៃឈើនិងគម្របព្រៃឈើដែលត្រូវការពារ ថែរក្សា និងដាំបន្ថែមដូចជាព្រៃស្រោង ព្រៃរបោះ ព្រៃការពារ ព្រៃអភិរក្ស ព្រៃលិចទឹក។ល។

**តំបន់រដ្ឋបាលនិងសេវាសាធារណៈ** សំដៅដល់តំបន់ដែលមានមុខងារចម្បងសម្រាប់សាងសង់សំណង់ដែលបម្រើដល់វិស័យរដ្ឋបាលនិងសេវាសាធារណៈដូចជាទីស្តីការក្រសួង ស្ថាប័ន មន្ទីរ អង្គភាព សាលារាជធានី សាលាខេត្ត សាលាក្រុង សាលាស្រុក ខណ្ឌ សាលាឃុំ សង្កាត់ សាលារៀន មន្ទីរពេទ្យ បណ្ណាល័យ មណ្ឌលសុខភាព ប្រៃសណីយ៍។ល។ តំបន់នេះមានផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងដីឡូត៍ និងមានសន្ទស្សន៍ប្រើប្រាស់ដីកំណត់ដោយអនុក្រឹត្យ។

**តំបន់លំនៅឋានកម្ពស់ខ្ពស់** សំដៅដល់តំបន់ដែលមានមុខងារសម្រាប់សាងសង់អគារលំនៅឋានដែលមានកម្ពស់ខ្ពស់ដូចជាអគារស្នាក់នៅ អគារលំនៅឋានសហកម្មសិទ្ធិដែលមានផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងដីឡូត៍ និងមានសន្ទស្សន៍ប្រើប្រាស់ដីកំណត់ដោយអនុក្រឹត្យ។

**តំបន់លំនៅឋានកម្ពស់មធ្យម** សំដៅដល់តំបន់ដែលមានមុខងារសម្រាប់សាងសង់អគារលំនៅឋានដែលមានកម្ពស់មធ្យមដូចជាភូមិគ្រឹះទោល ភូមិគ្រឹះភ្លោះ ផ្ទះល្វែង ផ្ទះល្វែងភ្លោះ អគារស្នាក់នៅ អគារលំនៅឋានសហកម្មសិទ្ធិដែលមានផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងដីឡូត៍ និងមានសន្ទស្សន៍ប្រើប្រាស់ដីកំណត់ដោយអនុក្រឹត្យ។

**តំបន់លំនៅឋានចម្រុះ** សំដៅដល់តំបន់ដែលមានមុខងារសម្រាប់សាងសង់អគារលំនៅឋានច្រើនប្រភេទដូចជាលំនៅឋានជាប់គ្នា លំនៅឋានពាក់កណ្តាលជាប់គ្នា លំនៅឋានដាច់ពីគ្នា អគារស្នាក់នៅ អគារលំនៅឋានសហកម្មសិទ្ធិដែលមានផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងដីឡូត៍ និងមានសន្ទស្សន៍ប្រើប្រាស់ដីកំណត់ដោយអនុក្រឹត្យ។

| | |
|---|---|
| **តំបន់លំនៅឋានជាប់គ្នាកម្ពស់ទាប** | សំដៅដល់តំបន់ដែលមានមុខងារសម្រាប់សាងសង់អគារលំនៅឋានដែលមានជញ្ជាំងជាប់គ្នាដែលមានកម្ពស់ទាបដូចជាផ្ទះល្វែង ផ្ទះល្វែងភ្លោះ អគារស្នាក់នៅ អគារលំនៅឋានសហកម្មសិទ្ធិដែលមានផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងដីឡូត៍ និងមានសន្ទស្សន៍ប្រើប្រាស់ដីកំណត់ដោយអនុក្រឹត្យ។ |
| **តំបន់លំនៅឋានដាច់ពីគ្នាកម្ពស់ទាប** | សំដៅដល់តំបន់ដែលមានមុខងារសម្រាប់សាងសង់អគារលំនៅឋានដាច់ពីគ្នាឬជាប់គ្នាមួយចំហៀងដែលមានកម្ពស់ទាបដូចជាភូមិគ្រឹះទោល ភូមិគ្រឹះភ្លោះ ផ្ទះក្នុងដីឡូត៍ដែលមានធ្លាគម្លាតជុំវិញ អគារស្នាក់នៅ អគារលំនៅឋានសហកម្មសិទ្ធិដែលមានផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងដីឡូត៍ និងមានសន្ទស្សន៍ប្រើប្រាស់ដីកំណត់ដោយអនុក្រឹត្យ។ |
| **តំបន់លម្ហសាធារណៈនិងផ្ទៃបៃតង** | សំដៅដល់តំបន់ដែលមានមុខងារសម្រាប់បម្រើដល់ការសម្រាក ការលម្ហែ ការកម្សាន្តនិងពិធីសាធារណៈនានាដូចជាឧទ្យាន សួនច្បារ សួនសត្វ សួនកុមារ កន្លែងក្មេងលេង សួនយុវជន សួនមនុស្សចាស់។ល។ ដែលត្រូវបានរៀបចំនិងសាងសង់សម្រាប់បម្រើដល់សាធារណជន។ តំបន់នេះមានផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងដីឡូត៍ និងមានសន្ទស្សន៍ប្រើប្រាស់ដីកំណត់ដោយអនុក្រឹត្យ។ |
| **តំបន់វប្បធម៌និងសាសនា** | សំដៅដល់តំបន់ដែលមានមុខងារចម្បងសម្រាប់សាងសង់សំណង់ដែលបម្រើដល់វិស័យប្រវត្តិសាស្ត្រ សិល្បៈ វប្បធម៌ និងសាសនាដូចជាប្រាសាទ វត្តអារាម វិហារសាសនា សាលារៀន សារមន្ទីរ ទីលានកីឡា កន្លែងសិប្បកម្មចម្លាក់ សាលាឆទានពុទ្ធិកសាកលវិទ្យាល័យ។ល។ តំបន់នេះមានផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងដីឡូត៍ និងមានសន្ទស្សន៍ប្រើប្រាស់ដីកំណត់ដោយអនុក្រឹត្យ។ |
| **តំបន់ស្នូលនៃការអភិវឌ្ឍ** | សំដៅដល់តំបន់ដែលមានសក្តានុពលខ្ពស់ឬតំបន់ដែលមានការអភិវឌ្ឍខ្ពស់សម្រាប់គាំទ្រដល់តំបន់ដែលមានសក្តានុពលទាប។ |
| **តំបន់ឧស្សាហកម្ម** | សំដៅដល់តំបន់ដែលមានមុខងារសម្រាប់សាងសង់សំណង់ដែលបម្រើដល់វិស័យឧស្សាហកម្មខ្នាតធំដែលមានជាតិពុលខ្ពស់ដូចជារោងចក្រ រោងសិប្បកម្មខ្នាតធំ ឃ្លាំង យានដ្ឋាន។ល។ ហើយមិនអនុញ្ញាតឱ្យសាងសង់លំនៅឋាននៅតំបន់នេះឡើយ។ តំបន់នេះមានផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងដីឡូត៍ និងមានសន្ទស្សន៍ប្រើប្រាស់ដីកំណត់ដោយអនុក្រឹត្យ។ |
| **តំបន់ឧស្សាហកម្មចម្រុះ** | សំដៅដល់តំបន់ដែលមានមុខងារចម្បងសម្រាប់សាងសង់សំណង់ដែលបម្រើដល់វិស័យឧស្សាហកម្មនិងសេវាកម្ម។ គ្រប់អគាររោងចក្រទាំងអស់ត្រូវបានអនុញ្ញាតឱ្យសាងសង់លើកលែងតែអគារដែលមានផលប៉ះពាល់បរិស្ថានខ្ពស់។ តំបន់នេះអាចអនុញ្ញាតឱ្យមានលំនៅឋាននិងអគារពាណិជ្ជកម្មដូចជាសាលារៀន មន្ទីរពេទ្យ សាកលវិទ្យាល័យ ភោជនីយដ្ឋាន រោងកុន ឃ្លាំង យានដ្ឋាន។ តំបន់នេះមានផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងដីឡូត៍ និងមានសន្ទស្សន៍ប្រើប្រាស់ដីកំណត់ដោយអនុក្រឹត្យ។ |

**តំបន់ឧស្សាហកម្មស្រាល** សំដៅដល់តំបន់ដែលមានមុខងារសម្រាប់សាងសង់សំណង់ដែលបម្រើដល់វិស័យឧស្សាហកម្មខ្នាតតូចដែលមានជាតិពុលតិចឬមធ្យមដូចជារោងចក្រ រោងសិប្បកម្មខ្នាតតូច ឃ្លាំង យានដ្ឋាន។ល។ ហើយអាចអនុញ្ញាតឱ្យសាងសង់លំនៅឋាននៅតំបន់នេះបាន។ តំបន់នេះមានផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងដីឡូត៍ និងមានសន្ទស្សន៍ប្រើប្រាស់ដីកំណត់ដោយអនុក្រឹត្យ។

**ទម្ងន់សរុបអនុញ្ញាតអតិបរមារបស់យាន** សំដៅដល់ផលបូកទម្ងន់យាននិងទម្ងន់ផ្ទុកមនុស្សនិងទម្ងន់ផ្ទុកទំនិញ។ ប្រសិនបើយានមានសណ្តោង ទម្ងន់សរុបអនុញ្ញាតអតិបរមារបស់យានគឺផលបូកនៃទម្ងន់សរុបអតិបរមារបស់យាននីមួយៗ។

**ទីក្រុង** សំដៅដល់រាជធានី ក្រុង និងទីប្រជុំជន។ ទីក្រុងត្រូវបានធ្វើចំណាត់ថ្នាក់ជាទីក្រុងប្រភេទធំ ប្រភេទមធ្យម និងប្រភេទតូចស្របតាមលក្ខខណ្ឌនៃចំនួនប្រជាជន ដង់ស៊ីតេប្រជាជន សមាមាត្រអ្នកធ្វើការមិនមែនជាកសិករ មុខងារទីក្រុង និងរចនាសម្ព័ន្ធបរិវត្តទីក្រុង។ល។

**ទីតាំងសម្រាកលម្ហែ** សំដៅដល់កន្លែងសម្រាប់ធ្វើសេវាកម្មសាធារណៈដែលស្ថិតនៅខាងក្រៅដីចំណីផ្លូវនៃផ្លូវថ្នល់ធំៗដូចជាផ្លូវល្បឿនលឿន ផ្លូវជាតិសម្រាប់ឱ្យអ្នកបើកបរនិងអ្នកធ្វើដំណើរឈប់សម្រាកដោយមានសណ្ឋាគារ ភោជនីយដ្ឋាន បណ្តាញផ្លូវថ្នល់សុវត្ថិភាព ចំណតរថយន្ត ស្ថានីយប្រេងឥន្ធនៈ ស្ថានីយផ្តល់ព័ត៌មាន យានដ្ឋានជួសជុលយានយន្ត បណ្តាញទឹកស្អាត ប៉ុន្តែមិនមែនជារមណីយដ្ឋានទេ។

**ទឹកកខ្វក់** សំដៅដល់ទឹកដែលបានប្រែប្រួលចរិតលក្ខណៈដើមរបស់វា ក្រោយពីការប្រើប្រាស់រួចមានដូចជាទឹកសំណល់ពីផ្ទះបាយ បន្ទប់ទឹក ការបោកគក់ឬការលាងសម្អាតនានា និងទឹកសំណល់ពីបង្គន់អនាម័យរួមទាំងទឹកនោមនិងលាមកដែលបញ្ចេញពីលំនៅឋាន បុរីលំនៅឋាន ទីក្រុងរណប អគារអាជីវកម្ម អគារពាណិជ្ជកម្ម សេវាកម្ម និងតំបន់រមណីយដ្ឋានឬមជ្ឈមណ្ឌលកម្សាន្ត។

**ទឹកក្រោមដី** សំដៅដល់ទឹកដែលហូរនៅក្រោមដីក្នុងចន្លោះថ្មតូចធំនិងភាគល្អិតនៃដីដែលផ្លាស់ទីពីកន្លែងមួយទៅកន្លែងមួយទៀត។

**ទ្រូងផ្លូវ** សំដៅដល់ចំណែកនៃផ្លូវដែលទុកសម្រាប់ឱ្យយានជំនិះគ្រប់ប្រភេទធ្វើចរាចរណ៍។

**ទំហំផ្លូវកម្រិតកំណត់** សំដៅដល់ទំហំមានខ្នាតកម្រិតកំណត់អំពីកម្ពស់និងផ្ទៃរបស់ផ្លូវ ស្ពាន កំពង់ចម្លង ផ្លូវរូង។ល។ ដើម្បីឱ្យរថយន្តដឹកជញ្ជូនទំនិញឆ្លងកាត់មានសុវត្ថិភាព។

**នគរូបនីយកម្ម** សំដៅដល់សិល្បៈ វិទ្យាសាស្ត្រ និងបច្ចេកទេសនៃការធ្វើផែនការរូបវន្តទីក្រុង ការអភិវឌ្ឍ ការអភិរក្ស ការគ្រប់គ្រងការអភិវឌ្ឍ ការសាងសង់ និងការកែលម្អនៅក្នុងទីក្រុងនិងតំបន់ជុំវិញ ព្រមទាំងតំបន់ទទួលឥទ្ធិពលក្នុងគោលបំណងទទួលបាននូវចីរភាព តុល្យភាព សុខុមាលភាព សោភណភាព សមធម៌ និងសមាហរណកម្ម។

**បទដ្ឋានទំហំដីឡូត៍បច្ចេកទេស** សំដៅដល់ទំហំដីឡូត៍ដែលកំណត់ដោយប្រវែងក្បាលដីនិងជម្រៅដី ហើយត្រូវបានកំណត់ឡើងដើម្បីធានាការរៀបចំ ការគ្រប់គ្រងទីក្រុង ការអភិវឌ្ឍទីក្រុង ការអភិវឌ្ឍរចនាសម្ព័ន្ធ និងការអភិវឌ្ឍដីឱ្យមានសោភណភាពនិងមានសណ្តាប់ធ្នាប់។

**បទប្បញ្ញត្តិបច្ចេកទេស** សំដៅដល់បទដ្ឋានបច្ចេកទេស ស្តង់ដាបច្ចេកទេស និងឯកសារណែនាំលម្អិតបច្ចេកទេសការងារ លក្ខខណ្ឌសុវត្ថិភាពការងារ និងលក្ខខណ្ឌសុវត្ថិភាពចរាចរណ៍។

**បរិក្ខារបែងចែកចំណែកផ្លូវ** សំដៅដល់បរិក្ខារសម្រាប់បែងចែកចំណែកទ្រូងផ្លូវជាពីរចំណែកឱ្យចរាចរណ៍ទៅមក ឬបែងចែកចំណែកនោះជាគន្លងផ្លូវ។ បរិក្ខារបែងចែកចំណែកផ្លូវមានជាប្រភេទចល័ត និងអចល័ត។

**បរិក្ខារផ្លូវថ្នល់** សំដៅដល់ទីចំណត ទីសុំចត ភ្លើងសញ្ញា ផ្លាកសញ្ញាកំណត់ល្បឿន ផ្លាកសញ្ញាបង្ហាញផ្លូវ សញ្ញាចន្លោះគម្លាត គំនូសសញ្ញាឬរបាំងឬបរិក្ខារបែងចែកចំណែកផ្លូវរង្វង់មូល ខឿនបែងចែកទិសចរាចរណ៍ ថ្មចិញ្ចើមផ្លូវ ជញ្ជាំង របងការពារ បង្គោលគីឡូម៉ែត្រ បង្គោលសញ្ញាកំណត់ព្រំ ព្រមទាំងផ្លាកសញ្ញានិងឧបករណ៍បំពាក់ផ្សេងទៀតនៅតាមបណ្តោយផ្លូវថ្នល់។

**បរិក្ខារសម្រួលការបង្ហូរទឹក** សំដៅដល់ប្រឡាយ ស្នាមភ្លោះ អាងស្តុកទឹក ស្ថានីយចម្រោះទឹកកខ្វក់ ទីជម្រាលឬចំណោត។ល។ ដែលបានរៀបចំនៅតាមបណ្តោយផ្លូវថ្នល់សម្រាប់ការពារផ្លូវថ្នល់ បរិក្ខារផ្លូវថ្នល់ និងសុវត្ថិភាពចរាចរណ៍។

**បឹងបួ** សំដៅដល់ល្ហាលទឹកធំល្វឹងល្វើយកើតពីទីជម្រាលឬជម្រៅធម្មជាតិដែលអាចមានទឹក ឬគ្មានទឹកទៅតាមរដូវកាលនិងមានប្រភពមកពីទន្លេ ស្ទឹង ព្រែកឬពីតំបន់ផ្ទៃរងទឹកភ្លៀង។

**ប្រព័ន្ធប្រព្រឹត្តិកម្មទឹកកខ្វក់** សំដៅដល់ប្រឡាយចំហ អាងស្តុក ស្ថានីយបូមលូឬទឹកភ្លៀង បណ្តាញលូមេ បណ្តាញលូមេរង ស្ថានីយប្រព្រឹត្តិកម្មទឹកកខ្វក់រួមមានតាមលក្ខណៈបច្ចេកវិទ្យាឬលក្ខណៈធម្មជាតិ។

**ប្រព័ន្ធលូ** សំដៅដល់បណ្តាញប្រមូលនិងបង្ហូរទឹកកខ្វក់រួមមានតំណភ្ជាប់ អណ្តូងលូ និងបណ្តាញលូ (បណ្តាញលូរួម បណ្តាញលូដាច់ដោយឡែក បណ្តាញលូមេ បណ្តាញលូមេរង បណ្តាញលូខ្នែង និងបណ្តាញលូខ្នែងរង)។

**ប្រភេទដីកម្រិតការសាងសង់** សំដៅដល់ប្រភេទដីដែលត្រូវគ្រប់គ្រងពិសេសចំពោះការសាងសង់។ ប្រភេទដីនេះត្រូវបានបែងចែកជាតំបន់កសិកម្ម តំបន់ព្រៃឈើ តំបន់ធនធានទឹក តំបន់ការពារ និងតំបន់ផ្សេងៗមួយចំនួនទៀតស្របតាមភូមិសាស្ត្រជាក់ស្តែង។

**ប្រភេទដីអាចសាងសង់បាន** សំដៅដល់ប្រភេទដីដែលជំរុញឱ្យមានការអភិវឌ្ឍនិងការសាងសង់លើគ្រប់វិស័យ។ ប្រភេទដីនេះត្រូវបានបែងចែកជាតំបន់លំនៅឋាន តំបន់ពាណិជ្ជកម្ម តំបន់ឧស្សាហកម្ម តំបន់ចម្រុះ តំបន់ដឹកជញ្ជូន តំបន់សេវាកម្មទេសចរណ៍ តំបន់រដ្ឋបាលនិងសេវាសាធារណៈ តំបន់លម្ហសាធារណៈនិងផ្ទៃបៃតង តំបន់វប្បធម៌និងសាសនា និងតំបន់ផ្សេងៗមួយចំនួនទៀតស្របតាមភូមិសាស្ត្រជាក់ស្តែង។

**ប្លង់គោលប្រើប្រាស់ដី ឬប្លង់គោល** សំដៅដល់ផែនការដែលកំណត់អំពីចក្ខុវិស័យនិងយុទ្ធសាស្ត្រសរុបសម្រាប់ការអភិវឌ្ឍរូបវន្តនិងកំណត់ពីប្រភេទនៃការប្រើប្រាស់ដី (ប្រភេទដីអាចសាងសង់បាននិងប្រភេទដីកម្រិតការសាងសង់) ព្រមទាំងបង្ហាញអំពីទម្រង់ទីក្រុង បណ្ដាញហេដ្ឋារចនាសម្ព័ន្ធទីក្រុង និងគមនាគមន៍សំខាន់ៗនៃទីក្រុង ព្រមទាំងការធ្វើសមាហរណកម្ម។ ប្លង់គោលប្រើប្រាស់ដីត្រូវភ្ជាប់មកជាមួយនូវផែនការសកម្មភាពសម្រាប់អភិវឌ្ឍនិងអភិរក្សទីក្រុងទៅតាមលំដាប់អាទិភាពសម្រាប់រយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែង។ ប្លង់គោលប្រើប្រាស់ដីគឺជាប្លង់ដែលត្រូវបានសម្រេចដាក់ឱ្យប្រើប្រាស់ជាផ្លូវការដោយស្ថាប័នរដ្ឋមានសមត្ថកិច្ច។

**ប្លង់ទ្រេត** សំដៅដល់ប្លង់សម្រាប់កំណត់កម្ពស់អតិបរមានៃសំណង់។ ប្លង់នេះត្រូវបានកំណត់ឡើងដោយសមាមាត្រនៃទំហំទទឹងផ្លូវនិងការថយឆ្ងាតគម្លាតនៃអគារជាមួយនឹងកម្ពស់អគារដើម្បីធានាឱ្យមានចរន្តពន្លឺ ចរន្តខ្យល់ និងបរិស្ថានរស់នៅល្អពីអគារមួយទៅអគារមួយទៀត ព្រមទាំងធានាភាពសុខដុមនីយកម្មនៃស្ថាបត្យកម្មក្នុងតំបន់និងហេដ្ឋារចនាសម្ព័ន្ធសាធារណៈ។

**ប្លង់លម្អិតនគរូបនីយកម្ម** សំដៅដល់ប្លង់រំលេចទីតាំងនៃតំបន់ណាមួយក្នុងទីក្រុងឬជាគម្រោងអភិវឌ្ឍទីក្រុងដើម្បីបង្ហាញអំពីយុទ្ធសាស្ត្ររូបវន្តលម្អិតនៃការរៀបចំផ្ទៃ ទីតាំងឬតំបន់ប្រើប្រាស់ដីណាមួយឬច្រើនទីក្រុងដែលរួមមានការបង្ហាញអំពីការរៀបចំ ការរចនាទម្រង់ រូបរាងនិងសោភណភាពនៃរចនាសម្ព័ន្ធរូបវន្តសម្រាប់ការអភិវឌ្ឍ ការអភិរក្ស និងការសាងសង់តាមរយៈគំនូរឬរូបសំណាក។ ប្លង់លម្អិតនគរូបនីយកម្មត្រូវគោរពតាមផែនការប្រើប្រាស់ដី។

**ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍** សំដៅដល់អនុបាតរវាងផ្ទៃក្រឡាបាតសំណង់ជាន់ផ្ទាល់ដីនិងផ្ទៃក្រឡាដីឡូត៍គិតជាភាគរយ។

**ផែនការប្រើប្រាស់ដី** សំដៅដល់ផែនការលម្អិតចេញពីប្លង់គោលប្រើប្រាស់ដីដែលកំណត់អំពីប្រភេទប្រើប្រាស់ដី តំបន់ប្រើប្រាស់ដី និងកំណត់អំពីបទបញ្ញានៃការប្រើប្រាស់ដីជាក់ស្ដែងការសាងសង់ ការអភិវឌ្ឍដី និងការអភិរក្សក្នុងតំបន់នីមួយៗ ព្រមទាំងកំណត់អំពីបណ្ដាញគមនាគមន៍និងការធ្វើសមាហរណកម្ម។ ផែនការប្រើប្រាស់ដីគឺជាផែនការដែលត្រូវបានសម្រេចដាក់ឱ្យប្រើប្រាស់ជាផ្លូវការដោយស្ថាប័នរដ្ឋមានសមត្ថកិច្ច។

**ផែនការប្រើប្រាស់ដីថ្នាក់ឃុំ សង្កាត់** សំដៅដល់ផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ទាំងមូល ទាំងដីរដ្ឋនិងទាំងដីឯកជនរបស់បុគ្គលឯកជនដោយប៉ាន់ប្រមាណពីសក្ដានុពលដីនិងធនធានទឹក និងលទ្ធភាពផ្សេងៗក្នុងការប្រើប្រាស់ដី ព្រមទាំងលក្ខខណ្ឌសេដ្ឋកិច្ចនិងសង្គមកិច្ចដើម្បីធ្វើការជ្រើសរើសនូវជម្រើសសមស្របក្នុងការប្រើប្រាស់ដី។

**ផែនការរូបវន្តទីក្រុង** សំដៅដល់ការធ្វើសមាហរណកម្មផែនការប្រើប្រាស់ដី និងផែនការហេដ្ឋារចនាសម្ព័ន្ធរូបវន្តដើម្បីធានាការអភិវឌ្ឍ ការអភិរក្ស និងការសាងសង់ក្នុងទីក្រុងឱ្យមានចីរភាព តុល្យភាព សុខុមាលភាព សោភណភាព និងសមធម៌។ ផែនការរូបវន្តទីក្រុងមានប្លង់គោលប្រើប្រាស់ដីឬប្លង់គោល ផែនការប្រើប្រាស់ដី និងប្លង់លម្អិតនគរូបនីយកម្ម។

**ផែនការរៀបចំដែនដី** សំដៅដល់ផែនការដែលកំណត់ចក្ខុវិស័យនិងយុទ្ធសាស្ត្រតម្រង់ទិសការប្រើប្រាស់ដី និងការអភិវឌ្ឍផ្នែករូបវន្តដោយផ្អែកលើសក្ដានុពលនៃភូមិសាស្ត្រនិងតំបន់នីមួយៗ ក្នុងក្របខណ្ឌថ្នាក់ជាតិ តាមតំបន់ និងថ្នាក់ខេត្ត។

**ផ្លូវខេត្ត** សំដៅដល់ផ្លូវដែលមានចរាចរណ៍មធ្យមរួមមាន៖ ក-ផ្លូវភ្ជាប់ចេញពីក្រុងនៃខេត្តមួយឆ្ពោះទៅកាន់ទីរួមស្រុក ខណ្ឌ ខ-ផ្លូវបែកចេញពីផ្លូវជាតិឆ្ពោះទៅកាន់ផ្លូវខេត្ត គ-ផ្លូវបែកចេញពីផ្លូវខេត្តឬផ្លូវក្រុងឆ្ពោះទៅកាន់ទីរួមស្រុក ខណ្ឌ ឃ-ផ្លូវបែកចេញពីក្រុងនៃខេត្តឆ្ពោះទៅកាន់ផ្លូវខេត្ត ង-ផ្លូវបែកចេញពីផ្លូវខេត្តឆ្ពោះទៅកាន់ផ្លូវខេត្ត និង ច-ផ្លូវបែកចេញពីផ្លូវខេត្តឬផ្លូវក្រុងឬផ្លូវទីប្រជុំជននានាក្នុងខេត្តឆ្ពោះទៅកាន់តំបន់សំខាន់ៗដូចជាកំពង់ផែ ស្ថានីយរថភ្លើង អាកាសយានដ្ឋាន តំបន់សេដ្ឋកិច្ចពិសេស រមណីយដ្ឋានទេសចរណ៍ ច្រកទ្វារព្រំដែនទ្វេភាគី និងតំបន់មានសក្ដានុពលសេដ្ឋកិច្ចមធ្យមផ្សេងទៀត។

**ផ្លូវជនបទ** សំដៅដល់៖ ក-ផ្លូវដែលភ្ជាប់ពីក្រុង ទីរួមស្រុក ខណ្ឌឆ្ពោះទៅកាន់ក្រុង ទីរួមស្រុក ខណ្ឌ ទីប្រជុំជនឃុំ សង្កាត់ និងទៅភូមិ ខ-ផ្លូវដែលភ្ជាប់ពីក្រុង ទីរួមស្រុក ខណ្ឌឆ្ពោះទៅកាន់ក្រុង ទីរួមស្រុក ខណ្ឌ គ-ផ្លូវដែលភ្ជាប់ពីក្រុង ទីរួមស្រុក ខណ្ឌឆ្ពោះទៅទីប្រជុំជនឃុំ សង្កាត់ ឃ-ផ្លូវដែលភ្ជាប់ពីទីប្រជុំជនឃុំ សង្កាត់ឆ្ពោះទៅទីប្រជុំជនឃុំ សង្កាត់ ង-ផ្លូវដែលភ្ជាប់ពីទីប្រជុំជនឃុំ សង្កាត់ឆ្ពោះទៅភូមិ ច-ផ្លូវដែលភ្ជាប់ពីភូមិទៅភូមិ និង ឆ-ផ្លូវក្នុងភូមិ។

**ផ្លូវជាតិ** សំដៅដល់ផ្លូវដែលមានចរាចរណ៍ច្រើនរួមមាន៖ ក-ផ្លូវភ្ជាប់ចេញពីរាជធានីភ្នំពេញឆ្ពោះទៅកាន់ក្រុងនៃខេត្តនីមួយៗនៅទូទាំងប្រទេស ខ-ផ្លូវភ្ជាប់ចេញពីក្រុងនៃខេត្តមួយឆ្ពោះទៅកាន់ក្រុងនៃខេត្តមួយទៀត គ-ផ្លូវភ្ជាប់ចេញពីផ្លូវជាតិឆ្ពោះទៅកាន់ផ្លូវជាតិ ឃ-ផ្លូវបែកចេញពីផ្លូវជាតិឆ្ពោះទៅកាន់ក្រុងនៃខេត្តមួយ ង-ផ្លូវបែកចេញពីផ្លូវជាតិឬផ្លូវភ្ជាប់ចេញពីក្រុងនៃខេត្តមួយឆ្ពោះទៅកាន់តំបន់សំខាន់ៗដូចជាកំពង់ផែ ស្ថានីយរថភ្លើង អាកាសយានដ្ឋាន តំបន់សេដ្ឋកិច្ចពិសេស រមណីយដ្ឋានទេសចរណ៍ ច្រកទ្វារព្រំដែន តំបន់មានសក្ដានុពលសេដ្ឋកិច្ចសំខាន់ៗផ្សេងទៀត និង ច-ផ្លូវសំខាន់ៗរបស់ជាតិមានចរាចរណ៍ច្រើនដែលកំណត់ដោយរាជរដ្ឋាភិបាលតាមសំណើរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន។

**ផ្លូវជាន់គ្នា** សំដៅដល់ផ្លូវពីរឬច្រើនស្ថិតនៅលើផ្ទៃរាបតែមួយឬស្ថិតនៅលើផ្ទៃខុសកម្រិតគ្នា មានទិសស្របគ្នា មានប្រភេទនិងមុខងារផ្លូវខុសគ្នា។

**ផ្លូវថ្នល់ ឬផ្លូវ** សំដៅដល់ទីហ៊ុំផ្លូវទាំងមូលរួមមានតួផ្លូវ ទ្រូងផ្លូវ ជាយផ្លូវឬចិញ្ចើមផ្លូវ ស្ពាន ស្ពានអាកាស ស្ពានរំលង ផ្លូវរូង និងកំពង់ចម្លងតភ្ជាប់ផ្លូវថ្នល់។

**ផ្លូវថ្មើរជើង** សំដៅដល់ផ្នែកមួយនៃផ្លូវថ្នល់ដែលធ្វើឬរៀបចំឡើងសម្រាប់ឱ្យមនុស្សដើរប្រកបដោយសុវត្ថិភាព។

**ផ្លូវរាជធានី ផ្លូវក្រុង និងផ្លូវទីប្រជុំជននានាក្នុងខេត្ត** សំដៅដល់ផ្លូវថ្នល់ដែលស្ថិតនៅក្នុងបរិវេណភូមិសាស្ត្ររដ្ឋបាលរាជធានី ខេត្តរួមមានទ្រូងផ្លូវ ចិញ្ចើមផ្លូវ និងផ្លូវថ្មើរជើង។

**ផ្លូវរូង** សំដៅដល់ខ្សែផ្លូវបម្រើឱ្យចរាចរណ៍ ស្ថិតនៅក្រោមផ្ទៃដីឬក្នុងរូងដែលមានជញ្ជាំងសុវត្ថិភាព។

**ផ្លូវល្បឿនលឿន** សំដៅដល់ផ្លូវសម្រាប់យានយន្តធ្វើចរាចរណ៍ មានបរិក្ខារចែកទ្រូងផ្លូវជាពីរចំណែកខុសទិសគ្នាឬចែកជាគន្លងផ្លូវ គ្មានកន្លែងផ្លូវប្រសព្វលើផ្ទៃរាបមួយឬត្រូវមានផ្លូវប្រសព្វតិចបំផុតក្នុងករណីចាំបាច់ និងបំពាក់គ្រប់គ្រាន់នូវបរិក្ខារផ្លូវថ្នល់ដើម្បីធានាលំហូរចរាចរណ៍អត់ឈប់ សុវត្ថិភាព និងបន្ថយពេលវេលាធ្វើដំណើរនិងមានកន្លែងកំណត់សម្រាប់ឱ្យយានយន្តចេញនិងចូលផ្លូវល្បឿនលឿន។

**មន្ត្រីមានសមត្ថកិច្ច** សំដៅដល់មន្ត្រីថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**ម្ចាស់សំណង់** សំដៅដល់ម្ចាស់សិទ្ធិលើអគារឬសំណង់។

**ម្ចាស់សំណង់ឬអ្នកអភិវឌ្ឍអចលនវត្ថុ** សំដៅដល់រូបវន្តបុគ្គលឬនីតិបុគ្គលដែលទទួលបានលិខិតអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច។

**រង្វង់មូល** សំដៅដល់កន្លែងផ្លូវប្រសព្វដែលនៅចំកណ្តាលមានខឿនជារាងរង្វង់មូល មានផ្លាកសញ្ញាបង្ហាញទិសចរាចរណ៍ និងមានទ្រូងផ្លូវឯកទិសព័ទ្ធជុំវិញដោយសញ្ញាព្រួញប្រាប់ទិសចរាចរណ៍។

**លម្ហសាធារណៈ និងផ្ទៃបៃតង** សំដៅដល់ចំណែកធ្លាមួយមិនមានអគារឬរចនាសម្ព័ន្ធត្រូវបានសាងសង់ផ្សេងទៀត និងអាចដំណើរការជាសាធារណៈរួមមាន៖ ១)លម្ហបៃតងដីដែលត្រូវបានគ្របដណ្តប់មួយផ្នែកឬទាំងស្រុងដោយស្មៅ ដើមឈើ រុក្ខជាតិឬបន្លែផ្សេងទៀត។ ទីធ្លាបៃតងមានរួមបញ្ចូលទាំងសួនកុមារ ឧទ្យាន សួនច្បារសហគមន៍ និងទីលានបញ្ចុះសព ២)កន្លែងអង្គុយឬទីធ្លាទំនេរក្នុងតំបន់សាធារណៈ ៣)តំបន់ព្រៃដូចជាព្រៃបម្រុងទុកអចិន្ត្រៃយ៍ ព្រៃឯកជន និងព្រៃលិចទឹក និង ៤)ផ្ទៃទឹក ទន្លេ បឹង ស្ទឹង អូរ ប្រឡាយ។ល។ ជាទូទៅលម្ហសាធារណៈនិងផ្ទៃបៃតងផ្តល់នូវតំបន់កម្សាន្តសម្រាប់ប្រជាជនទូទៅដើម្បីបង្កើនភាពស្រស់ស្អាតនិងគុណភាពបរិស្ថាន។

**សន្ទស្សន៍ប្រើប្រាស់ដី** សំដៅដល់អនុបាតរវាងផ្ទៃក្រឡាកម្រាលសំណង់សរុបជាផ្លូវការ និងផ្ទៃក្រឡាដីឡូត៍ដែលសំណង់នោះតាំងនៅ។

**ស្ថានីយចំណតរថយន្ត** សំដៅដល់កន្លែងចតរថយន្តសម្រាប់សកម្មភាពឡើងចុះអ្នកដំណើរនិងលើកដាក់ទំនិញ។

| | |
|---|---|
| **ស្ថានីយថ្លឹងយានយន្ត** | សំដៅដល់កន្លែងរៀបចំឡើងសម្រាប់ត្រួតពិនិត្យទម្ងន់យានយន្ត។ |
| **ស្ថានីយសេវាតាមដងផ្លូវ** | សំដៅដល់កន្លែងបម្រើដល់ចរាចរណ៍តាមដងផ្លូវដូចជាស្ថានីយប្រេងឥន្ធនៈ កន្លែងគ្រប់គ្រងនិងផ្តល់ព័ត៌មាន ទីតាំងសម្រាកលំហែ យានដ្ឋានជួសជុលយានយន្ត។ល។ |
| **ស្ថានីយប្រព្រឹត្តិកម្មទឹកកខ្វក់** | សំដៅដល់រោងចក្រសម្អាតទឹកកខ្វក់រួមរបស់ទីប្រជុំជន រាជធានី ខេត្ត ក្រុង ស្រុកឬខណ្ឌ។ |
| **ស្ថានីយសម្រាក** | សំដៅដល់កន្លែងសម្រាប់ឱ្យអ្នកធ្វើដំណើរសម្រាកដោយមានសេវាអាហារដ្ឋាន បង្គន់អនាម័យ កន្លែងជូនដំណឹង។ល។ |
| **ស្ពាន** | សំដៅដល់សំណង់ឆ្លងផ្ទៃទឹកសម្រាប់ចម្លងចរាចរណ៍ពីទីតាំងមួយទៅទីតាំងមួយទៀត។ |
| **ស្ពានវិលង** | សំដៅដល់ស្ពានឆ្លងផ្ទៃដីសម្រាប់ចម្លងចរាចរណ៍ពីទីតាំងមួយទៅទីតាំងមួយទៀតដោយវិលងផ្លូវថ្នល់ឬផ្លូវរថភ្លើងនៅទីតាំងតែមួយ។ |
| **ស្ពានអាកាស** | សំដៅដល់ស្ពានឆ្លងផ្ទៃដីសម្រាប់ចម្លងចរាចរណ៍ពីទីតាំងមួយទៅទីតាំងមួយទៀតដោយវិលងសំណង់គ្រប់ប្រភេទនៅទីតាំងខុសៗគ្នានិងកម្រិតកម្ពស់ខុសៗគ្នា។ |
| **សំណង់ផ្លូវថ្នល់** | សំដៅដល់ផ្លូវថ្នល់ កន្លែងឈប់យានជំនិះ ចំណតរថយន្តលើផ្លូវ បរិក្ខារផ្លូវថ្នល់ សំណង់សិល្បការ្យ និងសំណង់ផ្សេងៗទៀតបម្រើឱ្យផ្លូវថ្នល់។ |
| **សំណង់សិល្បការ្យ** | សំដៅដល់សំណង់ស្ពាន លូ ជញ្ជាំងទប់ដី ប្រព័ន្ធរំដោះទឹក និងសំណង់រូបវន្តផ្សេងទៀតដែលផ្តល់នូវសុវត្ថិភាព ប្រសិទ្ធភាព និងស្ថិរភាពដល់ផ្លូវថ្នល់។ |
| **សំណល់រាវ** | សំដៅដល់ទឹកសំណល់មានផ្ទុកសារធាតុបំពុលបរិស្ថានដែលបញ្ចេញពីសកម្មភាពឬដំណើរការផ្ទាល់នៃផលិតកម្ម អាជីវកម្មឬសេវាកម្ម។ |
| **សំណៅ** | សំដៅដល់ការចម្លងពីសេចក្តីដើមឬច្បាប់ដើមដើម្បីទុកជាឯកសារ។ |
| **ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់** | សំដៅដល់ដីចំណីផ្លូវ សំណង់ផ្លូវថ្នល់ ស្ថានីយចំណតរថយន្ត បរិវេណចំណតរថយន្ត ទីស៊ុំចតរថយន្ត ស្ថានីយសេវាតាមដងផ្លូវ និងទីតាំងសម្រាកលំហែ។ |
| **ទន្លេ** | សំដៅដល់ផ្លូវទឹកធម្មជាតិដែលទទួលប្រភពទឹកមកពីស្ទឹង ព្រែក ជ្រោះ អូរ ទឹកក្រោមដី និងពីតំបន់ផ្ទៃរងទឹកភ្លៀងនៅផ្នែកខាងលើ ហើយហូរចាក់ទៅសមុទ្រ។ |
| **អាងទន្លេ** | សំដៅដល់តំបន់ភូមិសាស្ត្រដែលកំណត់ដោយព្រំប្រទល់ទីជម្រាលនៃប្រព័ន្ធទឹកហូរដោយរាប់បញ្ចូលទាំងទឹកលើដីនិងទឹកក្រោមដី។ |
| **អាងទឹក** | សំដៅដល់ទីតម្កល់ទឹកដែលកើតឡើងដោយធម្មជាតិឬសិប្បនិម្មិតសម្រាប់ប្រើទៅតាមតម្រូវការ។ |
| **អាងបង្គន់អនាម័យ** | សំដៅដល់អាងទទួលទឹកកខ្វក់ពីបង្គន់អនាម័យនិងបន្ទប់ទឹកដើម្បីស្តុកនិងបំបែកសំណល់សរីរាង្គក្នុងទឹកកខ្វក់មុនការហូរចេញទៅក្នុងប្រព័ន្ធលូសាធារណៈ។ |
| **អាជ្ញាធរមានសមត្ថកិច្ច** | សំដៅដល់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សាលារាជធានី ខេត្ត សាលាក្រុង ស្រុក ខណ្ឌដែលមានសមត្ថកិច្ចផ្តល់លិខិតអនុញ្ញាតសាងសង់ស្របតាមសមត្ថកិច្ច។ |

**អូរ** សំដៅដល់ផ្លូវទឹកធម្មជាតិដែលទទួលប្រភពទឹកមកពីជ្រោះនិងពីតំបន់ផ្ទៃរងទឹកភ្លៀងនៅផ្នែកខាងលើ ហើយហូរចូលព្រែក ស្ទឹង ទន្លេឬបឹង។

**អ្នកជាប់ពាក់ព័ន្ធផ្លូវថ្នល់** សំដៅដល់អ្នកគ្រប់គ្រង អ្នកសាងសង់ អ្នកត្រួតពិនិត្យ អ្នកផ្តល់ហិរញ្ញប្បទានឬសម្បទានិកអភិវឌ្ឍនិងថែទាំផ្លូវថ្នល់ អ្នកដឹកជញ្ជូន និងអ្នកប្រើប្រាស់ផ្លូវថ្នល់ អ្នករស់នៅសងខាងផ្លូវថ្នល់ និងអ្នកផ្គត់ផ្គង់សម្ភារៈគ្រឿងចក្រនិងបរិក្ខារផ្លូវថ្នល់។

**អ្នកប្រើប្រាស់ផ្លូវថ្នល់** សំដៅដល់អ្នកបើកបរយាន អ្នកថ្មើរជើង អ្នកធ្វើអាជីវកម្មលើផ្លូវថ្នល់ អ្នកឃ្វាលឬអ្នកប្រើប្រាស់សត្វពាហនៈនិងអ្នកប្រើប្រាស់ផ្លូវថ្នល់ក្នុងគោលបំណងផ្សេងទៀត។

ᧁᧁ៙ᧅᧅ

**ឯកសារឧបសម្ព័ន្ធ**

## ឧបសម្ព័ន្ធទី១ ប្លង់ព្រំប្រទល់រដ្ឋបាលខណ្ឌព្រែកព្នៅ



# ឧបសម្ព័ន្ធទី២ ប្លង់បណ្តាញផ្លូវថ្នល់និងគមនាគមន៍ចម្បងៗ



## ១) ផ្លូវជាតិលេខ៥

– ផ្លូវជាតិលេខ៥ (ជាក់ស្តែងទំហំ២៤ម៉ែត្រនិងតាមគម្រោងកំណត់ដោយអនុក្រឹត្យនឹងពង្រីកដល់ទំហំ ៦០ម៉ែត្រ) ចាប់ពីស្ពានព្រែកព្នៅដល់ព្រំប្រទល់ស្រុកពញាឮដែលមានប្រវែង៧ ២០០ម៉ែត្រដោយអមសងខាងនៃខាងកើតនិងខាងលិចកំណាត់ផ្លូវជាតិលេខ៥ជាតំបន់លំនៅឋានចម្រុះ។



## ២) ផ្លូវទំនប់កប់ស្រូវ

– ផ្លូវទំនប់កប់ស្រូវចាប់ពីស្ពានព្រែកព្នៅដល់ស្ថានីយបូមទឹកកប់ស្រូវ (ជាក់ស្តែងទំហំ២៤ម៉ែត្រនិងតាមគម្រោងកំណត់ដោយអនុក្រឹត្យនឹងពង្រីកដល់ទំហំ៥០ម៉ែត្រ) និងចាប់ពីស្ថានីយបូមទឹកកប់ស្រូវនៃព្រំប្រទល់ជាមួយនឹងខណ្ឌពោធិ៍សែនជ័យ (ជាក់ស្តែងទំហំ២៤ម៉ែត្រនិងតាមគម្រោងកំណត់ដោយអនុក្រឹត្យនឹងពង្រីកដល់ទំហំ៦០ម៉ែត្រ)ដែលមានប្រវែង៩ ៤០០ម៉ែត្រ។ តំបន់ខាងលិចនៃផ្លូវទំនប់កប់ស្រូវជាលំនៅឋានចម្រុះនិងខាងកើតនៃផ្លូវទំនប់កប់ស្រូវជាតំបន់លម្ហបៃតង។



### ៣) ផ្លូវលេខ១៥១

- ផ្លូវលេខ១៥១ ចាប់ពីផ្លូវជាតិលេខ៥ ដល់ភ្នំប្រសិទ្ធិ (ជាក់ស្តែងទំហំ១៤ម៉ែត្រនិងតាមគម្រោងនឹងពង្រីកដល់ទំហំ៥០ម៉ែត្រ)ដែលមានប្រវែង១៣ ២០០ម៉ែត្រ។ តំបន់ខាងជើងនៃផ្លូវលេខ១៥១ជាតំបន់លំនៅឋានចម្រុះនិងខាងត្បូងនៃផ្លូវលេខ១៥១ជាតំបន់លម្ហបៃតង។



### ៤) ផ្លូវលេខ៤២ និងផ្លូវវត្តភ្មៀត

- ផ្លូវលេខ៤២ចាប់ពីផ្លូវលេខ១៥១ (ចំណុចជើងភ្នំប្រសិទ្ធិ)ដល់ព្រំប្រទល់ខណ្ឌពោធិ៍សែនជ័យ (ជាក់ស្តែងទំហំ៨ម៉ែត្រនិងតាមគម្រោងកំណត់ដោយអនុក្រឹត្យនឹងពង្រីកដល់ទំហំ៤០ម៉ែត្រ) ឆ្ពោះទៅបែកចានដែលមានប្រវែង៧ ៥០០ម៉ែត្រ។ តំបន់១០០ម៉ែត្រអមសងខាងផ្លូវលេខ៤២ជាតំបន់លំនៅឋានចម្រុះ
- ផ្លូវវត្តភ្មៀតចាប់ពីផ្លូវលេខ៤២ ដល់ព្រំប្រទល់ខណ្ឌពោធិ៍សែនជ័យ (ជាក់ស្តែងទំហំ៨ម៉ែត្រនិងតាមគម្រោងកំណត់ដោយអនុក្រឹត្យនឹងពង្រីកដល់ទំហំ៤០ម៉ែត្រ) ឆ្ពោះទៅវត្តភ្មៀតដែលមានប្រវែង១ ៧៧០ ម៉ែត្រ។ តំបន់១០០ម៉ែត្រអមសងខាងផ្លូវវត្តភ្មៀតជាតំបន់លំនៅឋានចម្រុះ។



## ៥) ផ្លូវភូមិសំរោងនិងផ្លូវកម្ពុប៊ី

- ផ្លូវភូមិសំរោងចាប់ពីផ្លូវជាតិលេខ៥ ដល់ផ្លូវលេខ១៥១ (ជាក់ស្តែងទំហំ៨ម៉ែត្រនិងតាមគម្រោងនឹងពង្រីកដល់ទំហំ២០ម៉ែត្រ) ដែលមានប្រវែង១៣ ២០០ម៉ែត្រ។ តំបន់អមសងខាងផ្លូវភូមិសំរោងជាតំបន់ចម្រុះ
- ផ្លូវកម្ពុប៊ីចាប់ពីផ្លូវជាតិលេខ៥ ដល់ផ្លូវទំនប់កប់ស្រូវ (ជាក់ស្តែងទំហំ៨ម៉ែត្រនិងតាមគម្រោងនឹងពង្រីកដល់ទំហំ២០ម៉ែត្រ)។ តំបន់អមសងខាងផ្លូវកម្ពុប៊ីជាតំបន់លំនៅឋានដាច់ពីគ្នាដែលមានកម្ពស់ទាប។

គំរូផ្លូវក្រុមទី៤ "អនុវិថីមានទទឹងផ្លូវ ២០ម៉ែត្រ"




ប្លង់ពុះកាត់ទទឹងផ្លូវ ក_ក




ប្លង់ដេក

## ៦) ផ្លូវភូមិ

– ផ្លូវភូមិមានទទឹងចាប់ពី៧ម៉ែត្រដល់តូចជាង១២ម៉ែត្រជាផ្លូវបម្រើឱ្យចរាចរណ៍សាធារណៈក្នុងភូមិ បុរីឬទីប្រជុំជន។








## គំរូផ្លូវកម្រិតទី៥ "អនុវិថីមានទទឹងផ្លូវ ២០ម៉ែត្រ"




ប្លង់មុខកាត់ទទឹងផ្លូវ ក_ក




ប្លង់ផាត

## គំរូផ្លូវកម្រិតទី៥ "អនុវិថីមានទទឹងផ្លូវ ២០ម៉ែត្រ"




ប្លង់មុខកាត់ទទឹងផ្លូវ ក_ក




ប្លង់ផាត

# គំរូផ្លូវកម្រិតទី៤ "វិថីមានទទឹងផ្លូវ ៣០ម៉ែត្រ"




ប្លង់កាត់ទទឹងផ្លូវ ក_ក




ប្លង់ដេក

# ឧបសម្ព័ន្ធទី៣ ប្លង់កំណត់កម្ពស់សំណង់តាមវិថីសំខាន់ៗ



# ឧបសម្ព័ន្ធទី៤ ប្លង់កំណត់កម្ពស់សំណង់តាមសន្ទស្សន៍ប្រើប្រាស់ដី



# ឧបសម្ព័ន្ធទី៥ ប្លង់កំណត់កម្ពស់សំណង់ក្នុងតំបន់គ្រប់គ្រងកម្ពស់ឧបសគ្គ




កម្ពស់សំណង់ក្នុងរាជធានីភ្នំពេញដែលបានកំណត់កម្ពស់ជាម៉ែត្រនិងកំណត់កម្ពស់តាមសន្ទស្សន៍ប្រើប្រាស់ដីដែលស្ថិតនៅក្នុងតំបន់គ្រប់គ្រងកម្ពស់ឧបសគ្គត្រូវមានកម្ពស់ទាបជាងដាច់ខាតនៃការកំណត់កម្ពស់ឧបសគ្គសម្រាប់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ។ ការសាងសង់សំណង់ខ្ពស់ៗគ្រប់ប្រភេទដែលមានកម្ពស់ខ្ពស់ជាងផ្ទៃកំណត់កម្ពស់ឧបសគ្គនៅក្នុងតំបន់គ្រប់គ្រងកម្ពស់ឧបសគ្គត្រូវមានការអនុញ្ញាតពីរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលជាមុន។

# ឧបសម្ព័ន្ធទី៦ ប្លង់លម្អសាធារណៈនិងផ្ទៃបៃតង



លម្ហសាធារណៈនិងផ្ទៃបៃតងគឺជាចំណែកផ្លាមួយមិនមានអគារឬរចនាសម្ព័ន្ធត្រូវបានសាងសង់ផ្សេងទៀត និងអាចដំណើរការជាសាធារណៈដែលអាចរួមបញ្ចូលៈ

១) លម្ហបៃតងគឺជាដីដែលត្រូវបានគ្របដណ្តប់មួយផ្នែកឬទាំងស្រុងដោយស្មៅ ដើមឈើ រុក្ខជាតិឬបន្លែផ្សេងទៀត។ ទីធ្លាបៃតងមានរួមបញ្ចូលទាំងសួនកុមារ ឧទ្យាន សួនច្បារសហគមន៍ និងទីលានបញ្ចុះសព។

២) កន្លែងអង្គុយឬទីធ្លាទំនេរក្នុងតំបន់សាធារណៈ។

៣) តំបន់ព្រៃមានដូចជាព្រៃបម្រុងទុកអចិន្ត្រៃយ៍ ព្រៃឯកជន និងព្រៃលិចទឹក។

៤) ផ្ទៃទឹកមានដូចជាទន្លេ បឹង ស្ទឹង អូរ ប្រឡាយ។ល។

ជាទូទៅលម្ហសាធារណៈនិងផ្ទៃបៃតងផ្តល់នូវតំបន់កម្សាន្តសម្រាប់ប្រជាជនទូទៅនិងជួយបង្កើនភាពស្រស់ស្អាតនិងគុណភាពបរិស្ថាន។

## ឧបសម្ព័ន្ធទី៧ ផ្លាតម្លាតអគារក្នុងដីឡូត៍ពីព្រំដីកាន់កាប់ស្របច្បាប់

| ល.រ. | អគារដែលមានកម្ពស់ | គម្លាតពីព្រំដីចំណីផ្លូវ(ម៉ែត្រ) | គម្លាតមិនជាប់ព្រំដីចំណីផ្លូវ(ម៉ែត្រ) | ផ្សេងៗ |
|---|---|---|---|---|
| ១. |ចាប់ពីជាន់ផ្ទាល់ដី ដល់ជាន់ទី៨ | ≥4.00 | ≥2.00 | |
| ២. | ចាប់ពីជាន់ទី៩ ដល់ជាន់ទី១១ | ≥5.00 | ≥2.50 | |
| ៣. | ចាប់ពីជាន់ទី១២ ឡើងទៅ | >5.00 | >2.50 | |
| ៤. | ចាប់ពីជាន់ទី១២ ដល់ជាន់ទី២០ | ≥6.00 | ≥3.00 | សម្រាប់សំណង់ស្ថិតតាមបណ្តោយមហាវិថី |
| ៥. | ចាប់ពីជាន់ទី២១ ដល់ជាន់ទី៣០ | ≥8.00 | ≥3.50 | សម្រាប់សំណង់ស្ថិតតាមបណ្តោយមហាវិថី |
| ៦. | ចាប់ពីជាន់ទី៣១ ឡើងទៅ | ≥10.00 | ≥4.00 | សម្រាប់សំណង់ស្ថិតតាមបណ្តោយមហាវិថី |

ការសាងសង់សំណង់គ្រប់ប្រភេទត្រូវរៀបចំប្រព័ន្ធខ្យល់ចេញ-ចូលតាមធម្មជាតិឬសិប្បនិម្មិតនូវទ្វារ បង្អួច រន្ធខ្យល់ឬឧបករណ៍គ្រឿងចក្រ។ អគារស្នាក់នៅត្រូវមានកម្ពស់ជាន់នីមួយៗអប្បបរមាត្រឹម៣,២០ម៉ែត្រ អគារពាណិជ្ជកម្ម អគារឧស្សាហកម្ម និងអគារសាលមហោស្រប សាលប្រជុំ ពិធី និងរោងភាពយន្តត្រូវមានកម្ពស់ជាន់នីមួយៗអប្បបរមាត្រឹម៤ម៉ែត្រ អគារសិក្សាធិការ អប់រំ កីឡា និងអគារសុខភាពត្រូវមានកម្ពស់ជាន់នីមួយៗអប្បបរមាត្រឹម៣,៦០ម៉ែត្រ និងត្រូវតម្រង់ជួរឬរក្សាផ្លាតម្លាតអគារក្នុងដីឡូត៍ពីព្រំដីកាន់កាប់ស្របច្បាប់ដូចមានចែងក្នុងប្លង់បណ្តាញផ្លូវថ្នល់និងគមនាគមន៍ចម្បងៗ និងប្លង់ជួរតម្រង់ ផ្លាតម្លាត កម្ពស់ សោភណភាព និងរចនាបថស្ថាបត្យកម្ម។

## គំរូទី ១

## ធ្លាគម្លាតអគារក្នុងដីឡូត៍ពីព្រំដីកាន់កាប់ស្របច្បាប់ និងកម្ពស់
## អគារលំនៅឋាន តំបន់ជុំវិញព្រះបរមរាជវាំង



គំរូទី ១.ក. លំនៅឋានដាច់ពីគ្នា



គំរូទី ១.ខ. លំនៅឋានជាប់គ្នា

# គំរូទី ២

## ផ្លាតម្លាតអគារក្នុងដីឡូត៍ពីព្រំដីកាន់កាប់ស្របច្បាប់ និងកម្ពស់ អគារលំនៅឋាន និងអគារពាណិជ្ជកម្ម ដែលរត់ជួរតម្រង់



# គំរូទី ៣

## ឆ្លាកម្លាតអគារក្នុងដីឡូត៍ពីព្រំដីកាន់កាប់ស្របច្បាប់ និងកម្ពស់ អគារលំនៅឋាន និងអគារពាណិជ្ជកម្ម




គំរូទី ៣.ក. លំនៅឋាន ឬអគារពាណិជ្ជកម្មជាប់គ្នា




គំរូទី ៣.ខ. លំនៅឋាន ឬអគារពាណិជ្ជកម្មដាច់ពីគ្នា

## គំរូទី ៤

## ឆ្លាកម្លាតអគារក្នុងដីឡូត៍ពីព្រំដីកាន់កាប់ស្របច្បាប់ និងកម្ពស់ អគារជុំវិញផ្សារធំថ្មី





## ឧបសម្ព័ន្ធទី៩ ប្លង់គំរូច្រាំងទន្លេ

- ច្រាំងទន្លេសាបដែលគិតពីច្រាំងទន្លេមក២៥ម៉ែត្រជាតំបន់លម្ហសាធារណៈនិងផ្ទៃបែតង
- ជំរុញការសាងសង់ច្រាំងទន្លេអំពីបេតុងដើម្បីទប់ស្កាត់ការបាក់ច្រាំងនិងរៀបចំជាសួនសាធារណៈ។

**គំរូទី១ : ច្រាំងទន្លេចោត**




**គំរូទី២ : ច្រាំងទន្លេ**
**ប្លង់មើលពីមុខ**



**គំរូទី២ : ច្រាំងទន្លេ**
**ផ្លង់ពុះ ក_ក**




**គំរូទី២ : ច្រាំងទន្លេ**
**ផ្លង់ពុះ ខ_ខ**



## ឧបសម្ព័ន្ធទី១០ បឹងធម្មជាតិ

ខណ្ឌព្រែកព្នៅមានបឹងធំៗចំនួន២គឺ៖

- បឹងសំរោងស្ថិតនៅតាមបណ្តោយផ្នែកខាងលិចផ្លូវជាតិលេខ៥ ក្នុងសង្កាត់ព្រែកព្នៅនិងសង្កាត់សំរោង ដែលមានទំហំ៣៣៦ហិកតា យោងអនុក្រឹត្យលេខ៦៥ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៨
- បឹងតាមោក (បឹងកប់ស្រូវ) ស្ថិតនៅចន្លោះផ្លូវទំនប់កប់ស្រូវនិងផ្លូវលេខ១៥១ ក្នុងខណ្ឌព្រែកព្នៅដែលមានទំហំ៣ ២៣៩,៧០ហិកតា យោងអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៦។

ចក្ខុវិស័យនៃការអភិរក្សបឹងតាមោកមាន៖

- ខណ្ឌចែកឱ្យដាច់ដោយទំនប់រវាងទឹកកខ្វក់និងទឹកធម្មជាតិ
- បង្កើតកន្លែងប្រព្រឹត្តិកម្មទឹកកខ្វក់ដើម្បីកាត់បន្ថយជាតិពុលមុនបង្ហូរចូលទន្លេ
- បង្កើតតំបន់បៃតងសាធារណៈជុំវិញបឹង។

## ឧបសម្ព័ន្ធទី១១ ព្រែកនិងប្រឡាយ

ខណ្ឌព្រែកព្នៅមានព្រែកធំៗចំនួន២គឺ៖

- ព្រែកព្នៅស្ថិតក្នុងសង្កាត់ព្រែកព្នៅមានទំហំ៣០ម៉ែត្រនិងប្រវែង២ ៦៩៦ម៉ែត្រដែលមានមុខងារទទួលទឹកពីបឹងតាមោកចាក់ចូលទន្លេសាប
- ព្រែកស្ថិតក្នុងសង្កាត់សំរោងមានប្រវែង៣០ ៥៨៥ម៉ែត្រដែលលាតសន្ធឹងពីបឹងតាមោកតាមបណ្តោយព្រំប្រទល់សង្កាត់សំរោងនឹងឃុំជ្រៃលាស់ ឃុំព្រែកតាទែន ស្រុកអង្គស្នួល ខេត្តកណ្តាល។

ខណ្ឌព្រែកព្នៅមានអូរនិងប្រឡាយមួយចំនួនគឺ៖

- អូរក្រចាប់ស្ថិតក្នុងសង្កាត់ពន្សាំងមានទំហំ៣០ម៉ែត្រនិងប្រវែង៨ ៩៤៥ម៉ែត្រដែលមានមុខងាររំដោះទឹកពីផ្នែកខាងលិចនៃសង្កាត់ពន្សាំងចូលបឹងតាមោក
- អូរព្រំប្រទល់ខណ្ឌព្រែកព្នៅនឹងខណ្ឌពោធិ៍សែនជ័យមានទំហំ៣៥ម៉ែត្រនិងប្រវែង១០ ០០០ម៉ែត្រដែលមានមុខងាររំដោះទឹកពីផ្នែកខាងត្បូងឈាងខាងលិចនៃសង្កាត់ពន្សាំងចូលបឹងតាមោក
- ប្រឡាយទួលសំពៅស្ថិតក្នុងសង្កាត់គោករកាមានទំហំ៤០ម៉ែត្រនិងប្រវែង១ ៣១៧ម៉ែត្រដែលមានមុខងាររំដោះទឹកពីភ្នំពេញចូលបឹងតាមោក
- ប្រឡាយ លឹម គានហោ ទ្វារទឹកទី១ ស្ថិតក្នុងសង្កាត់ពញាពន់មានទំហំ២០ម៉ែត្រនិងប្រវែង៩០៥ម៉ែត្រភ្ជាប់ពីទ្វារទឹកបឹងតាមោកទៅព្រែកព្រំប្រទល់សង្កាត់ពញាពន់ សង្កាត់សំរោង ឃុំជ្រៃលាស់ ឃុំព្រែកតាទែន ខេត្តកណ្តាល
- ប្រឡាយ លឹម គានហោ ទ្វារទឹកទី២ ស្ថិតក្នុងសង្កាត់ពញាពន់មានទំហំ៣០ម៉ែត្រនិងប្រវែង៩១២ម៉ែត្រភ្ជាប់ពីទ្វារទឹកបឹងតាមោកទៅព្រែកព្រំប្រទល់សង្កាត់ពញាពន់ សង្កាត់សំរោង ឃុំជ្រៃលាស់ ឃុំព្រែកតាទែន ខេត្តកណ្តាល
- ប្រឡាយទ្វារទឹកទី៣ ស្ថិតក្នុងសង្កាត់សំរោងមានទំហំ១០ម៉ែត្រនិងប្រវែង៦៧៨ម៉ែត្រដែលមានមុខងាររំដោះទឹកចូលបឹងតាមោក
- ប្រឡាយកងទ័ពស្ថិតក្នុងសង្កាត់ពញាពន់មានទំហំ១០ម៉ែត្រនិងប្រវែង១ ១០៥ម៉ែត្រចាប់ពីផ្លូវលេខ១៥១ដល់ព្រំប្រទល់ខណ្ឌព្រែកព្នៅជាមួយស្រុកពញាឮដែលមានមុខងាររំដោះទឹកចេញពីភូមិស្រែជូនតូច
- ប្រឡាយស្រះហ្លួងស្ថិតក្នុងសង្កាត់ពញាពន់មានទំហំ៦៧ម៉ែត្រនិងប្រវែង១ ០៦២ម៉ែត្រចាប់ពីផ្លូវលេខ១៥១ដល់ព្រំប្រទល់ខណ្ឌព្រែកព្នៅជាមួយស្រុកពញាឮដែលមានមុខងារស្តុកទឹកស្អាតសម្រាប់ប្រើប្រាស់

- ប្រឡាយគ្រួសសស្អិតក្នុងសង្កាត់ពញាពន់មានទំហំ៦ម៉ែត្រនិងប្រវែង៨ ០៨៨ម៉ែត្រចាប់ពីច្រកចូលវត្ត ភ្នំរាបទៅដល់បឹងតាមោកដែលមានមុខងាររំដោះទឹក
- ប្រឡាយវត្តគ្រួសស្អិតនៅសង្កាត់សំរោង ភូមិគ្រួសផ្នែកខាងជើងវត្តជេដ្ឋាឧត្តម (ហៅវត្តគ្រួស) ខាងត្បូងជាប់វត្ត ខាងលិចជាប់ផ្លូវជាតិលេខ៥ ខាងកើតជាប់ទន្លេសាបដែលមានមុខងាររំដោះទឹក។

**គម្រោងលើកផ្លូវ និងស្តារប្រឡាយហ្លួង ប្រវែង១០៦២ម**
**នៅភូមិស្រែជូនគួច សង្កាត់ពញាពន់ ខណ្ឌព្រែកព្នៅ**







**គម្រូប្រឡាយដីមានផ្លូវថែទាំ (ទំហំ≥២៨ម៉ែត្រ)**
មាត្រដ្ឋាន ១/២០០




**គម្រូប្រឡាយមធ្យម (ទំហំ≤២១ម៉ែត្រ)**
មាត្រដ្ឋាន ១/១២




**គម្រូប្រឡាយបេតុងមានផ្លូវថែទាំ (ទំហំ≥១៤ម៉ែត្រ)**
មាត្រដ្ឋាន ១/១៥០

# ឧបសម្ព័ន្ធទី១២ គម្រោងអាទិភាពនៃការអភិវឌ្ឍ ការអភិរក្ស និងការសាងសង់




ការសាងសង់និងការកែលម្អជាយុទ្ធសាស្ត្រតាមដងផ្លូវសំខាន់ៗនិងលម្ហសាធារណៈដោយរៀបចំជាសួនច្បារ ផ្លូវទេសចរណ៍ ចំណតយានយន្ត និងរចនាសម្ព័ន្ធការពារនិងអភិរក្សដើម្បីធានាការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងការសាងសង់សំណង់ផ្សេងៗប្រកបដោយនិរន្តរភាពក្នុងរាជធានីភ្នំពេញ។

# បញ្ជីគម្រោងអភិវឌ្ឍនិងផែនការសកម្មភាពតាមលំដាប់អាទិភាពចម្បង

| ឈ្មោះគម្រោង៖ សាងសង់និងកែលម្អផ្លូវយុទ្ធសាស្ត្រសម្រួលចរាចរណ៍និងបរិស្ថានរាជធានី | អាទិភាព ១.ក |
| --- | --- |
| **ប្រវត្តិគម្រោង** | |
| បឹងតាមោក (បឹងកប់ស្រូវ) ស្ថិតនៅចន្លោះផ្លូវទំនប់កប់ស្រូវនិងផ្លូវលេខ១៥១ ក្នុងខណ្ឌព្រែកព្នៅដែលមានទំហំ ៣ ២៣៩,៧០ហិកតា យោងអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៦។ | |
| **បរិយាយគម្រោង** | |
| **សមាសភាគគម្រោង** | ១) ខណ្ឌចែកឱ្យដាច់ដោយទំនប់រវាងទឹកកខ្វក់និងទឹកធម្មជាតិ<br>២) បង្កើតកន្លែងប្រព្រឹត្តិកម្មទឹកកខ្វក់ដើម្បីកាត់បន្ថយជាតិពុលមុនបង្ហូរចូលទន្លេ<br>៣) បង្កើតតំបន់បៃតងសាធារណៈជុំវិញបឹង។ |
| **រយៈពេលអនុវត្តគម្រោង** | គួរត្រូវបានអនុវត្តចាប់ពីឆ្នាំ២០១៨ដល់ឆ្នាំ២០៣៥ |
| **ទីតាំងគម្រោង** | ស្ថិតនៅក្នុងខណ្ឌព្រែកព្នៅ |
| **អង្គភាពអនុវត្តគម្រោង** | |
| មន្ទីរសាធារណការនិងដឹកជញ្ជូនរាជធានីភ្នំពេញ និងស្ថាប័នពាក់ព័ន្ធ | |

| ឈ្មោះគម្រោង៖ សាងសង់និងកែលម្អផ្លូវយុទ្ធសាស្ត្រសម្រួលចរាចរណ៍និងបរិស្ថានរាជធានី | អាទិភាព ១.ខ |
| --- | --- |
| **ប្រវត្តិគម្រោង** | |
| ជាតំបន់មានចរាចរណ៍ចង្អៀតដែលចាំបាច់ត្រូវរៀបចំនិងកែលម្អសម្រួលចរាចរណ៍តាមស្ថានភាពជាក់ស្តែងឱ្យបានសមស្របតាមការអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្តប្រកបដោយនិរន្តរភាពក្នុងរាជធានីភ្នំពេញ។ | |
| **បរិយាយគម្រោង** | |
| **សមាសភាគគម្រោង** | បើកផ្លូវថ្មីនិងពង្រីកបន្ថែមប្រព័ន្ធលូនិងលម្អសាធារណៈ |
| **រយៈពេលអនុវត្តគម្រោង** | គួរត្រូវបានអនុវត្តចាប់ពីឆ្នាំ២០១៨ដល់ឆ្នាំ២០២០ |
| **ទីតាំងគម្រោង** | ស្ថិតនៅក្នុងខណ្ឌព្រែកព្នៅ ផ្លូវលេខ១៥១ និងផ្លូវលេខ៤២ |
| **អង្គភាពអនុវត្តគម្រោង** | |
| មន្ទីរសាធារណការនិងដឹកជញ្ជូនរាជធានីភ្នំពេញ និងស្ថាប័នពាក់ព័ន្ធ | |

| ឈ្មោះគម្រោង៖ សាងសង់និងកែលម្អផ្លូវយុទ្ធសាស្ត្រសម្រួលចរាចរណ៍និងបរិស្ថានរាជធានី | អាទិភាព<br>១.គ |
|---|---|
| **ប្រវត្តិគម្រោង** | |
| ជាតំបន់ទេសចរណ៍មានចរាចរណ៍ចង្អៀតដែលចាំបាច់ត្រូវរៀបចំនិងកែលម្អសម្រួលចរាចរណ៍តាមស្ថានភាពជាក់ស្តែងបម្រើឱ្យវិស័យទេសចរណ៍សមស្របតាមការអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្តប្រកបដោយនិរន្តរភាពក្នុងរាជធានីភ្នំពេញ។ | |
| **បរិយាយគម្រោង** | |
| **សមាសភាគគម្រោង** | គួរត្រូវបានកែលម្អលម្អសាធារណៈដោយរៀបចំជាសួននិងចំណត |
| **រយៈពេលអនុវត្តគម្រោង** | គួរត្រូវបានអនុវត្តចាប់ពីឆ្នាំ២០១៨ដល់ឆ្នាំ២០២០ |
| **ទីតាំងគម្រោង** | ស្ថិតនៅភ្នំរាប ក្នុងសង្កាត់ពន្សាំង |
| **អង្គភាពអនុវត្តគម្រោង** | |
| មន្ទីរសាធារណការនិងដឹកជញ្ជូនរាជធានីភ្នំពេញ និងស្ថាប័នពាក់ព័ន្ធ | |

| ឈ្មោះគម្រោង៖ សាងសង់និងកែលម្អតំបន់ការពារនិងអភិរក្សធម្មជាតិ | អាទិភាព<br>១.ឃ |
|---|---|
| **ប្រវត្តិគម្រោង** | |
| ជាតំបន់ការពារនិងអភិរក្សធម្មជាតិដែលចាំបាច់ត្រូវរៀបចំ កែលម្អ និងការពារតាមស្ថានភាពជាក់ស្តែងបម្រើឱ្យវិស័យទេសចរណ៍សមស្របតាមការអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្តប្រកបដោយនិរន្តរភាពក្នុងរាជធានីភ្នំពេញ។ | |
| **បរិយាយគម្រោង** | |
| **សមាសភាគគម្រោង** | គួរត្រូវបានសាងសង់សំណង់ការពារច្រាំងបឹងនិងកែលម្អលម្អសាធារណៈ |
| **រយៈពេលអនុវត្តគម្រោង** | គួរត្រូវបានអនុវត្តចាប់ពីឆ្នាំ២០១៨ដល់ឆ្នាំ២០២០ |
| **ទីតាំងគម្រោង** | ស្ថិតនៅតាមមាត់បឹងសំរោងនិងបឹងតាមោក |
| **អង្គភាពអនុវត្តគម្រោង** | |
| មន្ទីរសាធារណការនិងដឹកជញ្ជូនរាជធានីភ្នំពេញ និងស្ថាប័នពាក់ព័ន្ធ | |

| ឈ្មោះគម្រោង៖ សាងសង់និងកែលម្អតំបន់ការពារនិងអភិរក្សធម្មជាតិ | អាទិភាព |
|---|---|
| | ១.ខ |

**ប្រវត្តិគម្រោង**

ជាតំបន់ការពារដែលចាំបាច់ត្រូវរៀបចំ កែលម្អ និងការពារតាមស្ថានភាពជាក់ស្តែងបម្រើឱ្យវិស័យទេសចរណ៍ សមស្របតាមការអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្តប្រកបដោយនិរន្តរភាពក្នុងរាជធានីភ្នំពេញ។

**បរិយាយគម្រោង**

| | |
|---|---|
| **សមាសភាគគម្រោង** | គួរត្រូវបានសាងសង់សំណង់ការពារច្រាំងបឹងនិងកែលម្អលម្អសាធារណៈ |
| **រយៈពេលអនុវត្តគម្រោង** | គួរត្រូវបានអនុវត្តចាប់ពីឆ្នាំ២០១៨ដល់ឆ្នាំ២០២០ |
| **ទីតាំងគម្រោង** | ស្ថិតនៅជុំវិញបឹងតាមោក |

**អង្គភាពអនុវត្តគម្រោង**

មន្ទីរសាធារណការនិងដឹកជញ្ជូនរាជធានីភ្នំពេញ និងស្ថាប័នពាក់ព័ន្ធ

## បញ្ជីគម្រោងអភិវឌ្ឍនិងផែនការសកម្មភាពតាមលំដាប់អាទិភាពបន្ទាប់

| ឈ្មោះគម្រោង៖ សាងសង់និងកែលម្អផ្លូវយុទ្ធសាស្ត្រសម្រួលចរាចរណ៍និងបរិស្ថានរាជធានី | អាទិភាព |
|---|---|
| | ២.ក |

**ប្រវត្តិគម្រោង**

ជាតំបន់មានដង់ស៊ីតេខ្ពស់ដែលចាំបាច់ត្រូវទប់ស្កាត់ឧបទ្ទវហេតុគ្រោះថ្នាក់ចរាចរណ៍និងធានាការប្រើប្រាស់ដីចំណីតាមបណ្តោយផ្លូវឱ្យបានសមស្របតាមការអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្តប្រកបដោយនិរន្តរភាពក្នុងរាជធានីភ្នំពេញ។

**បរិយាយគម្រោង**

| | |
|---|---|
| **សមាសភាគគម្រោង** | តាមដងផ្លូវសំខាន់ៗដែលមានទំហំចាប់ពី២០ម៉ែត្រឡើងទៅនិងភាគច្រើនជាតំបន់ពាណិជ្ជកម្មចម្រុះឬតំបន់ចម្រុះស្ថិតក្នុងលំដាប់អាទិភាពបន្ទាប់ |
| **រយៈពេលអនុវត្តគម្រោង** | គួរត្រូវបានអនុវត្តចាប់ពីឆ្នាំ២០២០ដល់ឆ្នាំ២០៣៥ |
| **ទីតាំងគម្រោង** | ស្ថិតនៅក្នុងខណ្ឌព្រែកព្នៅ |

**អង្គភាពអនុវត្តគម្រោង**

មន្ទីរសាធារណការនិងដឹកជញ្ជូនរាជធានីភ្នំពេញ និងស្ថាប័នពាក់ព័ន្ធ

| ឈ្មោះគម្រោង៖ សាងសង់និងកែលម្អផ្លូវយុទ្ធសាស្ត្រសម្រួលចរាចរណ៍និងបរិស្ថានរាជធានី | អាទិភាព ២.១ |
|---|---|

## ប្រវត្តិគម្រោង

ជាតំបន់មានដង់ស៊ីតេខ្ពស់ដែលចាំបាច់ត្រូវទប់ស្កាត់ឧបទ្ទវហេតុគ្រោះថ្នាក់ចរាចរណ៍ បង្កើនទំហំលម្ហបរិយាកាសពីតំបន់មួយទៅតំបន់ផ្សេងទៀត និងធានាការប្រើប្រាស់ដីចំណីតាមបណ្ដោយផ្លូវឱ្យបានសមស្របតាមការអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្តប្រកបដោយនិរន្តរភាពក្នុងរាជធានីភ្នំពេញ។

## បរិយាយគម្រោង

| | |
|---|---|
| **សមាសភាគគម្រោង** | តាមដងផ្លូវសំខាន់ៗដែលមានទំហំចាប់ពី២០ម៉ែត្រឡើងទៅ និងភាគច្រើនជាតំបន់ទេសចរណ៍ស្ថិតក្នុងលំដាប់អាទិភាពបន្ទាប់ |
| **រយៈពេលអនុវត្តគម្រោង** | គួរត្រូវបានអនុវត្តចាប់ពីឆ្នាំ២០២០ដល់ឆ្នាំ២០៣៥ |
| **ទីតាំងគម្រោង** | ស្ថិតនៅក្នុងខណ្ឌព្រែកព្នៅ |

## អង្គភាពអនុវត្តគម្រោង

មន្ទីរសាធារណការនិងដឹកជញ្ជូនរាជធានីភ្នំពេញ និងស្ថាប័នពាក់ព័ន្ធ

## ឧបសម្ព័ន្ធទី១៣ ប្លង់អាងបង្គន់អនាម័យនិងអាងប្រព្រឹត្តិកម្មទឹកកខ្វក់

អាងបង្គន់អនាម័យសំដៅដល់អាងទទួលទឹកកខ្វក់ពីបង្គន់អនាម័យនិងបន្ទប់ទឹកដើម្បីស្តុកនិងបំបែកសំណល់សរីរាង្គក្នុងទឹកកខ្វក់មុននឹងបង្ហូរចេញទៅក្នុងប្រព័ន្ធលូសាធារណៈ។ បទដ្ឋានអាងបង្គន់អនាម័យត្រូវបានកំណត់ដូចតទៅ៖

- ទំហំប្រើប្រាស់នៃអាងបង្គន់អនាម័យដោយគិតពីបាតអាងឡើងមកដល់បំពង់បង្ហូរចេញជាអប្បបរមា ៣ម៉ែត្រគ្រីគុណសម្រាប់លំនៅឋាន៣ម៉ែត្រគ្រីគុណក្នុងមួយជាន់នៃផ្ទះល្វែង ឬនៃភូមិគ្រឹះ៣ម៉ែត្រគ្រីគុណសម្រាប់ផ្ទៃក្រឡាកម្រាលសរុប៨០ម៉ែត្រទ្វេគុណ
- សណ្ឋាគារឬផ្ទះសំណាក់២ម៉ែត្រគ្រីគុណបូកបន្ថែម០,៥០ម៉ែត្រគ្រីគុណក្នុងមួយបន្ទប់
- កម្ពស់អាងបង្គន់អនាម័យពុំអាចទាបជាង១,៥០ម៉ែត្រ
- អាងបង្គន់អនាម័យត្រូវមានរន្ធបង្ហុយខ្ពស់ទៅលើ
- មិនត្រូវឱ្យទឹកភ្លៀងហូរចូលក្នុងអាងបង្គន់អនាម័យជាដាច់ខាត។



ពុះ ក-ក



ប្លង់អាងបង្គន់អនាម័យ

ចំពោះរោងចក្រ សហគ្រាស សិប្បកម្ម និងបុរីទាំងអស់ត្រូវម្ចាស់ការក្នុងការរៀបចំនិងបំពាក់នូវអាងប្រព្រឹត្តិកម្មទឹកកខ្វក់ដើម្បីសម្អាតសំណល់រាវដែលចេញពីរោងចក្រ សហគ្រាស សិប្បកម្ម និងបុរីទាំងនេះឱ្យស្របតាមបទដ្ឋានបច្ចេកទេសមុននឹងបង្ហូរចេញទៅក្នុងប្រព័ន្ធលូសាធារណៈ។ ប្លង់គំរូអាងប្រព្រឹត្តិកម្មទឹកកខ្វក់សម្រាប់សំណង់ឧស្សាហកម្មឬសំណង់ដែលមានសំណល់សរីរាង្គឬជាតិពុល។



ពុះ ក-ក



ប្លង់ប្រពន្ធ័អាងចម្រោះ




ប្លង់ពុះ ក-ក

1. អាងចម្រោះទឹកកាកសំណល់
2. អាងរម្ងាប់មេរោគ និងចម្រោះ
3. អាងបណ្តុះមេរោគ និងចម្រោះ
4. អាងរងកករ
5. អាងបូមទឹកចេញ
6. អាងរក្សាកាកសំណល់រឹង (ស្លែ)
7. បន្ទប់បច្ចេកទេស និងម៉ូទ័រផ្លុំខ្យល់
8. អាងទទួលទឹកភ្លៀង




ប្លង់គម្រោងប្រព្រឹត្តកម្មកាកសំណល់រាវ

# ឧបសម្ព័ន្ធទី១៤ ការកំណត់លេខផ្លូវនិងលេខផ្ទះ



ឧទាហរណ៍: ការដាក់ផ្លូវ និងលេខផ្ទះ ឬដីឡូត៍ ពីជើងមកត្បូង ពីកើតមកលិច

## ក- ការដាក់លេខផ្លូវនូវលេខគូនិងលេខសេស




គំនូសបង្ហាញការដាក់លេខផ្លូវ

- ការដាក់លេខផ្លូវដោយប្រើលេខគូគឺអនុវត្តចាប់ពីទិសខាងជើងមកទិសខាងត្បូងតាមលំដាប់ពីតូចមកធំ។ ផ្លូវលេខគូគឺជាផ្លូវដែលសណ្តូកពីទិសខាងកើតមកទិសខាងលិចឬចន្លោះទិសខាងកើត- ឦសានទៅទិសខាងលិច- នីរតីឬចន្លោះពីទិសខាងកើត- អាគ្នេយ៍ទៅទិសខាងលិច- ពាយ័ព្យ
- ការដាក់លេខផ្លូវដោយប្រើលេខសេសគឺអនុវត្តចាប់ពីទិសខាងកើតមកទិសខាងលិចតាមលំដាប់ពីតូចមកធំ។ ផ្លូវលេខសេសគឺជាផ្លូវដែលសណ្តូកពីទិសខាងជើងមកទិសខាងត្បូងឬចន្លោះពីទិសខាងជើង- ឦសានទៅទិសខាងត្បូង- នីរតីឬចន្លោះពីទិសខាងជើង- ពាយ័ព្យទៅទិសខាងត្បូង- អាគ្នេយ៍។

ក្នុងករណីផ្លូវរត់សណ្តូកក្នុងទិសផ្លូវលេខគូនិងផ្លូវលេខសេសផងត្រូវកំណត់យកលេខគូឬលេខសេសតាមលេខផ្លូវណាដែលមានភាគរយផ្លូវស្ថិតនៅច្រើនជាង។

ចំពោះលេខផ្លូវដែលដាក់តាមលំដាប់លេខរៀង ហើយត្រូវកាត់ផ្តាច់ដោយបរិក្ខារសាធារណៈឬឧបសគ្គផ្សេងៗដែលមិនអាចឆ្លងកាត់បានត្រូវប្រើលេខបន្តបន្ទាប់តាមលំដាប់លេខរៀង។

ការដាក់ឈ្មោះផ្លូវដោយដាក់ឈ្មោះរបស់អ្នកមានស្នាដៃជូនជាតិ វិរៈជនជាតិនិងអន្តរជាតិត្រូវអនុលោមតាមការអនុញ្ញាតដោយច្បាប់។

ការដាក់លេខផ្លូវត្រូវធ្វើសមាហរណកម្មទៅនឹងតំបន់ជាប់ព្រំប្រទល់ខណ្ឌតាមលេខរៀងលំដាប់តៗគ្នា។

**ខ-ការដាក់លេខផ្ទះ**







**គំនូសបង្ហាញការដាក់លេខផ្ទះឬដីឡូត៍ពីជើងមកត្បូង**　　**គំនូសបង្ហាញការដាក់លេខផ្ទះឬដីឡូត៍ពីកើតមកលិច**

ការដាក់លេខផ្ទះគឺអនុវត្តពីទិសខាងជើងមកទិសខាងត្បូងនិងពីទិសខាងកើតមកទិសខាងលិច ហើយចាប់ផ្ដើមដាក់លេខពីដើមទីនៃផ្លូវលេខរហូតដល់ចុងទីនៃផ្លូវលេខនីមួយៗ។

នៅពេលដែលមនុស្សឈរបែរមុខទៅទិសខាងជើងនៅលើបណ្ដោយផ្លូវដែលមានលេខសេសៈ

- នៅខាងស្ដាំដៃពីជើងមកត្បូងគឺជាលេខគូ ហើយការដាក់លេខផ្ទះឬដីឡូត៍ត្រូវអនុវត្តតាមលំដាប់លេខរៀងពីតូចមកធំ
- នៅខាងឆ្វេងដៃពីជើងមកត្បូងគឺជាលេខសេស ហើយការដាក់លេខផ្ទះឬដីឡូត៍ត្រូវអនុវត្តតាមលំដាប់លេខរៀងពីតូចមកធំ។

នៅពេលដែលមនុស្សឈរបែរមុខទៅទិសខាងកើតនៅលើបណ្ដោយផ្លូវដែលមានលេខគូៈ

- នៅខាងស្ដាំដៃពីកើតមកលិចគឺជាលេខគូ ហើយការដាក់លេខផ្ទះឬដីឡូត៍ត្រូវអនុវត្តតាមលំដាប់លេខរៀងពីតូចមកធំ។ ការដាក់លេខផ្ទះឬដីឡូត៍មកដល់ផ្លូវកែងលេខសេសត្រូវរំលងចំនួនពីរផ្ទះឬពីរដីឡូត៍នៅខាងកើតនិងខាងលិចផ្លូវដែលមានលេខសេស ទើបអនុវត្តការដាក់លេខរៀងបន្តពីតូចទៅធំទៀត ព្រោះផ្ទះឬដីឡូត៍នៅផ្លូវកែងនេះមានលំដាប់លេខរៀងពីជើងមកត្បូងរួចហើយ
- នៅខាងឆ្វេងដៃពីកើតមកលិចគឺជាលេខសេស ហើយការដាក់លេខផ្ទះឬដីឡូត៍អនុវត្តតាមលំដាប់លេខរៀងពីតូចមកធំ។ ការដាក់លេខផ្ទះឬដីឡូត៍មកដល់ផ្លូវកែងលេខសេសត្រូវរំលងចំនួនពីរផ្ទះឬពីរដីឡូត៍នៅខាងកើតនិងខាងលិចផ្លូវដែលមានលេខសេស ទើបអនុវត្តការដាក់លេខរៀងបន្តពីតូចទៅធំទៀត ព្រោះផ្ទះឬដីឡូត៍នៅផ្លូវកែងនេះមានលំដាប់លេខរៀងពីជើងមកត្បូងរួចហើយ។

ការដាក់លេខផ្ទះឬដីឡូត៍នេះត្រូវធ្វើសមាហរណកម្មនឹងតំបន់ជាប់ព្រំប្រទល់ខណ្ឌនិងមានលំដាប់លេខរៀងបន្តបន្ទាប់គ្នា។

ចំពោះដីឡូត៍ដែលមានលេខរួច ហើយដីឡូត៍នោះត្រូវធ្វើការសាងសង់ផ្ទះឬព្រុះជាច្រើនឡូត៍បន្តទៀត ការដាក់លេខផ្ទះឬដីឡូត៍ត្រូវអនុវត្តការដាក់ឈ្មោះលេខដើមដោយបន្ថែមអក្សរឡាតាំងតាមលំដាប់ពីតួអក្សរដំបូងបន្តបន្ទាប់តាមទិសពីជើងទៅត្បូងនិងពីកើតទៅលិច។

# ឧបសម្ព័ន្ធទី១៥ តំបន់ប្រើប្រាស់ដី កម្ពស់សំណង់ និងប្រភេទសំណង់

## កំណត់សម្គាល់

| តំបន់ប្រើប្រាស់ដី និងកម្ពស់សំណង់ | សន្ទស្សន៍ប្រើប្រាស់ដី | ផលធៀបក្រឡាផ្ទៃគម្របសំណង់ | អគារលំនៅឋាន (ភូមិគ្រឹះ និងពាក់កណ្តាលភូមិគ្រឹះ) | អគារលំនៅឋាន (ល្វែង និងផ្ទះល្វែង) | អគារលំនៅឋាន (អគារស្នាក់នៅរួម) | អគារពាណិជ្ជកម្ម (ភោជនីយដ្ឋាន) | អគារពាណិជ្ជកម្ម (សណ្ឋាគារ) | អគារពាណិជ្ជកម្ម (ផ្សារទំនើប) | អគារពាណិជ្ជកម្ម (ហាងទំនិញ) | អគារពាណិជ្ជកម្ម (កន្លែងលក់ទំនិញ) | អគារឧស្សាហកម្ម (រោងចក្រ) | អគារឧស្សាហកម្ម (ឃ្លាំង) | អគារសិក្សាធិការ អប់រំ និងកីឡា | អគារសុខាភិបាល (មន្ទីរពេទ្យ) | អគារសុខាភិបាល (គ្លីនិកឯកជន) | អគាររដ្ឋបាលសាធារណៈ ស្ថាប័នរដ្ឋ និងអគារពហុបំណង | សណ្ឋាគារ ផ្ទះសំណាក់ | ការិយាល័យឯកជន | ការិយាល័យពហុបំណង | ស្ថានីយប្រេងឥន្ធនៈ | អគារចំណតរថយន្ត | អគារផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| **I. ការកំណត់កម្ពស់សំណង់តាមសន្ទស្សន៍ប្រើប្រាស់ដី** | | | | | | | | | | | | | | | | | | | | | | |
| **ក. ប្រភេទដីអាចសាងសង់បាន** | | | | | | | | | | | | | | | | | | | | | | |
| ១. តំបន់លំនៅឋាន | | | | | | | | | | | | | | | | | | | | | | |
| ១.១ តំបន់លំនៅឋានដាច់ពីគ្នាកម្ពស់ទាប | FAR≤1.5 | BCR≤50% | ✓ | | | | | | | | | | | | | | | | | | | ✓ |
| ១.២ តំបន់លំនៅឋានជាប់គ្នាកម្ពស់ទាប | FAR≤1.5 | BCR≤75% | ✓ | ✓ | ✓ | | | | | | | | | | | | | | | | | ✓ |
| ១.៣ តំបន់លំនៅឋានកម្ពស់មធ្យមប្រភេទ១ | FAR≤3.0 | BCR≤60% | ✓ | ✓ | ✓ | | ✓ | | | ✓ | | | ✓ | ✓ | | | | | | | ✓ | ✓ |
| ១.៤ តំបន់លំនៅឋានកម្ពស់មធ្យមប្រភេទ២ | FAR≤3.0 | BCR≤60% | ✓ | ✓ | ✓ | | ✓ | | | ✓ | | | ✓ | ✓ | | | | | | | ✓ | ✓ |
| ១.៥ តំបន់លំនៅឋានកម្ពស់ខ្ពស់ប្រភេទ១ | FAR≤5.0 | BCR≤60% | ✓ | ✓ | ✓ | ✓ | ✓ | | | ✓ | | | ✓ | ✓ | | | | | | | ✓ | ✓ |
| ១.៦ តំបន់លំនៅឋានកម្ពស់ខ្ពស់ប្រភេទ២ | FAR≤5.0 | BCR≤60% | ✓ | ✓ | ✓ | ✓ | ✓ | | | ✓ | | | ✓ | ✓ | | | | | | | ✓ | ✓ |
| ១.៧ តំបន់លំនៅឋានចម្រុះ | FAR≤5.0 | BCR≤65% | ✓ | ✓ | ✓ | ✓ | ✓ | | ✓ | ✓ | | | ✓ | ✓ | | | | | | | ✓ | ✓ |
| ២. តំបន់ពាណិជ្ជកម្ម | | | | | | | | | | | | | | | | | | | | | | |
| ២.១. តំបន់ពាណិជ្ជកម្ម | FAR≤12 | BCR≤75% | | | | ✓ | ✓ | ✓ | ✓ | ✓ | | | ✓ | ✓ | ✓ | ✓ | ✓ | ✓ | | | ✓ | ✓ |
| ២.២. តំបន់ពាណិជ្ជកម្មចម្រុះ | FAR≤10 | BCR≤70% | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | | | ✓ | ✓ | ✓ | ✓ | ✓ | ✓ | | | ✓ | ✓ |
| ៣. តំបន់ឧស្សាហកម្ម | | | | | | | | | | | | | | | | | | | | | | |
| ៣.១. តំបន់ឧស្សាហកម្ម | FAR≤3.0 | BCR≤60% | | | | | | | | | ✓ | ✓ | | | | | | | | | | △ |
| ៣.២. តំបន់ឧស្សាហកម្មស្រាល | FAR≤3.0 | BCR≤60% | ✓ | ✓ | ✓ | | | | | | ✓ | ✓ | | | | | | | | | | △ |
| ៣.៣. តំបន់ឧស្សាហកម្មចម្រុះ | FAR≤3.0 | BCR≤60% | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | | | ✓ | △ |
| ៤. តំបន់ចម្រុះ | FAR≤10 | BCR≤70% | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | | | ✓ | ✓ | ✓ | ✓ | ✓ | ✓ | | | ✓ | ✓ |
| ៥. តំបន់ដឹកជញ្ជូន | FAR≤3.0 | BCR≤60% | | | | | | | | | | | | | | | | | ✓ | | | ✓ |
| ៦. តំបន់ទេសចរណ៍ | FAR≤5.0 | BCR≤50% | | | | ✓ | ✓ | ✓ | | ✓ | | | | | ✓ | | ✓ | | | | | ✓ |
| ៧. តំបន់រដ្ឋបាល និងសេវាសាធារណៈ | FAR≤5.0 | BCR≤60% | | | | | | | | ✓ | | | ✓ | ✓ | ✓ | | | ✓ | ✓ | | | ✓ |
| ៨. តំបន់លំហសាធារណៈ និងផ្ទៃបៃតង | FAR≤0.3 | BCR≤10% | | | | | | | | | | | | | | | | | | | | ✓ |
| ៩. តំបន់វប្បធម៌ និងសាសនា | FAR≤2.0 | BCR≤50% | | | | | | | | | | | ✓ | | | | | | | | | △ |
| ១០. តំបន់ផ្សេងៗ | FAR≤5.0 | BCR≤50% | △ | △ | △ | △ | △ | △ | △ | △ | △ | △ | △ | △ | △ | △ | △ | △ | △ | △ | △ | △ |
| **ខ. ប្រភេទដីកម្រិតការសាងសង់** | | | | | | | | | | | | | | | | | | | | | | |
| ១. តំបន់កសិកម្ម (ស្រែ ចំការ កសិដ្ឋាន ដំណាំក្នុងភូមិ) | | | | | | | | | | | | | | | | | | | | | | ✓ |
| ២. តំបន់ព្រៃឈើ (ព្រៃបម្រុងទុកអចិន្ត្រៃយ៍ ព្រៃឯកជន ព្រៃលិចទឹក) | | | | | | | | | | | | | | | | | | | | | | ✓ |
| ៣. តំបន់ធនធានទឹក | FAR≤1.5 | BCR≤30% | | | | | | | | | | | | | | | | | | | | ✓ |
| ៤. តំបន់ការពារ | | | | | | | | | | | | | | | | | | | | | | |
| ៥. តំបន់ផ្សេងៗកម្រិតការសាងសង់ | | | | | | | | | | | | | | | | | | | | | | ✓ |

**កម្ពស់អគារមានគ្រោះថ្នាក់**

- កម្ពស់ចាប់ពីជាន់ទី៤ ដល់ជាន់ទី១១
- កម្ពស់ចាប់ពីជាន់ទី១២ឡើងទៅ

**សម្គាល់**

➤ ការសាងសង់សំណង់ខ្ពស់ៗគ្រប់ប្រភេទ នៅក្នុងតំបន់គ្រប់គ្រងកម្ពស់ឧបសគ្គ ត្រូវអនុលោមតាម លិខិតលេខ០០៤១ រ.ល.អ.ស ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១០ របស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល។

✓ អនុញ្ញាតឱ្យសាងសង់ △ មានលក្ខខណ្ឌ

**ផ្លាកម្លាតអគារក្នុងដីល្បាក់ពីផ្លូវដីកាន់កាប់ច្បាប់**

| ល.រ | អគារដែលមានកម្ពស់ | គម្លាតពីព្រំដីចំណីផ្លូវ (ម៉ែត្រ) | គម្លាតមិនជាប់ព្រំដីចំណីផ្លូវ (ម៉ែត្រ) | ផ្សេងៗ |
|---|---|---|---|---|
| ១. | ចាប់ពីជាន់ផ្ទាល់ដី ដល់ជាន់ទី៨ | ≥ 4.00 | ≥ 2.00 | |
| ២. | ចាប់ពីជាន់ទី៩ ដល់ជាន់ទី១១ | ≥ 5.00 | ≥ 2.50 | |
| ៣. | ចាប់ពីជាន់ទី១២ ឡើងទៅ | > 5.00 | > 2.50 | |
| ៤. | ចាប់ពីជាន់ទី១២ ដល់ជាន់ទី២០ | ≥ 6.00 | ≥ 3.00 | សម្រាប់សំណង់ស្ថិតតាមបណ្តោយមហាវិថី |
| ៥. | ចាប់ពីជាន់ទី២១ ដល់ជាន់ទី៣០ | ≥ 8.00 | ≥ 3.50 | សម្រាប់សំណង់ស្ថិតតាមបណ្តោយមហាវិថី |
| ៦. | ចាប់ពីជាន់ទី៣១ ឡើងទៅ | ≥ 10.00 | ≥ 4.00 | សម្រាប់សំណង់ស្ថិតតាមបណ្តោយមហាវិថី |

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមហាផ្ទៃ**
**អគ្គនាយកដ្ឋានរដ្ឋបាល**

លេខៈ ៣១៦៤ អទប

**សូមជម្រាបជូន**
**ឯកឧត្តម លោកជំទាវ អភិបាល នៃគណៈអភិបាលរាជធានី ខេត្ត**

**កម្មវត្ថុ** ៖ ស្តីពីការជំរុញការសិក្សា និងការរៀបចំសំណុំបែបបទពាក់ព័ន្ធនឹងការកែសម្រួល និងកំណត់ព្រំប្រទល់រដ្ឋបាល និងបង្កើតក្រុង ស្រុក ខណ្ឌថ្មី។

**យោង** ៖ លិខិតលេខ ៦៣៧ សជណ ចុះថ្ងៃសុក្រ ៦រោច ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៨ របស់ក្រសួងមហាផ្ទៃ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប **ឯកឧត្តម លោកជំទាវ** ជ្រាបថា កន្លងមកក្រសួងមហាផ្ទៃបានធ្វើការណែនាំដល់រដ្ឋបាលរាជធានី ខេត្ត ឱ្យធ្វើការសិក្សា និងលើកសំណើសុំមកក្រសួងមហាផ្ទៃ ដើម្បីកែសម្រួល និងកំណត់ព្រំប្រទល់រដ្ឋបាល និងបង្កើតក្រុង ស្រុក ខណ្ឌថ្មី ដោយផ្អែកលើតម្រូវការចាំបាច់ បញ្ហាប្រឈម និងស្ថានភាពនៃការគ្រប់គ្រងជាក់ស្តែងឱ្យបានមុនដំណាច់ត្រីមាសទី៣ ឆ្នាំ២០១៨ ដូចមានក្នុងលិខិតចុះយោងខាងលើ។ ទន្ទឹមនេះដែរ អគ្គនាយកដ្ឋានរដ្ឋបាល ក៏បានធ្វើការប្រជុំជាមួយរាជធានី ខេត្ត ដើម្បីធ្វើការណែនាំអំពីគោលការណ៍ និងនីតិវិធីជាក់ស្តែងក្នុងការអនុវត្តកិច្ចការនេះរួចមកហើយ។

ដើម្បីបម្រើឱ្យការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ អាណត្តិទី៣ ដែលគ្រោងនឹងរៀបចំឡើងនៅពាក់កណ្តាលឆ្នាំ២០១៩ ការសិក្សា និងរៀបចំកែសម្រួលព្រំប្រទល់ និងការបង្កើតរដ្ឋបាលថ្មីនេះ ត្រូវធ្វើឱ្យបានរួចរាល់នៅមុនដំណាច់ឆ្នាំ២០១៨។ ដូច្នេះដើម្បីជួយជំរុញ និងសម្រេចការងារខាងលើនេះបានទាន់ពេលវេលា ខ្ញុំសូមស្នើដល់ **ឯកឧត្តម លោកជំទាវ** ពន្លឿនការសិក្សា និងការរៀបចំសំណុំបែបបទកែសម្រួលព្រំប្រទល់រដ្ឋបាល និងបង្កើតក្រុង ស្រុក ខណ្ឌថ្មី ជូនមកក្រសួងមហាផ្ទៃ **ឱ្យបានមុនថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៨ ជាកំណត់** ដើម្បីក្រសួងមហាផ្ទៃមានមូលដ្ឋានគ្រប់គ្រាន់ក្នុងការចាត់ចែងនីតិវិធីបន្ត។ ក្នុងករណីដែលរដ្ឋបាលរាជធានី ខេត្ត ពុំមានតម្រូវការចាំបាច់ក្នុងការកែសម្រួលព្រំប្រទល់រដ្ឋបាល និងសុំបង្កើតក្រុង ស្រុក ខណ្ឌថ្មីទេ ក៏សូមរាយការណ៍ជូនមកអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ ដើម្បីធ្វើការបូកសរុបរួចរាយការណ៍ជូនថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ **ឯកឧត្តម លោកជំទាវ អភិបាល នៃគណៈអភិបាលរាជធានី ខេត្ត** ជ្រាប និងចាត់ចែងអនុវត្តតាមការគួរ។

សូម **ឯកឧត្តម លោកជំទាវ** ទទួលនូវសេចក្តីរាប់អានពីខ្ញុំ។

ថ្ងៃសុក្រ ៣ កើត ខែស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែសីហា ឆ្នាំ២០១៨

**អគ្គនាយក**

ប្រាក់ សំអឿន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានីភ្នំពេញ
រដ្ឋបាលខណ្ឌព្រែកព្នៅ
លេខ ១១៥......បក

**សូមគោរពជូន**
**ឯកឧត្តមអភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ**

**កម្មវត្ថុ** ÷ ស្តីពីការស្នើសុំកែសម្រួល និងកំណត់ព្រំប្រទល់រដ្ឋបាល ខណ្ឌនិងខណ្ឌ សង្កាត់និងសង្កាត់ សង្កាត់និងស្រុក នៃរាជធានីភ្នំពេញ និងខេត្តឡើងវិញ។

**យោង** ÷ -លិខិតលេខ ៣១៦៨ អរប ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៨ របស់ក្រសួងមហាផ្ទៃ ។
- ស្មារតីអង្គប្រជុំសាលារាជធានីភ្នំពេញ ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៨។
- ស្មារតីអង្គប្រជុំផ្លូវប្លង់គោលប្រើប្រាស់ដីខណ្ឌនិងចក្ខុវិស័យឆ្នាំ២០៣៥ នៅរដ្ឋបាលខណ្ឌ នៅថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៨ ។
- ស្មារតីអង្គប្រជុំក្រុមប្រឹក្សាខណ្ឌ ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៨ ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទមានកត្តិយសសូមគោរពជម្រាបជូន **ឯកឧត្តមអភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ** មេត្តាជ្រាបថា ៖ ផ្អែកតាមអនុក្រឹត្យលេខ ៥៧៨ អនក្រ.បក ខណ្ឌព្រែកព្នៅមាន០៥ សង្កាត់ គឺសង្កាត់ព្រែកព្នៅ, សង្កាត់សំរោង, សង្កាត់ពញាពន់, សង្កាត់ពន្សាំង និងសង្កាត់គោករកា។ ដោយយោងលើការពិនិត្យស្ថានភាពភូមិសាស្ត្រជាក់ស្តែង និងដើម្បីងាយស្រួលក្នុងការគ្រប់គ្រងការងាររដ្ឋបាល ការគ្រប់គ្រង ការផ្តល់សេវា និងការការពារសន្តិសុខសុវត្ថិភាពជូនប្រជាពលរដ្ឋ រដ្ឋបាលខណ្ឌព្រែកព្នៅ សូមស្នើសុំកែសម្រួលព្រំប្រទល់រដ្ឋ-បាលខណ្ឌ រវាងខណ្ឌព្រែកព្នៅនិងខណ្ឌពោធិ៍សែន និងខណ្ឌព្រែកព្នៅនៃរាជធានីភ្នំពេញជាមួយស្រុកពញាឮនៃខេត្តកណ្តាលឡើងវិញ មានដូចខាងក្រោម៖

១. ស្នើសុំកែសម្រួលនិងកំណត់ព្រំប្រទល់រដ្ឋបាល ខណ្ឌព្រែកព្នៅនិងខណ្ឌពោធិ៍សែនជ័យ ដោយផ្ទេរមួយចំនួននៃសង្កាត់ស្ពាននិងសង្កាត់សំរោងក្រោម កាត់ចូលសង្កាត់គោករកា ខណ្ឌព្រែកព្នៅ ។ ផ្លូវកប់ស្រូវបានលាតសន្ធឹងកាត់ខណ្ឌព្រែកព្នៅ និងខណ្ឌពោធិ៍សែនជ័យ ដូច្នេះគណៈកម្មាធិការសុរិយោដីខណ្ឌព្រែកព្នៅ សូមស្នើសុំកែសម្រួលនិងកំណត់ព្រំប្រទលដូចខាងក្រោម៖

១.១ ខាងលិចផ្លូវកប់ស្រូវ ស្នើយកចំនុចចាប់ពីផ្លូវបេតុងចុះពីផ្លូវកប់ស្រូវទៅដល់ស្ពានឆ្លងអូរវត្តភ្នៀត ដែលមានប្រវែង ៤០២៩ម៉ែត្រ។ ត្រង់ចំនុចស្ពានឆ្លងអូរវត្តភ្នៀតនេះ ស្នើសុំជាព្រំប្រទល់រដ្ឋ

បាលរវាងខណ្ឌព្រែកព្នៅនិងខណ្ឌពោធិ៍សែនជ័យ។ តាមផ្លូវបេតុងនេះ ស្នើសុំកែតម្រូវខាងជើងផ្លូវជារដ្ឋបាលខណ្ឌព្រែកព្នៅ ហើយផ្នែកខាងត្បូងផ្លូវជារដ្ឋបាលខណ្ឌពោធិ៍សែនជ័យ ។ ដោយឡែកផ្លូវក្រោមស្ពានវត្តភ្លៀតនេះទៅទិសខាងលិច ស្នើសុំជាព្រំប្រទល់រដ្ឋបាលរវាងខណ្ឌព្រែកព្នៅ និងខណ្ឌពោធិ៍សែនជ័យ ដោយយកខាងជើងអូរជាទឹកដីខណ្ឌព្រែកព្នៅ ហើយខាងត្បូងជាទឹកដីខណ្ឌពោធិ៍សែនជ័យ ។ ទឹកដីរដ្ឋបាលខណ្ឌពោធិ៍សែនជ័យដែលស្នើសុំកាត់ចូលមកខណ្ឌព្រែកព្នៅមានទំហំ ៣.៦៨៧.៥៨៦ម៉ែត្រក្រឡា ។

១.២ខាងកើតផ្លូវកប់ស្រូវ ស្នើសុំកែតម្រូវយកផ្លូវបេតុងចាប់ពីផ្លូវទំនប់កប់ស្រូវចម្ងាយ៨៧៩ម៉ែត្របត់ស្តាំតាមផ្លូវបេតុងរោងចក្របារីភូមិអង្គតាកូវនិងឆ្លោះតាមផ្លូវរវាងភូមិត្រពាំងសំព័រសង្កាត់គោករកានិងភូមិស្រែរមៀ ភូមិចំការស្បែង ភូមិគោកព្រិច សង្កាត់សំរោងក្រោម រហូតដល់ប្រឡាយ។ **ត្រង់ចំនុចប្រឡាយនេះ ស្នើសុំជាព្រំប្រទល់រដ្ឋបាលខណ្ឌព្រែកព្នៅនិងខណ្ឌពោធិ៍សែនជ័យ។**

២. ស្នើសុំកែតម្រូវព្រំប្រទល់រដ្ឋបាលសង្កាត់ពញាពន់ ខណ្ឌព្រែកព្នៅ និង ឃុំឈ្វាំង ស្រុកពញាឮ ព្រោះព្រំប្រទល់បច្ចុប្បន្នពិបាកធ្វើការកំណត់ដោយរត់កាត់ភូមិ ដីស្រែប្រជាពលរដ្ឋដោយពុំអាចសន្មត់យកអ្វីជាគោលនៃព្រំប្រទល់រដ្ឋបាលខណ្ឌព្រែកព្នៅនិងស្រុកពញាពន់ ដូច្នេះស្នើសុំយកផ្លូវត្រសក្រហមចាប់ពីផ្លូវបេតុងកែងផ្លូវត្រសក្រហមភូមិត្រពាំងព្រីង(ផ្លូវខាងក្រោយវត្តប្រាសាទ ) ទៅដល់វត្តព្រៃព្រីងនិងវត្តប្រសិទ្ធិក្រោមផ្នែកខាងជើងឆ្ពោះទៅទល់ផ្លូវ១៥១(ផ្លូវភ្នំបាសិត) ដែលមានប្រវែង **៤២៧៥ ម៉ែត្រ**។

សូមជូនភ្ជាប់ ៖ ផែនទីកែតម្រូវព្រំប្រទល់ ។

សូម **ឯកឧត្តមអភិបាល** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ ។

ថ្ងៃអង្គារ ៩រោច ខែកត្តិក ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២
ព្រែកព្នៅ ថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៨

**អភិបាល នៃគណៈអភិបាលខណ្ឌព្រែកព្នៅ**

សុខ_សម្បត្តិ

# ឧបសម្ព័ន្ធទី១៧ ប្លង់គោលប្រើប្រាស់ដីខណ្ឌព្រែកព្នៅ ចក្ខុវិស័យឆ្នាំ២០៣៥



ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្ម ថ្នាក់ជាតិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលរាជធានីភ្នំពេញ
គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្ម រាជធានីភ្នំពេញ

# ប្លង់គោលប្រើប្រាស់ដីខណ្ឌព្រែកព្នៅនៃរាជធានីភ្នំពេញ ចក្ខុវិស័យឆ្នាំ២០៣៥



## មាត្រដ្ឋានផែនទី

មាត្រដ្ឋាន ១/៣០០០០

0 ២៥០ ៥០០ ១០០០ ១៥០០ ២០០០ ម៉ែត្រ

COORDINATE SYSTEM: WGS_1984_UTM_Zone_48N

**មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ**

សិក្សាដោយ : ការិយាល័យរៀបចំដែនដី និងនគរូបនីយកម្ម
រៀបចំដោយ : លោក ហ៊ឿន វុត្ថសុខា អនុប្រធានការិយាល័យរៀបចំដែនដី និងនគរូបនីយកម្ម
ពិនិត្យដោយ : លោក ពីង តេង: ប្រធានការិយាល័យរៀបចំដែនដី និងនគរូបនីយកម្ម

គាំទ្របច្ចេកទេសដោយ: អគ្គលេខាធិការដ្ឋានគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ

# ប្លង់គោលប្រើប្រាស់ដីខណ្ឌព្រែកព្នៅ

## ចក្ខុវិស័យឆ្នាំ ២០៣៥



**រៀបចំដោយ**

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ**

អាសយដ្ឋាន: ដីឡូត៍លេខ ២០០៥ ផ្លូវលេខ ៣០៧ សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ
ទូរសព្ទ (៨៥៥) ២៣ ៨៨៦ ៩៩៩
គេហទំព័រ www.mlmupc.gov.kh អ៊ីមែល mlmupc.cabinet@gmail.com

ប្លង់គោលប្រើប្រាស់ដីខណ្ឌព្រែកព្នៅ ចក្ខុវិស័យឆ្នាំ ២០៣៥